# អដ្ឋកថា បបញ្ចសូទនី

## នៃព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសក

## អដ្ឋមភាគ

# លេខ ២៧

ពុទ្ធសករាជ ២៥៥៤

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសក

### អដ្ឋមភាគ

### ភាគ ២៧

ឈ្មោះ

## បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៤

អធិប្បាយ

**សុញ្ញតវគ្គ**

រួមមាន ១០ សូត្រ

# ស្រៈនិងសញ្ញា

# *Signes et accents.*



B

# ស្រៈពេញតួ

## *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# Consonnes.

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក | ខ | គ | ឃ | ង |
| ឡាតាំង Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| សិង្ហ Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡូប Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| លង្កា Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

F

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| [illegible] [illegible] | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

G

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຠ | ມ |
| សិង្ហ Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ | រ | ល | វ | ស | ហ | ឡ | ំ | ។ |
| រ៉ូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | ෴ |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភុតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភុតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបានទូវសេចក្ដី*

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញុំាងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធនូៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសិរីៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរ:ជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា**ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុឋៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយទមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ភ្លាត ហ៊ន | ឧបាសក នាក់ ម៉ៅ
ឧបាសក ទុំ ទួន | ឧបាសក ហុក ស៊ីងហួត
ឧបាសក ជឹម ជំនិត | ឧបាសក កើត ឌិត្យ
ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន
ឧបាសក អ៊ឹម រ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត
ឧបាសក សំ ឆាយ | ឧបាសក ម៉ៅ ផុន
ឧបាសក ជា ស៊ីបាន | ឧបាសិកា ថាប់ លឿម
ឧបាសិកា ហាយ សារ៉ាត់ | ឧបាសិកា ប៊ុត សុម៉ាលី
ឧបាសិកា យស សម្បត្តិ | ឧបាសិកា ពូ ហ៊ាង
ឧបាសិកា ប៊ុត សេដាដួង | ឧបាសិកា មុំ

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នូវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

| | |
|---|---|
| ឧបាសក ក្អាត ហ៊ិន | ឧបាសក ហាយ ចំរើន |
| ឧបាសក ហុក សឹងហួត | ឧបាសក អ៊ីម រ៉ៃយ៉ា |
| ឧបាសក ឈួន សំណាង | ឧបាសក ឃឿម សារ៉ែន |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណ:

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

*ឈ្មោះធម៌* | *ទំព័រ*

## ទេវទហវគ្គ


| | |
|---|---|
| **អដ្ឋកថា ទេវទហសូត្រ ទី ១** | ១ |
| *ទិដ្ឋធម្មវេទនីយកម្ម* | *៧* |
| *សម្បរាយវេទនីយកម្ម* | *១៣* |
| *អ្នកប្រកបសេចក្ដីព្យាយាម.....* | *២២* |
| **អដ្ឋកថា បញ្ចត្តយសូត្រ ទី ២** | ២៥ |
| *កប្ប ២ យ៉ាង* | *២៦* |
| *អធិប្បាយ ទិដ្ឋ សុត មុត វិញ្ញាត* | *៣៣* |
| *សត្វ ៤ ជំពូក ខ្លាចវត្ថុដែលមិនគួរខ្លាច* | *៣៥* |
| *ការប្រកាន់ខន្ធអតីត: ១៨* | *៣៧* |
| *ទិដ្ឋិ ៦២* | *៤២* |
| *អត្ថនៃព្រះនិព្វាន* | *៤៤* |
| **អដ្ឋកថា កិន្តិសូត្រ ទី ៣** | ៤៧ |
| *ព្យញ្ជនៈមិនជាប្រមាណក្នុងព្រះសូត្រ* | *៤៩* |
| **អដ្ឋកថា សាមគាមសូត្រ ទី ៤** | ៥៥ |
| *និគ្រន្ថនាដបុត្ត* | *៥៧* |
| *ការវិវាទ.......* | *៦២* |
| *ព្រោះហេតុនៃអាជីវៈ* | *៦៤* |
| *ការមិនគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ក្នុងសិក្ខា* | *៦៩* |

អធិករណ៍ ៤ យ៉ាង ៧២
ពាក្យថា ធម៌ជាដើម ៧៨
វិវាទាធិករណ៍ រម្ងាប់ដោយសមថៈ ២ ៨១

**អដ្ឋកថា សុនក្ខត្តសូត្រ ទី ៥ ៨៥**
ការបង្អោនទៅក្នុងអាមិស..... ៨៦
សេចក្តីលំបាក................. ៩០
ទោសដែលជាពិស គឺ អវិជ្ជា ៩២
កម្លាំងព្រះខីណាស្រព ៩៣

**អដ្ឋកថា អានេញ្ជសប្បាយសូត្រ ទី ៦ ៩៥**
អធិប្បាយពាក្យថា កាម ៩៥
ការគ្របសង្កត់កាម ៩៩
ត្រាស់ការច្នៃឱយៈ ១១២

**អដ្ឋកថា គណកមោគ្គល្លានសូត្រ ទី ៧ ១១៦**
ព្រះខីណាស្រព ២ ពួក ១១៧

**អដ្ឋកថា គោបកមោគ្គល្លានសូត្រ ទី ៨ ១២០**
វស្សការព្រាហ្មណ៍ ១២៤

**អដ្ឋកថា មហាបុណ្ណមសូត្រ ទី ៩ ១២៧**
ឧបោសថសីល ១២៨
សេចក្តីប្រាថ្នា ១៣២
ការបញ្ញត្តិថា ខន្ធ ១៣៣

| | |
|---|---|
| អដ្ឋកថា ចូឡបុណ្ណមសូត្រ ទី ១០ | ១៣៧ |
| *សេពគប់ជាមួយអសប្បុរស* | ១៣៨ |
| *មិនគោរពក្នុងទាន* | ១៣៩ |
| **អនុបទវគ្គ ទី ២** | ១៤២ |
| អដ្ឋកថា អនុបទសូត្រ ទី ១ | ១៤២ |
| *ហេតុឲ្យកើតបណ្ឌិត* | ១៤៣ |
| *បញ្ញាច្រើន បញ្ញាក្រាស់* | ១៤៤ |
| *ព្រះអគ្គសាវកសម្រេចធម៌ ដែនខេត្ត ២ យ៉ាង* | ១៤៩ |
| អដ្ឋកថា ឆព្វិសោធនសូត្រ ទី ២ | ១៦១ |
| *សេចក្ដីសម្គាល់របស់ធាតុ* | ១៦៣ |
| *រូប* | ១៦៤ |
| *ហេតុផលដែលត្រាស់អាសវក្ខយញ្ញាណ* | ១៦៦ |
| *ឆព្វិសោធនិយធម៌* | ១៦៦ |
| *រឿងព្រះទីឃភាណកអភយត្ថេរ* | ១៧២ |
| អដ្ឋកថា សប្បុរិសធម្មសូត្រ ទី ៣ | ១៧៤ |
| *វិនិច្ឆ័យ និរោធវារៈ* | |
| អដ្ឋកថា សេវិតព្វាសេវិតព្វសូត្រ ទី ៤ | ១៧៨ |
| *សមាចារ* | ១៧៨ |
| *ព្រះអនាគាមីនៅមានភវតណ្ហា* | ១៧៩ |

អត្តភាពបុថុជ្ជនមានទុក្ខ ១៨០

ទុក្ខមិនមានដល់អ្នកមិនបដិសន្ធិ ១៨២

**អដ្ឋកថា ពហុធាតុកសូត្រ ទី ៥ ១៨៤**

ភ័យ ឧបទ្រវៈ ឧបសគ្គ ១៨៤

ភ័យកើតអំពីជនពាល ១៨៦

រូបបរិគ្គហៈ-អរូបបរិគ្គហៈ ១៨៧

អធិប្បាយ សុខធាតុ ១៨៩

អធិប្បាយ កាមធាតុ ១៩០

អាយតនៈក្នុង-អាយតនៈក្រៅ ១៩២

ឋានៈ-ឱកាស ១៩២

ព្រះអរិយៈអាចមិនដឹងក្នុងជាតិតទៅ ១៩៥

វិនិច្ឆ័យអនន្តរិយកម្ម ៥ ១៩៨

វិនិច្ឆ័យដោយកម្ម ១៩៩

វិនិច្ឆ័យដោយទ្វារ ២០៤

វិនិច្ឆ័យដោយវិបាក ២០៥

វិនិច្ឆ័យដោយសាធារណៈជាដើម ២០៦

ខេត្ត ៣ ២០៧

ព្រះពុទ្ធមិនឧបត្តិក្នុងចក្រវាឡដទៃ ២០៨

អន្តរធាន ៣ ២០៩

ព្រះបរិយត្តិអន្តរធាន ២១១

បរិនិព្វាន ៣ ២១២

ការប្រជុំនៃព្រះធាតុ ២១៣

ស្តេចចក្រពត្តិមិនឧបត្តិព្រមគ្នា ២២២

ស្ត្រីមិនជាព្រះពុទ្ធ ២២៣

ភេទប្រុស-ស្រីមិនមានក្នុងព្រហ្មលោក ២២៥
កាយទុច្ចរិត-កាយសុចរិត ២២៦
សមង្គី ៥ ២២៧
ឧបមានិមិត្តប្រាកដ ២២៩

**អដ្ឋកថា ឥសីគិលិសូត្រ ទី ៦ ២៣៤**
ប្រវត្តភ្នំឥសីគិលិ ២៣៤
ព្រះនាមរបស់ព្រះបច្ចេកពុទ្ធ ២៣៧

**អដ្ឋកថា មហាចត្តារីសកសូត្រ ទី ៧ ២៤១**
ឧបមាដូចអ្នកស្រែ ២៤២
អធិប្បាយបទ តក្កៈ-អប្បនា-វចីសង្ខារ ២៤៥
អារតិ វិរតិ បដិវិរតិ វេរមណី ២៣៦
អធិប្បាយ កុហនា ២៣៧
អ្នកមានសម្មាទិដ្ឋិ ក៏មានសម្មាសង្កប្បៈ ២៣៩
សម្មាទិដ្ឋិ ៥ ២៥១
វាទៈ ៣ ២៥២

**អដ្ឋកថា អនាបានស្សតិសូត្រ ទី ៨ ២៥៥**
អធិប្បាយ កាយ ២៦០
អធិប្បាយ វេទនា ២៦១
អធិប្បាយ ចិត្ត ២៦៤
អធិប្បាយ ធម៌ ២៦៥
អធិប្បាយ ពោជ្ឈង្គធម៌ ២៦៧

**អដ្ឋកថា កាយគតាសតិសូត្រ ទី ៩ ២៦៩**

អធិប្បាយ គេហសិត ២៦៩
អធិប្បាយ វិជ្ជា ២៧០

**អដ្ឋកថា សង្ខារូបបត្តិសូត្រ ទី ១០ ២៧៤**
ធម៌ ៥ ប្រការ ២៧០
ឧបមាផ្លែកន្ទួតព្រៃ ២៧៥
មាសជម្ពូនុទ ២៧៦
ការផ្សាយ ៥ យ៉ាង ២៧៧
ធម៌ ៥ យ៉ាង ឲ្យដល់ព្រហ្មលោក និងអស់អាសវៈ ២៧៨

# អដ្ឋកថា សុត្តន្តបិដក

## ឈ្មោះ បបញ្ចសូទនី

## អដ្ឋកថា មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

## អដ្ឋមភាគ

# លេខ ២៧

## សុញ្ញតវគ្គ

## អ ដ្ឋ ក ថា

## ចូឡសុញ្ញតសូត្រទី ១

**[១]** *ចូឡសុញ្ញតសូត្រ មានបទផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖*

*ក្នុងបទទាំងនោះ បទថា ឯកមិទំ សេចក្តីថា បានឮថា ព្រះថេរៈធ្វើវត្តចំពោះព្រះមានព្រះភាគ ហើយទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កំណត់វេលាហើយអង្គុយចម្រើនសុញ្ញតាផលសមាបត្តិ មានព្រះនិព្វានជាអារម្មណ៍ ហើយចេញតាមវេលាដែលកំណត់ ។ លំដាប់នោះ សង្ខាររបស់លោកប្រាកដដោយសភាពជារបស់សូន្យ លោកប្រាថ្នាស្តាប់សុញ្ញតាកថា ក៏មានសេចក្តីគិតយ៉ាង*

នេះថា យើងមានធុរៈរវល់ មិនអាចទៅក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាត្រាស់សុញ្ញតាកថា ដល់ខ្ញុំព្រះអង្គ ណ្ហើយចុះយើងនឹងសូមឲ្យព្រះអង្គ រលឹកដល់ប្រការដែលព្រះអង្គចូលទៅអាស្រ័យ និគមឈ្មោះ នគរកៈ ត្រាស់កថារឿងមួយនោះ ព្រះមានព្រះភាគនឹងត្រាស់សុញ្ញតា-កថាដល់យើងយ៉ាងនេះ ។ កាលព្រះអានន្ទ នឹងសូមឲ្យព្រះទសពលទ្រង់រលឹកបានទើបពោលពាក្យថា **ឯកមិទំ** ជាដើម ។ បទថា **ឥទំ** ក្នុងបទថា **ឯកមិទំ** នោះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា **កច្ចិ មេតំ ភន្តេ** សេចក្តីថា ព្រះថេរៈចាំបានត្រឹមតែមួយបទ ក៏អាចនឹងកាន់យក ទ្រទ្រង់ចាំទុក បានដល់ ៦ ម៉ឺនបទ ព្រោះដូច្នោះ លោកមិនអាចដើម្បីនឹងមានសុញ្ញតាវិហារធម៌ ហើយទ្រទ្រង់ចាំបទសូម្បីត្រឹមតែមួយបទ ដូច្នោះ ការដែលអ្នកប្រាជ្ញនឹងស្តាប់ ធ្វើដូចជាអ្នកដឹងហើយសួរមិនសមគួរ ។ ព្រះថេរៈបំណងនឹងស្តាប់សុញ្ញតាកថាដែលព្រះអង្គទ្រង់សម្តែងទុកយ៉ាងពិស្តារឲ្យជាក់ច្បាស់ ទើបក្រាបទូលយ៉ាងនេះដូចជាមិនដឹង បុគ្គលខ្លះសូម្បីមិនដឹង ក៏ធ្វើដូចជាដឹង ។ ព្រះថេរៈនឹងធ្វើការបញ្ចោតបន្ទំយ៉ាងនេះបានយ៉ាងណា ។ ព្រះថេរៈសម្តែងសេចក្តីគោរពចំពោះព្រះមានព្រះភាគទើបក្រាបទូលពាក្យជាដើមថា **កច្ចិ មេតំ** ដូច្នេះ សូម្បីក្នុងឋានៈ

ដែលខ្វនដឹង ។

បទថា **បុព្វេ** សេចក្តីថា សូម្បីក្នុងវេលាដែលចូលទៅអាស្រ័យនិគម ឈ្មោះថា **នគរកៈ** ក្នុងបឋមពោធិកាល ។ បទថា **ឯត្តរហិ** ប្រែថា សូម្បីក្នុង កាលឥឡូវនេះ ។ ព្រះមានព្រះភាគ លុះត្រាស់យ៉ាងនេះហើយ ទើបមានព្រះពុទ្ធ-តម្រិះថា អានន្ទប្រាថ្នានឹងស្តាប់សុញ្ញតាកថា ក៏បុគ្គលខ្វះអាចនឹងស្តាប់ តែមិន អាចនឹងរៀន បុគ្គលខ្វះអាចទាំងស្តាប់ទាំងរៀន តែមិនអាចនឹងសម្តែង តែ សម្រាប់ព្រះអានន្ទ អាចទាំងស្តាប់ ទាំងរៀន ទាំងសម្តែង តថាគតនឹងពោល សុញ្ញតាកថាដល់គេ ។ កាលនឹងត្រាស់សុញ្ញតាកថានោះ ទើបត្រាស់ពាក្យ មានជាដើមថា **សេយ្យថាបិ** ដូច្នេះ ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុញ្ញោ ហត្ថិគវាស្សវឡវេន** នោះ សេចក្តី ថា ដំរីជាដើម ដែលគេធ្វើជាដំរីឈើ ដំរីជីស្អិត គំនូរដំរី មាននៅក្នុងប្រាសាទ នោះ ប្រាក់មាសដែលធ្វើជាចិត្រកម្មក្នុងទីតាំងរបស់ស្តេចវេស្សវ័ណ ស្តេចមន្ធា-ធាតុរាជជាដើមខ្វះ ដែលគេប្រកបត្រង់បង្អួច ទ្វារ និងគ្រែ តាំង ដែលប្រដាប់ ដោយប្រាក់មាសនោះ ដែលរក្សាទុកដើម្បីបដិសង្ខរណៈ (ជួសជុល) របស់ចាស់ ក៏មាន ។ សូម្បីបុរសស្ត្រីដែលមកស្តាប់ធម៌ និងសួរបញ្ហាជាដើម ក៏គេធ្លាក់

ទុកជារូបឈើជាដើម ដូច្នោះ ប្រាសាទនោះ ទើបមិនមានរូបរបស់បុរសស្ត្រីទាំងនោះ ។ លោកពោលពាក្យនេះ សំដៅដល់ការមិនមាននៃដំរីជាដើម ដែលមានវិញ្ញាណជាប់ដោយឥន្ទ្រិយ ប្រាក់ និងមាសដែលប្រើប្រាស់ ក្នុងខណៈដែលត្រូវការ (ក៏មិនអាចប្រើប្រាស់បាន) មានតែរូបចម្លាក់បុរសស្ត្រី ដែលនៅជានិច្ច ។ បទថា **ភិក្ខុសង្ឃំ បដិច្ច** សេចក្តីថា សូម្បីភិក្ខុទាំងឡាយនឹងចូលទៅបិណ្ឌបាតប្រាសាទនោះ ក៏មិនទំនេរចាកភិក្ខុដែលត្រេកអរនឹងភត្តក្នុងវិហារ និងភិក្ខុដែលឈឺ ភិក្ខុព្យាបាលជម្ងឺ ភិក្ខុដែលសិក្សា ភិក្ខុដែលខ្វល់ខ្វាយចីវរកម្មជាដើម ដោយប្រការដូច្នេះ ។ លោកទើបពោលយ៉ាងនេះ ព្រោះមានភិក្ខុនៅជាប្រចាំ ។ បទថា **ឯកត្តំ** ប្រែថា ភាវៈតែមួយ អធិប្បាយថា មិនទំនេរ ។ លោកអធិប្បាយថា មានភាពមិនទំនេរតែម្យ៉ាង ។

[២] បទថា **អមនសិករិត្វា** ប្រែថា មិនធ្វើទុកក្នុងចិត្ត ។ បទថា **អនាវជ្ជិត្វា** ប្រែថា មិនពិចារណា ។ បទថា **គាមសញ្ញំ** សេចក្តីថា សម្គាល់ថា ជាស្រុក ឬសម្គាល់ថា មានស្រុក គឺ ដោយអំណាចការប្រព្រឹត្តទៅនៃកិលេស ។ សូម្បីក្នុងមនុស្សសញ្ញា ក៏មានន័យតែម្យ៉ាងនោះឯង ។ បទថា **អរញ្ញសញ្ញំ បដិច្ចមនសិករោតិ ឯកត្តំ** សេចក្តីថា ធ្វើទុកក្នុងចិត្តនូវព្រៃនេះថា ជាអរញ្ញសញ្ញា

ចំពោះព្រៃតែម្យ៉ាងប៉ុណ្ណោះ យ៉ាងនេះថា នេះដើមឈើ នេះភ្នំ នេះព្រៃស្រោង ដែលខៀវ ។ បទថា **បក្ខន្ទតិ** ប្រែថា ធ្លាក់ចុះ ។ បទថា **អធិមុច្ចតិ** ប្រែថា បង្អោនទៅថាយ៉ាងនេះ ។ បទថា **យេ អស្សុ ទរថា** សេចក្តីថា សេចក្តីក្រវល់ក្រវាយដែលប្រព្រឹត្តទៅហើយក្តី សេចក្តីខ្វល់ខ្វាយព្រោះកិលេសក្តី ដែលនឹងគប្បីមានព្រោះអាស្រ័យគាមសញ្ញាទាំងនោះ រមែងមិនមានដោយអរញ្ញសញ្ញាក្នុងព្រៃនេះ ។ សូម្បីក្នុងបទទីពីរ ក៏ន័យនេះដូចគ្នា ។ បទថា **អត្ថិ ចេវាយំ** សេចក្តីថា មានត្រឹមតែសេចក្តីខ្វល់ខ្វាយដែលប្រព្រឹត្តទៅ ដែលកើតឡើងព្រោះអាស្រ័យអរញ្ញសញ្ញាតែម្យ៉ាង ។ បទថា **យំ ហិ ខោ តត្ថ ន ហោតិ** សេចក្តីថា សេចក្តីខ្វល់ខ្វាយដែលប្រព្រឹត្តទៅហើយ និងសេចក្តីខ្វល់ខ្វាយព្រោះកិលេសដែលកើតឡើងដោយគាមសញ្ញា និងមនុស្សសញ្ញានោះ រមែងមិនមានក្នុងអរញ្ញ-សញ្ញានេះ ដូចដំរីជាដើម មិនមានក្នុងប្រាសាទរបស់នាងវិសាខាមិគារមាតា ។ បទថា **យំ បន តត្ថ អវសិដ្ឋំ** សេចក្តីថា នៅមានត្រឹមតែសេចក្តីខ្វល់ខ្វាយដែលប្រព្រឹត្តទៅក្នុងអរញ្ញសញ្ញានោះ ។ ដូចភិក្ខុសង្ឃដែលនៅក្នុងប្រាសាទរបស់នាងវិសាខាមិគារមាតា ។ បទថា **តំ សន្តមិទំ អត្ថីតិ បជានាតិ** សេចក្តីថា ដឹងច្បាស់វត្ថុនោះដែលមានប៉ុណ្ណោះថា នេះមាន ។ បទថា **សុញ្ញតាវក្កន្តិ** ប្រែ

ថា ការកើតឡើងនៃសុញ្ញតា ។

[៣] បទថា **អមនសិករិត្វា មនុស្សសញ្ញំ** គឺ មិនកាន់យកតាមសញ្ញាក្នុងបទនេះ ។

ព្រោះហេតុអ្វី ។

ព្រោះបានឮថា ភិក្ខុនោះមានសេចក្តីគិតយ៉ាងនេះថា យើងនឹងញ៉ាំងគាមសញ្ញាឲ្យកើតដោយមនុស្សសញ្ញា ញ៉ាំងមនុស្សសញ្ញាឲ្យកើតដោយអរញ្ញសញ្ញា ញ៉ាំងអរញ្ញសញ្ញាឲ្យកើតដោយបឋវីសញ្ញា ញ៉ាំងបឋវីសញ្ញាឲ្យកើតដោយអាកាសានញ្ចាយតនសញ្ញា ។ល។ ញ៉ាំងអាកិញ្ចញ្ញាយតនសញ្ញាឲ្យកើត ដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ញ៉ាំងនេវសញ្ញានាសញ្ញាយតនសញ្ញាឲ្យកើតដោយវិបស្សនា ញ៉ាំងវិបស្សនាឲ្យកើតដោយមគ្គ នឹងសម្តែងអច្ចន្តសុញ្ញតាដោយលំដាប់ ដូច្នោះ ទើបផ្តើមទេសនាយ៉ាងនេះ ។

ក្នុងបទទាំងនោះ បទថា **បឋវីសញ្ញំ** សេចក្តីថា ព្រោះហេតុអ្វីទើបលះអរញ្ញសញ្ញា ហើយធ្វើទុកក្នុងចិត្តនូវបឋវីសញ្ញា ។ ព្រោះសម្រេចគុណពិសេសដោយអរញ្ញសញ្ញា ។ ប្រៀបដូចបុរសឃើញទីស្រែដែលគួរកើកកាយ ក៏ក្រឡេកមើលទីស្រែរហូត ៧ ដង ដោយគិតថា ស្រូវសាលីជាដើម ដែលសាបព្រោះ

ចុះក្នុងស្រែនេះ នឹងសម្បូរណ៍ដោយល្អ យើងនឹងបានលាភធំ ស្រូវសាលីជាដើម រមែងមិនសម្បូរណ៍ឡើយ តែបើគេធ្វើទីនោះឲ្យប្រាសចាកជង្គត់ និងបន្លាហើយ ក្ជួរ សាបព្រោះ កាលធ្វើយ៉ាងនេះ ស្រូវសាលីរមែងសម្បូរណ៍ យ៉ាងណា ភិក្ខុ ក៏ដូច្នោះដែរ ធ្វើទុកក្នុងចិត្តនូវព្រៃនេះឲ្យជាអរញ្ញសញ្ញាដល់ ៧ ដងថា នេះព្រៃ នេះដើមឈើ នេះភ្នំ នេះព្រៃសណ្ឋ: រមែងសម្រេចឧបចារសមាធិ ។ សម្រាប់ បឋវីសញ្ញា ភិក្ខុនោះធ្វើបឋវីកសិណ បរិកម្មឲ្យជាកម្មដ្ឋានប្រចាំ ញ៉ាំងឈាន ឲ្យកើត ចម្រើនវិបស្សនាដែលមានឈានជាបទដ្ឋាន អាចនឹងសម្រេចព្រះអរ-ហត្តបាន ព្រោះដូច្នោះ លោករមែងលះអរញ្ញសញ្ញា ធ្វើទុកក្នុងចិត្តដល់បឋវី-សញ្ញា ។ បទថា **បដិច្ច** ប្រែថា អាស្រ័យគ្នាកើតឡើង ។

ឥឡូវនេះ ដើម្បីនឹងសម្តែងការប្រៀបធៀបបឋវីកសិណ ដែលភិក្ខុមាន សេចក្តីសម្គាល់ថា បឋវីក្នុងបឋវីកសិណ ទើបត្រាស់ពាក្យមានជាដើមថា **សេ-យ្យថាបិ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អសុភស្ស** ឯតំ គឺ គោឧសភ: សេចក្តីថា គោជទៃ កើតឫសខ្វះ មានស្នាមចាក់ខ្វះ ស្បែករបស់គោទាំងនោះ កាលលាតចេញ រមែងមានទោសគួរតិះដៀល ចំណែកទោសទាំងឡាយរមែង មិនកើតដល់គោឧសភ: ព្រោះសម្បូរណ៍ដោយលក្ខណ: ដូច្នោះ ទើបកាន់យក

ស្បែករបស់គោឧសភៈនោះ ។ បទថា **សង្កុសតេន** បានដល់ កោសរូសរយ ដង ។ បទថា **សុវិហតំ** បានដល់ លាចេញហើយ កោសដរាបអស់គ្មានសល់ ។ ពិតហើយ ស្បែកគោដែលគេកោសមិនបានច្រើនដង ក៏មិនទាន់រលីងល្អ តែកាលកោសរូសរយដង ក៏រមែងរលីងល្អដូចផ្ទៃស្គរ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **ឧក្កុលវិកុលំ** ប្រែថា ខ្ពស់ខ្លះ ទាបខ្លះ គឺ ជាទីទួលខ្លះ ជាទីកន្ទក់ខ្លះ ។ បទថា **នទីវិទុគ្គំ** បានដល់ ទន្លេ និងកន្លែងដែលដើរមិនជាសប្បាយ ។ បទថា **បឋវីសញ្ញំ បដិច្ច មនសិករោតិ ឯកត្តំ** សេចក្តីថា ធ្វើទុកក្នុងចិត្តនូវសញ្ញាតែមួយ៉ាង ដែលអាស្រ័យគ្នាកើតឡើងក្នុងបឋវីកសិណ ។ បទថា **ទរថមត្តា** សេចក្តីថា ចាប់ផ្តើមអំពីនេះ គប្បីជ្រាបសេចក្តីខ្វល់ខ្វាយ ដោយសេចក្តីខ្វល់ខ្វាយដែលប្រព្រឹត្តទៅក្នុងភារៈទាំងពួង ។

**[៥៨]** បទថា **អនិមិត្តំ ចេតោ សមាធិំ** បានដល់ សមាធិចិត្តដែលប្រកបដោយវិបស្សនា ។ ចេតោសមាធិដែលវៀរចាកនិមិត្តថា ទៀងជាដើមនោះ លោកពោលថា **អនិមិត្ត** ។

បទថា **ឥមមេវកាយំ** លោកសម្តែងវត្ថុដោយវិបស្សនា ។ ក្នុងបទទាំងនោះ បទថា **ឥមមេវ** បានដល់ មហាភូតរូបទាំង ៤ នេះ ។ បទថា **សឡាយ-**

តនិកំ ប្រែថា បដិសំយុត្តដោយសង្ខាយតនៈ ។ បទថា **ជីវិតប្បច្ចយា** សេចក្តីថា ជីវិតរស់នៅបាន ក៏ជីវិតិន្ទ្រិយនៅប្រព្រឹត្តទៅ អធិប្បាយថា បវរិសញ្ញានោះនៅមានសេចក្តីខ្វល់ខ្វាយដែលប្រព្រឹត្តទៅ ។ ដើម្បីនឹងទ្រង់សម្តែងសេចក្តីឃើញច្បាស់ដោយចំពោះរបស់វិបស្សនា ទើបត្រាស់ថា **អនិមិត្ត** ទៀត ។

**[៩]** បទថា **កាមាសវំ បដិច្ច** ប្រែថា អាស្រ័យកាមាសវៈ ។ អធិប្បាយថា សេចក្តីក្រវល់ក្រវាយដែលនឹងកើតឡើង និងដែលប្រព្រឹត្តទៅហើយមិនមានក្នុងទីនេះ គឺ មិនមានក្នុងអរិយមគ្គ និងអរិយផល ។ បទថា **ឥមមេវ កាយំ** ត្រាស់ដើម្បីសម្តែងសេចក្តីខ្វល់ខ្វាយរបស់បញ្ចក្ខន្ធដ៏សេស ។ ដោយប្រការដូច្នេះ ជាការទ្រង់ផ្លាស់មនុស្សសញ្ញាជាគ្រាមសញ្ញា ។ល។ មគ្គជាវិបស្សនា ហើយទ្រង់សម្តែងសេចក្តីសូន្យទទេកន្លងចំណែកដោយលំដាប់ ។

**[១០]** បទថា **បរិសុទ្ធំ** បានដល់ ប្រាសចាកឧបក្កិលេស ។ បទថា **អនុត្តរំ** ប្រែថា វៀរចាកសភាវៈដទៃដ៏ក្រៃលែងជាង គឺ ប្រសើរបំផុតគ្រប់យ៉ាង ។ បទថា **សុញ្ញតំ** បានដល់ សុញ្ញតាផលសមាបត្តិ ។ បទថា **តស្មា** សេចក្តីថា ព្រោះសមណព្រាហ្មណ៍ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវករបស់ព្រះពុទ្ធក្នុងអតីតក្តី សមណព្រាហ្មណ៍ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង

សាវករបស់ព្រះពុទ្ធក្នុងអនាគតក្តី សមណព្រាហ្មណ៍ គឺ ព្រះពុទ្ធ ព្រះបច្ចេក-ពុទ្ធ និងសាវកនៃព្រះពុទ្ធក្នុងបច្ចុប្បន្នក្តី ចូលសុញ្ញតៈដែលបរិសុទ្ធិក្រៃលែងនេះ បានតាំងនៅហើយ កំពុងតាំងនៅ នឹងបានតាំងនៅហើយ ដូច្នោះ ពាក្យដ៏សេសក្នុងបទទាំងពួងងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ចូឡសុញ្ញតសូត្រ ទី ១

# អ ដ្ឋ ក ថា

## មហាសុញ្ញតសូត្រទី ២

**[១១]** *មហាសុញ្ញតសូត្រ មានបទផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៖*

*បណ្ដាបទទាំងនោះ បទថា* **កាឡខេមកស្ស** *សេចក្ដីថា ស្ដេចសក្យៈនោះមានសម្បុរខ្មៅ ។ ក៏ពាក្យថា* **ខេមកោ** *ជាឈ្មោះរបស់ស្ដេចសក្យៈនោះ ។ បទថា* **វិហារោ** *សំដៅដល់ទីសម្រាករបស់ស្ដេចសក្យៈលោមព័ទ្ធដោយកំផែងក្នុងប្រទេសមួយកន្លែងជិតនិគ្រោធារាមនោះឯង សាងខ្លោងទ្វារ ប្រតិស្ឋានសេនាសនៈ មានរូបហង្សជាដើម និងមានមណ្ឌល រោងឆាន់ជាដើម សាងទុក ។ បទថា* **សម្ពហុលានិ សេនាសនានិ** *បានដល់ គ្រែ តាំង ពូក ខ្នើយ កន្ទេល កំណាត់ ស្បែក សន្ថតដែលធ្វើដោយស្មៅ សន្ថតដែលធ្វើដោយស្លឹកឈើ សន្ថតដែលធ្វើដោយចំបើងជាដើម ដែលគេក្រាលទុក គឺ តម្កល់គ្រែទល់គ្រែ ។ល។ តម្កល់សន្ថតដែលធ្វើដោយចំបើងទល់សន្ថតដែលធ្វើដោយចំបើង ។ ដូចជាទីនៅរបស់ភិក្ខុដែលនៅរួមគ្នាជាគណៈ ។ បទថា* **សម្ពហុលា នុខោ** *សេចក្ដីថា*

ដែលឈ្មោះថា សេចក្ដីសង្ស័យរមែងមិនមានដល់ព្រះមានព្រះភាគ ព្រោះព្រះអង្គទ្រង់ដកកិលេសទាំងពួងបានហើយត្រង់ពោធិបល្ល័ង្កនុ៎ះឯង ។ បុច្ឆាដែលមានវិតក្កៈជាបុព្វភាគក្តី និង នុ អក្សរដែលមានវិតក្កៈជាបុព្វភាគក្តី ជានិបាត កាលដល់វារៈព្រះបាលី មិនត្រូវវិនិច្ឆ័យ ។

បានឮថា បន្ទាប់ពីនេះ ព្រះមានព្រះភាគ មិនធ្លាប់ទតព្រះនេត្រឃើញភិក្ខុទាំងឡាយនៅក្នុងទីជាមួយគ្នាដល់ ១០ រូប ១២ រូប ។ គ្រានោះ ព្រះអង្គមានព្រះតម្រិះថា ដែលឈ្មោះថា ការនៅជាគណៈនេះ បានប្រព្រឹត្តបដិបត្តិរួមគ្នាមកក្នុងវដ្ដៈហើយ ដូចទឹកដែលហូរចុះកាន់ទន្លេ និងការនៅជាគណៈ ក៏បានប្រព្រឹត្តរួមគ្នាមកហើយក្នុងកំណើតនរក កំណើតសត្វតិរច្ឆាន បិត្តិវិស័យ និងអសុរកាយក៏មាន ក្នុងមនុស្សលោក ទេវលោក និងព្រហ្មលោកក៏មាន នរកម៉ឺនយោជន៍សូម្បីពេញទៅដោយសត្វទាំងឡាយ ដូចនាឡិដែលពេញទៅដោយកម្ទេចផង់សំណា ពួកសត្វក្នុងស្ថានទីដែលប្រកបដោយទារុណ ៥ ប្រការ នឹងប្រមាណ ឬកំណត់មិនបាន ពួកសត្វដែលនៅរួមគ្នាជាគណៈ រមែងក្ដៅក្រហាយក្នុងទីដែលត្រូវកាំបិតជាដើម ដូចច្នោះ ។ ក្នុងកំណើតសត្វតិរច្ឆាន ពួកសត្វកណ្ដៀរក្នុងដំបូកមួយកន្លែង រមែងនឹងប្រមាណ ឬកំណត់មិនបាននិងពួកស្រមោច

គ្រហមជាដើម សូម្បីក្នុងសំបុកតែមួយជាដើមក៏ដូចគ្នា សូម្បីក្នុងកំណើតសត្វតិរច្ឆាន ក៏រមែងនៅរួមគ្នាជាគណៈ ។ ក៏នគរប្រេត មានមួយគាវុតក៏មាន កន្លះយោជន៍ក៏មាន ដែលពេញទៅដោយពួកប្រេត សូម្បីក្នុងពួកប្រេត ក៏នៅរួមគ្នាជាគណៈយ៉ាងនេះឯង ។ កពអសូរ មានប្រមាណម៉ឺនយោជន៍ដូចរន្ធត្រចៀកដែលគេយកម្ជុលស៊កទុកត្រង់ត្រចៀក សូម្បីក្នុងអសុរកាយ ក៏រមែងនៅរួមគ្នាជាគណៈយ៉ាងនេះ ។ ក្នុងមនុស្សលោក ចំពោះក្រុងសាវត្ថី មានដល់ ៥ លាន ៧ សែនត្រកូល ។ ក្នុងក្រុងរាជគ្រឹះ ទាំងខាងក្នុងខាងក្រៅមានមនុស្សអាស្រ័យនៅ ១៨ កោដិ ក្នុងឋានៈសូម្បីដទៃៗ គឺ សូម្បីក្នុងមនុស្សលោក ក៏នៅរួមគ្នាជាគណៈដូចគ្នា ។ សូម្បីក្នុងទេវលោក និងព្រហ្មលោក ចាប់តាំងពីភូម្មទេវតាទៅ ក៏នៅរួមគ្នាជាគណៈ ។ ក៏ទេវបុត្រតែមួយអង្គ រមែងមានទេពអប្សរអ្នកបម្រើដល់ពីរកោដិកន្លះ អង្គខ្លះមានដល់ ៩ កោដិ សូម្បីព្រហ្មចំនួនរាប់ម៉ឺនក៏នៅរួមក្នុងទីតែមួយជាមួយគ្នា ។ តពីនោះ ទ្រង់ត្រិះរិះថា តថាគតបំពេញបារមី ១០ អស់ ៤ អសង្ខេយ្យមួយសែនកប្ប ក៏ដើម្បីកម្ចាត់ការនៅរួមគ្នាជាគណៈ តែភិក្ខុទាំងនេះ ផ្តើមតាំងពីនេះទៅ ភិក្ខុទាំងនេះ រមែងកុះករត្រេកអរក្នុងពួក ធ្វើកម្មមិនសមគួរឡើយ ។ ព្រះអង្គទ្រង់កើតធម្មសង្វេគ ព្រោះភិក្ខុទាំងឡាយជាហេតុ

ទ្រង់ត្រិះរិះថា បើតថាគតនឹងបញ្ញត្តិសិក្ខាបទថា ភិក្ខុពីររូបមិនគប្បីនៅក្នុងទីតែមួយជាមួយគ្នា តែមិនអាចនឹងបញ្ញត្តិបាន ណ្ហើយចុះ តថាគតនឹងសម្ដែងព្រះសូត្រឈ្មោះ **មហាសុញ្ញតាបដិបត្តិ** ដែលដូចជាការបញ្ញត្តិសិក្ខាបទសម្រាប់កុលបុត្រអ្នកប្រាថ្នាចំពោះការសិក្សា និងដូចជាកញ្ចក់សម្រាប់ឆ្លុះពួកសត្វគ្រប់ប្រភេទ ដែលគេដាក់ទុកត្រង់ទ្វារក្រុង អំពីនោះក្សត្រិយ៍ជាដើម ឃើញទោសរបស់ខ្លួនក្នុងកញ្ចក់ នឹងលះបង់ទោសនោះ រមែងជាអ្នករកទោសមិនបាន យ៉ាងណា សូម្បីកាលតថាគតបរិនិព្វានកន្លងទៅហើយដល់ ៥,០០០ ឆ្នាំ កុលបុត្រទាំងឡាយរមែងរឭកដល់ព្រះសូត្រនេះ នឹងបន្ទោបង់សភាពជាពួក ត្រេកអរក្នុងឯកីភាព នឹងធ្វើទីបំផុតនៃវដ្ដទុក្ខបាន ។ កុលបុត្រទាំងឡាយរឭកដល់ព្រះសូត្រនេះហើយ បន្ទោបង់ការនៅជាពួក ញុំាងទុក្ខក្នុងវដ្ដៈឲ្យអស់ទៅ ហើយបរិនិព្វានរាប់មិនបាន ដូចញុំាងមនោរថរបស់ព្រះមានព្រះភាគឲ្យបរិបូណ៌ ។ ក៏សូម្បីក្នុងវាលិកបិដ្ឋិវិហារ ព្រះអភ័យត្ថេរអ្នកជំនាញព្រះអភិធម្ម ស្វាធ្យាយព្រះសូត្រនេះរួមជាមួយភិក្ខុទាំងឡាយជាច្រើន ក្នុងវស្សូបនាយិកសម័យ ពោលថា ព្រះសម្មាសម្ពុទ្ធទ្រង់អនុគ្រោះឲ្យធ្វើយ៉ាងនេះ ពួកយើងនឹងធ្វើយ៉ាងណា ។ ភិក្ខុទាំងអស់នោះ បន្ទោបង់ការនៅរួមគ្នាជាគណៈ ត្រេកអរក្នុងឯកីភាព ហើយក៏បានសម្រេច

ព្រះអរហត្តខាងក្នុងវស្សា ។ ព្រះសូត្រនេះឈ្មោះថា **ទម្លាយការនៅរួមគ្នាជាគណៈ** ដោយប្រការដូច្នេះ ។

**[១២]** បទថា **យេនាយ** បានដល់ ស្តេចសក្យៈអ្នកមានឈ្មោះយ៉ាងនោះ ។ បទថា **វិហារេ** សេចក្តីថា សូម្បីក្នុងវត្តនេះ គប្បីជ្រាបថា សាងទុកក្នុងទីជិតកន្លែងមួយរបស់និគ្រោធារាមនុ៎ះឯង ដូចវត្តរបស់ស្តេចសក្យៈឈ្មោះ កាឡខេមកៈ ។ បទថា **ចីវរកម្មំ** សេចក្តីថា ការចាត់ចែងយកសំពត់ចាស់សៅហ្មងមាតាបទៈ និងឆាក (ទាំ) ជាដើមក្តី សំពត់ដែលកើតឡើងដើម្បីធ្វើចីវរ ដែលមិនទាន់បានធ្វើ និងមិនទាន់ដេរ មកចាត់ចែងក្តីក៏គួរ ។ តែក្នុងទីនេះបំណងយកចំណែកដែលនៅមិនបានចាត់ចែងធ្វើ ។ ក៏មនុស្សទាំងឡាយ បានថ្វាយសំពត់ចីវរដល់ព្រះអានន្ទត្ថេរ ។ ព្រោះដូច្នោះ ព្រះថេរៈទើបបបួលភិក្ខុជាច្រើន ទៅធ្វើចីវរកម្មក្នុងវត្តនោះ ។ សូម្បីភិក្ខុទាំងនោះ អង្គុយតាំងពីផ្តើមដោតម្ជុលដេរពីព្រឹកព្រលឹម ក្រោកឡើងក្នុងវេលាមិនប្រាកដ ។ កាលដេរសម្រេចហើយ ភិក្ខុទាំងនោះគិតថា នឹងចាត់សេនាសនៈតែមិនទាន់បានចាត់ចែង ។ បទថា **ចីវរកាលសមយោ នោ** សេចក្តីថា បានឮថា ព្រះថេរៈគិតថា ព្រះមានព្រះភាគទ្រង់នឹងឃើញសេនាសនៈទាំងឡាយ ដែលភិក្ខុទាំងនេះ មិនទាន់បានរៀបចំទុកដាក់

ដោយប្រការដូច្នេះ ព្រះសាស្តាទ្រង់មិនពេញព្រះទ័យ ប្រាថ្នានឹងសង្កត់សង្កិន យើងនឹងជួយកិច្ចការដែលនៅសល់របស់ភិក្ខុទាំងនេះ ព្រោះដូច្នោះ ព្រះថេរៈទើបពោលយ៉ាងនេះ ។ ក៏ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះ ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងនេះមិនមែនបំណងចំពោះការងារតែមួយប៉ុណ្ណោះទេ តែនៅយ៉ាងនេះដោយអំណាចនៃចីវរកិច្ច ។

**[១៣]** បទថា **ន ខោ អានន្ទ** សេចក្តីថា ម្នាលអានន្ទ កម្មសម័យក្តី អកម្មសម័យក្តី ចីវរកាលសម័យក្តី ចូរលើកទុកចុះ ភិក្ខុដែលត្រេកអរដោយការប្រចបូកប្រចបល់ រមែងមិនល្អឡើយ អ្នកកុំបានជួយកិច្ចការដែលនៅសល់ក្នុងឋានៈដែលមិនគួរជួយឡើយ ។

បណ្តាបទទាំងនោះ បទថា **សង្គណិកា** ជាបទរួមបរិស័ទរបស់ខ្លួន ។ បទថា **គណោ** ជាបទរួមបុគ្គលផ្សេងៗ ដោយប្រការដូច្នេះ ភិក្ខុនឹងត្រេកអរដោយការប្រចបូកប្រចបល់ក៏ដោយ ត្រេកអរក្នុងគណៈក៏ដោយ ត្រេកអរក្នុងការមានពួកច្រើនសូម្បីទាំងពីរ ដែលជាប់ទាក់ទងដោយពួក រមែងមិនល្អដោយប្រការទាំងពួង ។ តែភិក្ខុបោសសំអាតទីសម្រាកពេលថ្ងៃ ក្នុងវេលាក្រោយភត្តហើយលាងដៃជើងឲ្យស្អាត ទទួលមូលកម្មដ្ឋាន ប្រកបរឿយៗ ដល់ភាពជាអ្នកមាន

អារម្មណ៍ជាមួយ រមែងស្រស់ល្អក្នុងព្រះពុទ្ធសាសនា ។

បទថា **នេក្ខម្មសុខំ** សេចក្ដីថា សុខរបស់ភិក្ខុដែលចេញចាកកាមសម្បជាសុខដែលកើតពីសេចក្ដីស្ងប់ ក៏ចាត់ជាសុខកើតពីសេចក្ដីស្ងប់ចាកកាម ។ ដែលឈ្មោះថា **ឧបសមសុខ** ព្រោះអត្ថថា ប្រព្រឹត្តទៅដើម្បីស្ងប់កិលេស មានរាគៈជាដើម ។ ឈ្មោះថា **សម្ពោធិសុខ** ព្រោះអត្ថថា ប្រព្រឹត្តទៅដើម្បីដឹងនូវមគ្គ ។ បទថា **និកាមលាភី** ប្រែថា បានតាមត្រូវការ គឺ បានតាមប្រាថ្នា ។ បទថា **អកិច្ឆលាភី** ប្រែថា បានដោយមិនលំបាក ។

បទថា **អកសិរលាភី** ប្រែថា បានដោយងាយ ។ បទថា **សាមាយិកំ** បានដល់ រួចផុតកិលេសជាគ្រាៗ ។ បទថា **កន្តំ** ប្រែថា ជាទីពេញចិត្ត ។ បទថា **ចេតោវិមុត្តឹ** បានដល់ ចេតោវិមុត្តិដែលជារូបាវចរ និងអរូបាវចរ ។ សមពិតដូចដែលត្រាស់ទុកថា ឈាន ៤ និងអរូបសមាបត្តិ ៤ នេះ ចាត់ជាវិមោក្ខ ។ បទថា **អសាមាយិកំ** សេចក្ដីថា រួចផុតពីកិលេសមិនជាប់ដោយសម័យ ។ **អបច្ចន្តវិមុត្តិ** ចាត់ជាលោកុត្តរៈពិត ។ សមដូចដែលត្រាស់ទុកថា អរិយមគ្គ ៤ សាមញ្ញផល ៤ នេះ ចាត់ជាវិមោក្ខដែលប្រព្រឹត្តទៅមិនជាសម័យ ។

បទថា **អកុប្បំ** ប្រែថា មិនញុំាងកិលេសឲ្យកម្រើក ។ តាមដែល

អធិប្បាយមកនេះ លោកពោលសំដៅដល់អ្វី ។ ភិក្ខុដែលចូលចិត្តនៅប្របូកប្របល់គ្នា និងរួមគ្នាជាគណៈ រមែងមិនអាចនឹងញុំាងលោកិយគុណ និងលោកុត្តរគុណ ឲ្យកើតឡើងបាន ។ តែបើលះការនៅជាគណៈ ត្រេកអរក្នុងឯកីភាព ក៏នឹងអាចញុំាងលោកិយគុណ និងលោកុត្តរគុណឲ្យកើតបាន ។ ពិតដូច្នោះ សូម្បីព្រះវិបស្សីពោធិសត្វ ហែហមទៅដោយបព្វជិត ៨៤,០០០ រូប ត្រាច់ទៅ ៧ ឆ្នាំ ក៏មិនអាចនឹងញុំាងសព្វញ្ញុតញ្ញាណឲ្យកើតបាន ។ លុះលះបង់ការនៅជាគណៈហើយ ត្រេកអរក្នុងឯកីភាព ឡើងកាន់ពោធិមណ្ឌល ៧ ថ្ងៃ ក៏ញុំាងគុណនៃសព្វញ្ញុឲ្យកើត ។ ព្រះពោធិសត្វរបស់យើងទាំងឡាយ ត្រាច់ទៅរហូតអស់ ៦ ឆ្នាំ ជាមួយភិក្ខុបញ្ចវគ្គិយ ក៏មិនអាចនឹងញុំាងគុណនៃព្រះសព្វញ្ញុឲ្យកើតឡើងបាន ។ កាលបញ្ចវគ្គិយចៀសទៅហើយ ទ្រង់ត្រេកអរក្នុងឯកីភាព ស្តេចឡើងកាន់ពោធិមណ្ឌល ក៏ញុំាងគុណនៃព្រះសព្វញ្ញុឲ្យកើតបាន ។

ព្រះមានព្រះភាគត្រាទ្រង់សម្តែងថា អ្នកដែលចូលចិត្តនៅប្របូកប្របល់ មិនមានផ្លូវដែលនឹងសម្រេចគុណវិសេសបានយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់នឹងសម្តែងការកើតទោស ទើបត្រាស់ថា **នាហំ** អានន្ទជាដើម ។ ក្នុងបទទាំងនោះ បទថា **រូបំ** បានដល់ សរីរៈ ។ បទថា **យត្ថ រត្តស្ស** បានដល់ ត្រេកអរ

ដោយតម្រេកក្នុងរូបណា ។ បទថា **ន ឧប្បជ្ជេយ្យ** សេចក្តីថា មិនកើតតម្រេក ក្នុងរូបណា តថាគតមិនពិចារណាឃើញនូវរូបនោះ ។ ការពិត រមែងកើតឡើង បាន ដូចកើតដល់បរិព្វាជកឈ្មោះថា សញ្ជ័យ ដោយសេចក្តីជាយ៉ាងដទៃ កាល ព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានចូលទៅជាសាវករបស់ព្រះទសពល ដូច កើតដល់និគ្រន្ថនាដបុត្រ គ្រាឧបាលីគហបតីផ្លាស់ប្តូរចិត្ត និងដូចកើតដល់សេដ្ឋី ជាដើម ក្នុងបិយជាតិកសូត្រ ។

**[១៤]** បទថា **អយំ ខោ បន អានន្ទ** ជាបទអនុសន្ធិមួយ ។ បើភិក្ខុ ដែលបួសថ្មី ជាអ្នកមានការចេះដឹងតិច នឹងគប្បីពោលថា ព្រះសម្មាសម្ពុទ្ធ តែនាំពួកយើងចេញចាកពួក ប្រកបទុកក្នុងភាពត្រម៉ង់ត្រមោច ដូចអ្នកស្រែ នាំ គោដែលចូលទៅកាន់ស្រែ ចេញអំពីស្រែ ចំណែកព្រះអង្គឯងហែហមទៅដោយ ព្រះរាជា និងរាជបរិវារជាដើម ព្រោះដូច្នោះ ព្រះតថាគតសូម្បីនឹងប្រថាប់គង់ កណ្តាលបរិស័ទ មានចក្រវាឡជាទីបំផុត ក៏ទ្រង់ផ្តើមទេសនានេះ ដើម្បីទ្រង់ នឹងសម្តែងថា ជាអ្នកនៅឯកកោ ដើម្បីនឹងមិនឲ្យឱកាសភិក្ខុរូបខ្លះនោះ សម្តែង ធ្វើឲ្យទាស់ចិត្តបាន ។ បណ្តាបទទាំងនោះ បទថា **សព្វនិមិត្តានំ** បានដល់ និមិត្តដែលតាក់តែងហើយ មានរូបជាដើម ។ បទថា **អជ្ឈត្តំ** សេចក្តីថា ក្នុង

ខាងក្នុងខ្លួន ។ បទថា **សុញ្ញតំ** បានដល់ សុញ្ញតាផលសមាបត្តិ ។ បទថា **តត្ថ ចេ** ជាសត្តមីវិភត្តិចុះក្នុងអត្ថទុតិយាវិភត្តិ ។ អធិប្បាយថា ដូចគ្នានឹង **តំ ចេ** ។ បទថា **បុន តត្រ** សេចក្ដីថា ព្រះតថាគតប្រថាប់នៅកណ្ដាលបរិស័ទនោះ ។ បទថា **វិវេកនិន្នេន** បានដល់ បង្អោនទៅក្នុងព្រះនិព្វាន ។ បទថា **ព្យន្តីភូតេន** សេចក្ដីថា ប្រាសចាក គឺ រលាស់ចេញ បានដល់ ប្រាសចាកធម៌ជាទីតាំងនៃអាសវៈ ។

បទថា **ឧយ្យោជនិកបដិសំយុត្តំ** សេចក្ដីថា ប្រកបដោយវាចាដែលបបួលយ៉ាងនេះថា អ្នកទាំងឡាយចូរទៅចុះ ។ សួរថា ក៏ព្រះមានព្រះភាគត្រាស់យ៉ាងនេះ វេលាណា ។

ឆ្លើយថា ត្រាស់ក្នុងវេលាក្រោយភត្តកិច្ចខ្លះ ក្នុងវេលាបំពេញពុទ្ធកិច្ចក្នុងយាមខាងដើមខ្លះ ។

ព្រះមានព្រះភាគសម្រេចសីហសេយ្យាសនៈក្នុងព្រះគន្ធកុដិ ខាងក្រោយភត្តាហារ ចេញចាកសីហសេយ្យាសនៈហើយ ប្រថាប់គង់ចូលផលសមាបត្តិ ។ ក្នុងសម័យនោះ បរិស័ទទាំងឡាយ រមែងប្រជុំគ្នាដើម្បីស្ដាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបវេលាហើយ ស្ដេចចេញចាកព្រះគន្ធកុដិ ត្រង់ទៅកាន់

ពុទ្ធអាសនៈដ៏ប្រសើរ ទ្រង់សម្ដែងធម៌មិនឲ្យវេលាកន្លងទៅ ដូចបុរសអ្នកកាន់យកប្រេងដែលស្ងួតទុកសម្រាប់ប្រកបថ្នាំ ទ្រង់បញ្ជូនបរិស័ទទៅដោយចិត្តដែលបង្អោនទៅក្នុងវិវេក ។ កាលបុរិមយាមកន្លងទៅ ទ្រង់បញ្ជូនបរិស័ទត្រឡប់ដោយព្រះតម្រាស់យ៉ាងនេះថា ម្នាលវាសេដ្ឋៈ រាត្រីកន្លងទៅហើយដែរ ឥឡូវនេះពួកអ្នកចូរសម្គាល់កាលដែលសមគួរចុះ ។ រាប់ចាប់ផ្ដើមតាំងពីព្រះពុទ្ធទាំងឡាយសម្រេចព្រះពោធិញ្ញាណហើយ សូម្បីវិញ្ញាណទាំង ១០ របស់ព្រះអង្គ ក៏បង្អោនទៅដើម្បីព្រះនិព្វានតែម្យ៉ាង ។

បទថា **តស្មាតិហានន្ទ** សេចក្ដីថា ព្រោះសុញ្ញតាវិហារ ស្ងប់ប្រណីតដូច្នោះ ។ បទថា **អជ្ឈត្តមេវ** បានដល់ ខាងក្នុងគោចរនុ៎ះឯង ។ ខាងក្នុងរបស់ខ្លួន ក្នុងបទនេះថា **អជ្ឈត្តំ សុញ្ញតំ** អធិប្បាយថា អាស្រ័យបញ្ចក្ខន្ធរបស់ខ្លួន ។

**[១៥]** បទថា **សម្បជានោ ហោតិ** សេចក្ដីថា ជាអ្នកដឹងច្បាស់ ដោយការដឹងថា កម្មដ្ឋានមិនទាន់សម្បូរណ៍ ។ បទថា **ពហិទ្ធា** បានដល់ ក្នុងបញ្ចក្ខន្ធរបស់អ្នកដទៃ ។ បទថា **អជ្ឈត្តពហិទ្ធា** សេចក្ដីថា គ្រាខ្លះខាងក្នុង គ្រាខ្លះខាងក្រៅ ។ បទថា **អនេញ្ជំ** សេចក្ដីថា ធ្វើទុកក្នុងចិត្តនូវអនេញ្ជសមាបត្តិ គឺ អរូបសមាបត្តិថា យើងនឹងជាឧភតោភាគវិមុត្តិ ។

បទថា **តស្មឹយេវ បុរិមស្មឹ** លោកពោលសំដៅដល់ឈានដែលជាបាទ ។ ក៏កាលភិក្ខុនោះចេញចាកឈានដែលជាបាទ ដែលនៅមិនទាន់ស្ទាត់ជំនាញ ដាក់ចិត្តដល់សុញ្ញតាក្នុងខាងក្នុង ចិត្តរមែងមិនត្រាច់ទៅក្នុងសុញ្ញតាសមាបត្តិនោះ ។ តពីនោះ ដាក់ចិត្តទៅខាងក្រៅថា ក្នុងសន្តានរបស់អ្នកដទៃជាយ៉ាងណាហ្ន៎ ។ តអំពីនោះ ចិត្តរមែងមិនត្រាច់ទៅក្នុងសុញ្ញតាសមាបត្តិនោះ ។ អំពីនោះដាក់ចិត្តទាំងខាងក្នុង និងខាងក្រៅថា ក្នុងសន្តានរបស់ខ្លួនក្នុងកាលខ្លះ យ៉ាងណា ។ ក្នុងសន្តានរបស់អ្នកដទៃក្នុងកាលខ្លះ យ៉ាងណា ។ ចិត្តរមែងមិនត្រាច់ទៅ សូម្បីក្នុងសុញ្ញតាសមាបត្តិនោះ ។ តពីនោះ អ្នកប្រាថ្នានឹងជាឧភតោភាគវិមុត្តិ ដាក់ចិត្តដល់អនេញ្ជាសមាបត្តិថា ក្នុងអរូបសមាបត្តិយ៉ាងណាហ្ន៎ ។ ចិត្តរមែងមិនត្រាច់ទៅសូម្បីក្នុងអនេញ្ជាសមាបត្តិនោះ ។ ភិក្ខុដែលលះបង់សេចក្តីព្យាយាមមិនគប្បីប្រព្រឹត្តតាមក្រោយឧបដ្ឋាកជាដើម ដោយគិតថា ឥឡូវនេះ ចិត្តរបស់យើងមិនទាន់ត្រាច់ទៅ តែគប្បីដាក់ចិត្តដល់ឈានដែលជាបាទឲ្យស្មើដោយល្អតែម្យ៉ាង ។ ដើម្បីនឹងទ្រង់សម្តែងថា ការដាក់ចិត្តដល់កម្មដ្ឋាន ចិត្តរមែងត្រាច់ទៅយ៉ាងសប្បាយ ដូចបុរសកាត់ឈើ កាលពូថៅមិនមុត ត្រូវសំលៀងពូថៅសិនហើយទើបកាត់ ពូថៅទើបមុត ដោយប្រការដូច្នេះ ទើបត្រាស់ពាក្យមានជាដើម

ថា **តស្មិញ្ញេវ** ដូច្នេះ ។

ឥឡូវនេះ កាលនឹងទ្រង់សម្តែងថា កាលភិក្ខុនោះបដិបត្តិយ៉ាងនេះ ការដាក់ចិត្តក្នុងសមាបត្តិនោះៗ រមែងដល់ព្រម ទើបត្រាស់ថា **បក្ខន្ទតិ** ។ បទថា **ឥមិនា វិហារេន** បានដល់ នៅដោយវិហារធម៌ គឺ សមថៈ និងវិបស្សនា ។ បទថា **ឥតិហ តត្ថ សម្បជានោ** សេចក្តីថា សូម្បីកាលកំពុងដើរចង្រ្កម ក៏ដឹងច្បាស់ថា កាលកម្មដ្ឋាននោះដល់ព្រម កម្មដ្ឋានរបស់យើងក៏ដល់ព្រម ។ បទថា **សយតិ** ប្រែថា រមែងដេក ។ ក្នុងសេចក្តីនេះ សេចក្តីថា ភិក្ខុដើរចង្រ្កមក្នុងវេលាណាៗ ក៏ដឹងថា ឥឡូវនេះយើងអាចដើរចង្រ្កមបានរហូតដល់អស់វេលា មានប្រមាណប៉ុណ្ណោះ យើងមិនឈប់សម្រាកឥរិយាបថណាឡើយ ហើយតាំងនៅ ។ ក្នុងវារៈទាំងពួងក៏ន័យនេះ ។ បទថា **ឥតិហ តត្ថ** សេចក្តីថា រមែងដឹងច្បាស់ក្នុងឥរិយាបថនោះៗ ដោយដឹងថា យើងនឹងមិនពោលយ៉ាងនេះ ។ សូម្បីក្នុងទុតិយវារៈ ភិក្ខុក៏ដឹងច្បាស់ ដោយដឹងថា យើងនឹងពោលពាក្យបែបនេះ ។ ក៏ភិក្ខុនេះ នៅមានសមថវិបស្សនាទន់ខ្ចីដោយពិត ។ ដើម្បីនឹងតាមរក្សាសមថ-វិបស្សនាទាំងនោះ គប្បីប្រាថ្នាសប្បាយ ៧ យ៉ាង គឺ អាវាស ១ គោចរ ១ ការសន្ទនា ១ បុគ្គល ១ ភោជន ១ រដូវ ១ ឥរិយាបថ ១ ដើម្បីនឹងសម្តែង

សប្បាយទាំង ៧ នោះ ទើបត្រាស់យ៉ាងនេះ ។ ក្នុងវិតក្កវារៈទាំងឡាយ គប្បីជ្រាបសេចក្តីដឹងច្បាស់ដោយការដឹងនូវអវិតក្កៈ និងវិតក្កៈ ។

**[១៧]** ព្រះមានព្រះភាគត្រាស់ មគ្គទាំងពីរដោយការលះវិតក្កៈដូចពោលមកនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់ប្រាប់ការឃើញច្បាស់ដោយតតិយមគ្គ ទើបត្រាស់ពាក្យមានជាដើមថា **បញ្ច ខោ ឥមេ អានន្ទ** កាមគុណា ដូច្នេះ ។ បទថា **អាយតនេ** សេចក្តីថា ក្នុងហេតុដែលនាំឲ្យកើតកិលេសណាមួយ ក្នុងកាមគុណទាំងនោះ ។ បទថា **សមុទាចារោ** បានដល់ កិលេសដែលនៅលះមិនបាន ព្រោះញាំងការវេវវាយ ។ បទថា **ឯវំ សន្តំ** សេចក្តីថា មានយ៉ាងនេះឯង ។ បទថា **សម្បជានោ** បានដល់ ដឹងច្បាស់ ដោយដឹងថា កម្មដ្ឋានមិនទាន់សម្បូរណ៍ក្នុងទុតិយវារៈ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ឯវំ សន្តំ** ប្រែថា មានយ៉ាងនេះ ។

បទថា **ឯវំ សម្បជានោ** បានដល់ ដឹងច្បាស់ ដោយដឹងថា កម្មដ្ឋានសម្បូរណ៍ ។

ក៏កាលភិក្ខុនេះពិចារណាថា ឆន្ទរាគៈក្នុងកាមគុណទាំង ៥ យើងលះបានហើយ ឬមិនទាន់បានលះហ្ន៎ ដូច្នេះ ដឹងច្បាស់ថា នៅមិនទាន់បានលះ ត្រូវ

ផ្លូវសេចក្តីព្យាយាម ទើបដកដកធនុរាគៈនោះបានដោយអនាគាមិមគ្គ ។ អំពីនោះ ពិចារណាផលសមាបត្តិក្នុងលំដាប់នៃមគ្គ ចេញចាកផលសមាបត្តិហើយពិចារណាទើបដឹងថា លះបានហើយ ។ អធិប្បាយថា រមែងដឹងច្បាស់ ដោយដឹងថា លះធនុរាគៈនោះបានហើយ ។

[១៨] ឥឡូវនេះ កាលនឹងត្រាស់ប្រាប់ការឃើញច្បាស់នូវអរហត្តមគ្គ ទើបត្រាស់ពាក្យមានជាដើមថា **បញ្ច ខោ ឥមេ អានន្ទ ឧបាទានក្ខន្ធា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សោ បហីយតិ** សេចក្តីថា លះមានះថា យើងមានក្នុងរូប លះឆន្ទៈថា យើងមានក្នុងរូប លះអនុស័យថា យើងមានក្នុងរូប ។ សេចក្តីដឹងច្បាស់ក្នុងវេទនាជាដើម គប្បីជ្រាបដោយន័យដូចពោលហើយយ៉ាងនោះឯង ។ ព្រះមានព្រះភាគ ត្រាស់ថា **ឥមេ ខោ តេ អានន្ទធម្មា** ដូច្នេះ ទ្រង់សំដៅដល់ធម៌ គឺ សមថវិបស្សនា មគ្គ និងផលដែលត្រាស់ហើយក្នុងខាងក្រោយ ។ បទថា **កុសលាយត្តិកា** ប្រែថា ជាប់តាមកុសល ។ សេចក្តីពិតកុសលធម៌ទាំងឡាយ ជាកុសល ជាធម៌ដែលជាប់មកតាមកុសល អាកិញ្ចញ្ញាយតនឈានជាកុសល នេវសញ្ញានាសញ្ញាយតនជ្ឈាន ទាំងកុសល ទាំងធម៌ដែលជាប់មកតាមកុសល នេវសញ្ញានាសញ្ញាយតនជ្ឈានជាកុសល សោតាបត្តិ-

មគ្គជាកុសល ជាធម៌ដែលជាប់មកតាមកុសល ។បេ។ អនាគាមិមគ្គជាកុសល អរហត្តមគ្គជាកុសល ទាំងជាធម៌ដែលជាប់មកតាមកុសល បឋមជ្ឈាន ក៏ចាត់ជាកុសលដូចគ្នា ធម៌ដែលសម្បយុត្តដោយបឋមជ្ឈាននោះ ជាកុសល ទាំងជាធម៌ដែលជាប់មកតាមកុសល ។បេ។ អរហត្តមគ្គជាកុសល ធម៌ដែលសម្បយុត្តដោយអរហត្តមគ្គនោះ ជាកុសល ជាធម៌ដែលជាប់មកតាមកុសល ។ បទថា **អរិយា** ប្រែថា មិនមានកិលេស គឺ បរិសុទ្ធិ ។ បទថា **លោកុត្តរា** ប្រែថា ខ្ពង់ចាកលោក គឺ បរិសុទ្ធិក្នុងលោក ។ បទថា **អនវក្កន្តា បាបិមតា** ប្រែថា ដែលមារមានចិត្តបាបធ្លាក់ចុះមិនបាន ។ ក៏មារ រមែងមិនឃើញចិត្តរបស់ភិក្ខុអ្នកអង្គុយចូលសមាបត្តិ ៨ មានវិបស្សនាជាបាទ គឺ មិនអាចនឹងដឹងថា ចិត្តរបស់ភិក្ខុនោះអាស្រ័យអារម្មណ៍ឈ្មោះនេះប្រព្រឹត្តទៅ ព្រោះដូច្នោះ ទើបត្រាស់ថា **អនវក្កន្តា** ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់បទនេះថា **តំ កឹ មញ្ញសិ** ។ សេចក្តីពិត ក្នុងគណៈក៏មានអានិសង្សម្យ៉ាង ដើម្បីនឹងទ្រង់សម្តែងអានិសង្សនោះ ទើបត្រាស់ពាក្យនេះ ។ បទថា **អនុពន្ធិតុំ** ប្រែថា ជាប់ទៅ គឺ លោមព័ទ្ធ ។ ក្នុងបទថា **ន ខោ អានន្ទ** នេះ មានវិនិច្ឆ័យថា ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវកអ្នកបានស្តាប់ហើយ តែព្រះមានព្រះភាគ រមែងលះបង់

អកុសល ចម្រើនកុសល លះបង់ធម៌ដែលមានទោស ចម្រើនធម៌ដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធិ ដូច្នេះជាដើម ធ្វើខ្លួនឲ្យជាពហុស្សូត ដូចទាហានដែលព្រមដោយអាវុធ ៥ យ៉ាង ។ ក៏ព្រោះភិក្ខុសូម្បីនឹងរៀនសុត្តបរិយត្តិ តែមិនបដិបត្តិអនុលោមបដិបទាសមគួរដល់សុត្តបរិយត្តិនោះ លោករមែងឈ្មោះថា មិនមានអាវុធនោះ ចំណែកភិក្ខុណាបដិបត្តិ ភិក្ខុនោះឯង ទើបឈ្មោះថា មានអាវុធ ។ ដូច្នោះ កាលនឹងសម្តែងសេចក្តីនេះថា មិនគួរនឹងជាប់តាម ទើបត្រាស់ថា **ន ខោ អានន្ទ** ដូច្នេះ ។

**[១៩]** ឥឡូវនេះ ដើម្បីទ្រង់សម្តែងរឿងដែលគួរជាប់តាម ទើបត្រាស់ពាក្យមានជាដើមថា **យា ច ខោ** ដូច្នេះជាដើម ។ កថាវត្ថុ ១០ ក្នុងឋានៈទាំង ៣ មកក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ ។ មកដោយអំណាចនៃធម៌ដែលជាសប្បាយ និងធម៌ដែលជាអសប្បាយៈ ដូចក្នុងប្រយោគថា តថាគតទើបពោលកថាបែបនេះ ដោយប្រការដូច្នេះ ។ មកដោយអំណាចនៃសុត្តបរិយត្តិ ដូចក្នុងប្រយោគ ថា **យទិទំ សុត្តំ គេយ្យំ** តែក្នុងទីនេះ មកហើយដោយបរិបូណ៌ ។ ព្រោះដូច្នោះ កាលនឹងត្រាស់កថាវត្ថុ ១០ ក្នុងព្រះសូត្រនេះ ទើបត្រាស់រួមទុកក្នុងឋានៈនេះ ។

ឥឡូវនេះ ព្រោះហេតុដែលភិក្ខុពួកខ្លះសូម្បីនៅតែម្នាក់ឯង ក៏រមែងមិនកើតប្រយោជន៍ ដូច្នោះ ដើម្បីទ្រង់សម្តែងទោសក្នុងការនៅម្នាក់ឯង ។ ទ្រង់សំដៅដល់ភិក្ខុពួកខ្លះនោះ ទើបត្រាស់ពាក្យជាដើមថា **ឯវំ សន្តេ ខោ អានន្ទ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ឯវំ សន្តេ** សេចក្តីថា កាលនៅម្នាក់ឯងយ៉ាងនោះមាន ។

**[២០]** បទថា **សត្ថា** សំដៅយកសាស្តាក្រៅសាសនា ។ បទថា **អន្វាវត្តន្តិ** ប្រែថា បណ្តោយតាម គឺ ចូលទៅរក ។ បទថា **មុច្ឆំ និកាមយតិ** ប្រែថា ប្រាថ្នាការរួចផុត អធិប្បាយថា ឲ្យប្រព្រឹត្តទៅ ។ បទថា **អាចរិយូបទ្ទវេន** សេចក្តីថា ឈ្មោះថា ឧបទ្រវៈរបស់អាចារ្យ ព្រោះមានអន្តរាយ គឺ កិលេសកើតឡើងក្នុងខាងក្នុងរបស់ខ្លួន ។ សូម្បីក្នុងឧបទ្រវៈដ៏សេស ក៏មានន័យនេះដូចគ្នា ។

**[២១]** បទថា **អវធីសុ នំ** ប្រែថា សម្លាប់សាស្តានោះចេញហើយ ។ ក៏លោកពោលដល់សេចក្តីស្លាប់នូវសេចក្តីល្អ ដោយបទថា **អវធីសុ នំ** នេះ ។

**[២២]** បទថា **វិនិបាតាយ** ប្រែថា ឲ្យធ្លាក់ចុះទៅតែម្យ៉ាង ។ ក៏ព្រោះហេតុអ្វី លោកទើបពោលឧបទ្រវៈរបស់អ្នកប្រព្រឹត្តព្រហ្មចរិយៈថា មានវិបាក

ជាទុក្ខច្រើនជាង មានផលក្តៅផ្សាច្រើនជាង និងប្រព្រឹត្តទៅដើម្បីសេចក្តីធ្លាក់ចុះ ។ ពិតហើយ ការបួសខាងក្រៅព្រះសាសនា មានលាភតិច និងក្នុងការបួសក្រៅសាសនានោះ មិនមានផ្លូវនឹងឲ្យកើតគុណធំទូលាយទៅបានឡើយ និងមាន ក៏ត្រឹមតែសមាបត្តិ ៨ អភិញ្ញា ៥ ប៉ុណ្ណោះ ។ ប្រៀបដូចអ្នកដែលរបូតធ្លាក់អំពីខ្នងលា រមែងមិនមានទុក្ខច្រើន និងមានខ្លួនត្រឹមតែប្រលាក់ធូលីប៉ុណ្ណោះ យ៉ាងណា ក្នុងលទ្ធិក្រៅសាសនាក៏ដូច្នោះ នឹងសាបសូន្យ ក៏ត្រឹមតែលោកិយ-គុណប៉ុណ្ណោះ ដូច្នោះ ឧបទ្រវៈពីរយ៉ាងខាងដើម លោកទើបមិនពោលទុកយ៉ាងនេះ ដោយប្រការដូច្នេះ ។ តែការបួសក្នុងព្រះសាសនា មានលាភច្រើន និងការបួសក្នុងព្រះសាសនានោះ មានគុណដែលនឹងគប្បីបានសម្រេចធំក្រៃលែងជាង គឺ មគ្គ ៤ ផល ៤ និព្វាន ១ ។ ខត្តិយកុមារជាឧភតោសុជាត ប្រថាប់លើកដំរី ស្តេចទ្រង់ប្រពាតព្រះនគរ កាលធ្លាក់អំពីកដំរី រមែងជាទុក្ខច្រើន យ៉ាងណា អ្នកដែលសាបសូន្យអំពីព្រះសាសនាក៏ដូច្នោះ រមែងសាបសូន្យអំពីលោ-កុត្តរគុណ ៩ ប្រការដូច្នេះ ។ ព្រោះហេតុនោះ លោកទើបពោលឧបទ្រវៈរបស់អ្នកប្រព្រឹត្តព្រហ្មចរិយៈទុកយ៉ាងនេះ ។

បទថា **តស្មា** សេចក្តីថា ព្រោះឧបទ្រវៈរបស់អ្នកប្រព្រឹត្តព្រហ្មចរិយៈ

មានវិបាកជាទុក្ខច្រើនជាង ឧបទ្រវៈដ៏សេស ឬព្រោះវត្តបដិបត្តិរបស់បុគ្គលជាសត្រូវ រមែងប្រព្រឹត្តទៅដើម្បីវត្តមិនជាប្រយោជន៍ ដើម្បីទុក្ខរហូតអស់កាលយូរ វត្តបដិបត្តិរបស់អ្នកជាមិត្ត រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដូច្នោះ គប្បីប្រកបការហៅដោយភាពជាមិត្ត និងមិនមែនហៅដោយភាពជាសត្រូវ ដោយអត្ថទាំងមុនទាំងក្រោយយ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **មិត្តវត្តាយ** ប្រែថា ដោយការបដិបត្តិជាមិត្ត ។ បទថា **សបត្តវត្តាយ** ប្រែថា ដោយការបដិបត្តិជាសត្រូវ ។

**[២៤]** បទថា **វោក្កម្ម ច សត្ថុ សាសនំ** សេចក្តីថា កាលល្មើសកន្លងនូវអាបត្តិ សូម្បីត្រឹមតែទុក្កដ និងទុព្ភាសិត ឈ្មោះថា ប្រព្រឹត្តដើម្បីគេចវេះ កាលមិនកន្លងល្មើស ដូច្នោះ ឈ្មោះថា មិនប្រព្រឹត្តគេចវេះ ។ បទថា **ន តេ អហំ អានន្ទ តថា បរក្កមិស្សាមិ** សេចក្តីថា តថាគតមិនបដិបត្តិក្នុងលោកទាំងឡាយយ៉ាងនោះ ។ បទថា **អាមកេ** ប្រែថា មិនទាន់ឆ្អិន ។ បទថា **អាមកមត្តេ** ប្រែថា ក្នុងកាជនៈឆៅ គឺ មិនទាន់ស្ងួតល្អ ។ ពិតហើយ ជាងឆ្នាំងសន្សឹមៗ យកដៃទាំងពីរទ្រកាជនៈឆៅដែលនៅមិនស្ងួតល្អ មិនទាន់ឆ្អិន ដោយគិតថា កុំបែកឡើយ ។ ពន្រឹកសេចក្តីថា តថាគតនឹងមិនបដិបត្តិក្នុងអ្នកទាំងឡាយ

ដូចជាផ្ទាំងបដិបត្តិក្នុងភាជនៈនៅនោះ ដោយប្រការដូច្នេះ ។ បទថា **និគ្គយ្ហ និគ្គយ្ហ** សេចក្តីថា តថាគតនឹងមិនប្រៀនប្រដៅតែមួយដង ហើយស្ងៀម តែនឹងតិះដៀលហើយ ប្រៀនប្រដៅ គឺ ទូន្មានរឿយៗ ។ បទថា **បវយ្ហ បវយ្ហ** ប្រែថា តថាគតនឹងលើកសរសើរ នឹងលើកតម្កើង ។ ប្រៀបដូចជាផ្ទាំង ដកភាជនៈដែលខូចៗ ក្នុងភាជនៈដែលឆ្អិនចេញ គជាគំនរទុក គឺ យកតែចំណែកដែលល្អប៉ុណ្ណោះ យ៉ាងណា សូម្បីតថាគតក៏ដូច្នោះ នឹងគាំទ្រលើកតម្កើង ពោលទូន្មានជាស់តឿន ទូន្មានរឿយៗ ។ បទថា **យោ សារោសោ ឋស្សតិ** សេចក្តីថា បណ្តាអ្នកទាំងឡាយដែលតថាគតពោលទូន្មានហើយ បុគ្គលណាមានខ្លឹម គឺ មគ្គផល បុគ្គលនោះ នឹងតាំងនៅបាន ម្យ៉ាងទៀត សូម្បីលោកិយគុណ ក៏ប្រាថ្នាយកថា ជាខ្លឹមក្នុងទីនេះដូចគ្នា ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា មហាសុញ្ញតសូត្រទី ២

# អ ដ្ឋ ក ថា

## អច្ឆរិយព្ភូតធម្មសូត្រទី ៣

[២៥] *អច្ឆរិយព្ភូតធម្មសូត្រ មានបទផ្ដើមថា* ***ឯវមេ្ម សុតំ*** *ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៖*

*បណ្ដាបទទាំងនោះ បទថា* ***យត្រ ហិ នាម*** *ជានិបាតចុះក្នុងអត្ថថា អស្ចារ្យ អធិប្បាយថា ព្រះតថាគតព្រះអង្គណា ។ ដែលឈ្មោះថា* ***បបញ្ចធម៌*** *ក្នុងបទថា* ***ឆិន្នបបញ្ចេ*** *នេះ បានដល់ កិលេស ៣ យ៉ាង គឺ តណ្ហា មានះ និងទិដ្ឋិ ។ កម្មវដ្ដៈដែលជាកុសល និងអកុសល លោកហៅថា* ***វដ្ដៈ*** *ក្នុងបទថា* ***ឆិន្នវដ្ដុមេ*** *នេះ ។*

*បទថា* ***បរិយាទិន្នវដ្ដេ*** *ជាវេវចនៈរបស់បទថា* ***ឆិន្នវដ្ដុមេ*** *នោះឯង ។*

*បទថា* ***សព្វទុក្ខវីសតិវដ្ដេ*** *សេចក្ដីថា កន្លងបង់នូវទុក្ខ ពោលគឺ វិបាកវដ្ដៈទាំងពួង ។*

*បទថា* ***អនុស្សរិស្សតិ*** *នេះ ជាពាក្យពោលដល់អនាគតកាល ដោយប្រើនិបាតថា* ***យត្រ*** *។ តែក្នុងបទនេះ គប្បីជ្រាបសេចក្ដីថា លោកប្រើសំដៅ*

ដល់អតីត ។ ពិតហើយ ព្រះមានព្រះភាគទ្រង់រឭកដល់ព្រះពុទ្ធទាំងនោះហើយ មិនមែនរឭកដល់ក្នុងកាលឥឡូវនេះ ។

[២៦] បទថា ឯវំ ជច្ចា សេចក្តីថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សី ជាដើម មានព្រះជាតិជាក្សត្រិយ៍ ព្រះពុទ្ធទាំងឡាយ មានព្រះកកុសន្ធៈជាដើម មានព្រះជាតិជាព្រាហ្មណ៍ ។

បទថា ឯវំ គោត្តា សេចក្តីថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើម ជាកោណ្ឌញ្ញគោត្រ ព្រះពុទ្ធទាំងឡាយ មានព្រះកកុសន្ធៈជាដើម ជាកស្សបគោត្រ ។

បទថា ឯវំ សីលា សេចក្តីថា មានសីលយ៉ាងនេះ គឺ មានសីលទាំងលោកិយៈ និងលោកុត្តរៈ ។

ក្នុងបទថា ឯវំ ធម្មា នេះ លោកសំដៅយកធម៌ដែលប្រព្រឹត្តទៅក្នុងបក្ខពួកនៃសមាធិ អធិប្បាយថា មានសមាធិយ៉ាងនេះ គឺ មានសមាធិជាទាំងលោកិយៈ និងលោកុត្តរៈ ។ បទថា ឯវំ បញ្ញា សេចក្តីថា មានបញ្ញាយ៉ាងនេះ គឺ មានទាំងបញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ ។ ក៏ក្នុងបទថា ឯវំ វិហារី នេះ ក៏ព្រោះកាន់យកធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកសមាធិទុកក្នុងខាងក្រោយ

ហើយក៏ជាការកាន់វិហារធម៌ទុកផង បើនឹងមានអ្នកជំទាស់ថា ហេតុអ្វី លោកទើបកាន់យកវត្ថុដែលកាន់យកហើយទៀតហ្ន៎ ។ ឆ្លើយថា ប្រការនេះលោកមិនកាន់យកយ៉ាងនោះឡើយ ។ ពិតហើយ ការដែលលោកកាន់យកវត្ថុដែលកាន់យកហើយទៀតនេះ ក៏ដើម្បីនឹងសម្តែងដល់និរោធសមាបត្តិ ព្រោះដូច្នោះ ក្នុងសេចក្តីនេះ បានសេចក្តីយ៉ាងនេះថា មានប្រក្រតីនៅដោយនិរោធសមាបត្តិ យ៉ាងនេះ ។

ក្នុងបទថា **ឯវំ វិមុត្តា** នេះ បានដល់ វិមុត្តិ ៥ យ៉ាង គឺ វិក្ខម្ភនវិមុត្តិ ១ តទង្គវិមុត្តិ ១ សមុច្ឆេទវិមុត្តិ ១ បដិបស្សទ្ធិវិមុត្តិ ១ និស្សរណវិមុត្តិ ១ ក្នុងវិមុត្តិទាំង ៥ នោះ សមាបត្តិ រាប់ជាវិក្ខម្ភនវិមុត្តិ ព្រោះរួចផុតហើយអំពីកិលេស មាននីវរណៈជាដើម ដែលខ្លួនគ្របសង្កត់នោះឯង ។ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម រាប់ជាតទង្គវិមុត្តិ ព្រោះរួចផុតហើយអំពីនិច្ចសញ្ញាជាដើម ដែលខ្លួនលះបង់ហើយ ដោយអំណាចនៃអង្គដែលជាសត្រូវ របស់មគ្គនោះៗ ។ អរិយមគ្គ ៤ រាប់ជាសមុច្ឆេទវិមុត្តិ ព្រោះរួចផុតអំពីកិលេសទាំងឡាយដែលខ្លួនដកឡើងហើយនោះឯង ។ សាមញ្ញផល ៤ រាប់ជាបដិបស្សទ្ធិវិមុត្តិ ព្រោះកិលេសទាំងឡាយកើតឡើងហើយក្នុងទីបំផុតនៃបដិបស្សទ្ធិដោយ

អានុភាពនៃមគ្គ ។ និព្វាន រាប់ជានិស្សរណវិមុត្តិ ព្រោះជាការរលាស់ចេញ កម្ចាត់ចេញ តាំងនៅក្នុងទីឆ្ងាយពីកិលេសទាំងពួង ។ ក្នុងសេចក្តីនេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា រួចផុតហើយយ៉ាងនេះ ដោយអំណាចនៃវិមុត្តិ ៥ ទាំងនេះ ដោយប្រការដូច្នេះ ។

**[២៧]** បទថា *តស្មាតិហ* សេចក្តីថា ព្រោះហេតុដែលលោកពោលថា ព្រះតថាគតទាំងឡាយ គួរអស្ចារ្យដូច្នោះ អច្ឆរិយព្ភុតធម៌ទាំងឡាយរបស់ព្រះតថាគត ទើបច្បាស់លាស់ក្រៃលែងហួសប្រមាណ ។

**[២៨]** ក្នុងបទថា *សតោ សម្បជានោ* នេះ បានដល់ សម្បជញ្ញៈ ២ យ៉ាង គឺ ទាំងក្នុងមនុស្សលោក និងទេវលោក ។ ក្នុងសម្បជញ្ញៈ ២ នោះ ក្នុងវេស្សន្តរជាតក ព្រះវេស្សន្តរឲ្យព្រះឱរសទាំងពីរដល់ព្រាហ្មណ៍ហើយ ក្នុងថ្ងៃស្អែកថ្វាយព្រះមហេសីដល់ស្តេចសក្កៈ កាលនឹងកាន់យកពរ ៨ យ៉ាង ដែលស្តេចសក្កៈទ្រង់ជ្រះថ្លាប្រទានហើយ បានជ្រើសរើសកាន់យកពរថា យើងចូរបដិសន្ធិក្នុងភពតុសិត យ៉ាងនេះថា

កាលបើកន្លងផុតពីអត្តភាពនេះទៅ សូមឲ្យទៅកាន់ឋានសួគ៌
ទៅដល់ជាន់តុសិតដែលជាកន្លែងវិសេស មិនគប្បីត្រឡប់អំពី

នោះ ពរនេះជាពរទី ៨ ។

ចាប់តាំងពីនោះមក ក៏ដឹងថា យើងនឹងកើតក្នុងតុសិតពិភព ។ នេះចាត់ជាសម្បជញ្ញៈក្នុងមនុស្សលោក ។ កាលព្រះអង្គទ្រង់ចុតិអំពីអត្តភាពជាព្រះវេស្សន្តរហើយ កើតក្នុងភពតុសិត បានដឹងខ្លួនថា យើងកើតហើយ នេះជាសម្បជញ្ញៈក្នុងទេវលោក ។

សួរថា ក៏ទេវតាដ៏សេសទាំងឡាយមិនដឹងឬ ។ ឆ្លើយថា មិនដឹងក៏មិនមែន តែទេវតាទាំងនោះ ត្រូវក្រឡេកមើលដើមកល្បព្រឹក្សជិតវិមានក្នុងឧទ្យានដែលពួកទេពអប្សរ បានដាស់ឲ្យភ្ញាក់ដោយសម្លេងតន្ត្រីទិព្វ ឲ្យរឭកថា អ្នកនិរទុក្ខ នេះជាទេវលោក លោកកើតក្នុងទេវលោកនេះហើយ ដូច្នេះ ទើបនឹងដឹង ។ ព្រះពោធិសត្វមិនដឹងក្នុងបឋមជវនវារៈ ។ រាប់ពីទុតិយជវនវារៈទៅ ទើបដឹង ។ ការដឹងរបស់ព្រះអង្គមិនសាធារណៈទូទៅ ដូចអ្នកដទៃ ដូចពណ៌នាមកដូច្នេះ ។

**[២៩]** ក្នុងបទថា ***អដ្ឋាសិ*** នេះ សេចក្តីថា សូម្បីទេវតាពួកដទៃនឹងតាំងនៅក្នុងភពនោះ ក៏រមែងដឹងខ្លួនថា ពួកយើងតាំងនៅហើយក៏ពិត តែទេវតាទាំងនោះ ត្រូវឥដ្ឋារម្មណ៍ដែលមានកម្លាំង ក្នុងទ្វារទាំង ៦ គ្របសង្កត់ ក៏បាត់បង់សតិ មិនដឹងសូម្បីវត្ថុដែលខ្លួនបរិភោគហើយ ផឹកហើយ រមែងចុតិ ព្រោះ

ការអត់អាហារ ។

សួរថា ព្រះពោធិសត្វមិនមានអារម្មណ៍យ៉ាងនោះឬ ។ ឆ្លើយថា មិនមានក៏មិនមែន ។ ព្រោះថា ព្រះអង្គ រមែងនៅលើទេវតាដ៏សេសដោយឋានៈ ១០ ។ ក៏ព្រះអង្គមិនព្រមឲ្យអារម្មណ៍ញាំញី ព្រះអង្គគ្របសង្កត់អារម្មណ៍នោះតាំងនៅបាន ។ ព្រោះហេតុនោះ ទើបត្រាស់ថា **សតោ សម្បជានោ អានន្ទ ពោធិសត្តោ តុសិតេ កាយេ អដ្ឋាសិ** ។

**[៣០]** បទថា **យាវតាយុកំ** នេះ សួរថា ក្នុងអត្តភាពដ៏សេស ព្រះពោធិសត្វមិនតាំងនៅរហូតដល់អស់អាយុឬ ។ ឆ្លើយថា ពិតហើយមិនតាំងនៅរហូតដល់អស់អាយុ ។ ក៏ក្នុងកាលដទៃៗ ព្រះពោធិសត្វកើតក្នុងទេវលោកដែលទេវតាមានអាយុវែង មិនអាចបំពេញបារមីក្នុងទេវលោកនោះបាន ដូច្នោះព្រះអង្គទ្រង់បិទព្រះនេត្រទាំងពីរ ធ្វើអធិមុត្តកាលកិរិយា (សង្កត់ចិត្តឲ្យស្លាប់) ហើយកើតក្នុងមនុស្សលោក កាលកិរិយានេះ មិនមានដល់ទេវតាពួកដទៃ ។ ក៏ក្នុងគ្រានោះ មិនមានការលួចទ្រព្យ មិនមានអ្នកមិនរក្សាសីល ព្រះអង្គតាំងនៅរហូតអស់អាយុ ព្រោះទ្រង់បំពេញបារមីគ្រប់យ៉ាងបរិបូណ៌ហើយ ។ ព្រះអង្គមានសតិសម្បជញ្ញៈ ឃ្លាតចាកពួកទេវតាជាន់តុសិត ស្ថិតនៅក្នុងព្រះគភ៌ព្រះ-

មាតា ។ ព្រះពោធិសត្វទ្រង់បំពេញព្រះបារមីគ្រប់យ៉ាងជាមុន ហើយបានតាំងនៅរហូតអស់ព្រះជន្មក្នុងគ្រានោះ ដោយប្រការដូចពណ៌នាមកដូច្នេះ ។

ក៏បុព្វនិមិត្ត ៥ យ៉ាង គឺ ផ្កាឈើស្វិត ១ សំពត់សៅហ្មង ១ ញើសចេញអំពីក្លៀក ១ កាយផ្ដើមសៅហ្មង ១ ទេវតាមិនតាំងនៅលើអាសនៈរបស់ទេវតា ១ នេះ រមែងកើតដល់ទេវតាទាំងឡាយ ដើម្បីនឹងជាស់តឿនឲ្យដឹងថាឥឡូវនេះ នៅសល់ ៧ ថ្ងៃនឹងត្រូវចុតិ ដោយការរាប់ថ្ងៃរបស់មនុស្ស ។ បណ្ដាបទទាំងនោះ បទថា **មាលា** បានដល់ ផ្កាឈើប្រដាប់ ដោយរាប់ថ្ងៃបដិសន្ធិជាកំណត់ ។ បានឮថា ផ្កាឈើទាំងនោះនឹងមិនក្រៀមស្វិតរហូតដល់ ៥៧ កោដិនឹង ៦០ សែនឆ្នាំ ក៏ស្វិតស្រពោនក្នុងគ្រានោះ ។ សូម្បីក្នុងសំពត់ទាំងឡាយក៏ន័យនេះដូចគ្នា ។ ក៏ទេវតាទាំងឡាយ រមែងមិនស្គាល់ត្រជាក់ មិនស្គាល់ក្ដៅ រហូតដល់អស់កាលមានប្រមាណប៉ុណ្ណេះ ។ តែក្នុងកាលនោះ ញើសនឹងហូរចេញចាករាងកាយជាគ្រាប់ៗ ។ ក៏រហូតដល់អស់កាលមានប្រមាណប៉ុណ្ណេះ រាងកាយរបស់ទេវតាទាំងនោះ មិនធ្លាប់ប្រាកដថា សៅហ្មង ដូចជា ធ្មេញបាក់ ឬសក់ស្កូវឡើយ ។ ទេពធីតា នឹងប្រាកដរាងកាយដូចស្រីក្រមុំវ័យ ១៦ ឆ្នាំទេវបុត្រនឹងប្រាកដរាងកាយដូចជាកម្លោះវ័យ ២០ ឆ្នាំ ។ ក្នុងវេលាជិតស្លាប់

ទេវបុត្រទាំងនោះ រមែងមានអត្តភាពសៅហ្មង ។ មួយទៀត ទេវបុត្រទាំងនោះ មិនមានសេចក្តីអផ្សុកក្នុងទេវលោក រហូតអស់កាលប្រមាណប៉ុណ្ណោះ តែក្នុងវេលាជិតស្លាប់ ទេវបុត្ររមែងនឿយហត់ នឿយណាយ តក់ស្លុត ញាប់ញ័រ មិនត្រេកអរក្នុងអាសនៈរបស់ខ្លួន ។ ទាំងនេះ ចាត់ជាបុព្វនិមិត្ត ៥ ប្រការ ។ និមិត្តទាំងឡាយ មានឧក្កាបាតធ្លាក់ ផែនដីញ័រ និងច័ន្ទគ្រាសជាដើម នឹងប្រាកដចំពោះអ្នកមានបុណ្យច្រើន មានសក្តិធំក្នុងលោក ដូចព្រះរាជា អាមាត្រជាអ្នកធំ ជាដើមប៉ុណ្ណោះ មិនប្រាកដដល់សាមញ្ញជនទូទៅ យ៉ាងណា បុព្វនិមិត្ត ៥ ក៏ដូច្នោះ នឹងប្រាកដចំពោះពួកទេវតាដែលមានសក្តិធំប៉ុណ្ណោះ មិនប្រាកដដល់ទេវតាទូទៅ ។

ក៏ក្នុងពួកមនុស្សទាំងឡាយ ហោរជាដើមប៉ុណ្ណោះ ទើបនឹងដឹងបុព្វនិមិត្តទាំងឡាយ មនុស្សទូទៅមិនដឹង យ៉ាងណា ពួកទេវតាទាំងឡាយក៏ដូច្នោះ ទេវតាទូទៅ សូម្បីនោះរមែងមិនដឹង នឹងដឹងក៏ចំពោះទេវតាដែលឆ្លាតប៉ុណ្ណោះ ។ ក៏ក្នុងបណ្តាទេវតាទាំងនោះ ទេវបុត្រអ្នកកើតដោយកុសលកម្មបន្តិចបន្តួច កាលបុព្វនិមិត្តកើតហើយ អ្នកណានឹងដឹងថា ឥឡូវនេះ ពួកយើងនឹងទៅកើតក្នុងទីណា ទើបខ្លាច ចំណែកទេវបុត្រអ្នកមានបុណ្យច្រើន គិតថា ពួកយើងអាស្រ័យ

ទានដែលឲ្យ សីលដែលរក្សា ភាវនាដែលចម្រើនហើយ នឹងសោយសម្បត្តិក្នុងទេវលោកជាន់ខ្ពស់ៗ ឡើងទៅ ទើបមិនខ្វាច សម្រាប់ព្រះពោធិសត្វ ទ្រង់ឃើញបុព្វនិមិត្តទាំងនោះហើយ គិតថា ឥឡូវនេះយើងនឹងបានជាព្រះពុទ្ធក្នុងអត្តភាពតទៅ ទើបមិនខ្វាច ។ គ្រានោះ កាលនិមិត្តទាំងនោះ ប្រាកដដល់ព្រះពោធិសត្វហើយ ទេវតាក្នុងម៉ឺនចក្រវាឡមកប្រជុំគ្នា ហើយទូលអារាធនាថា បពិត្រព្រះអង្គអ្នកនិរទុក្ខ ការដែលព្រះអង្គទ្រង់បំពេញទសបារមី នឹងប្រាថ្នាសម្បត្តិថា នឹងជាស្តេចសក្កៈក៏ទេ នឹងប្រាថ្នាសម្បត្តិថា នឹងជាមារ ជាព្រហ្មជាស្តេចចក្រពត្តិក៏ទេ តែទ្រង់បំពេញដោយប្រាថ្នានឹងជាព្រះពុទ្ធ ដើម្បីជួយសត្វលោក បពិត្រព្រះអង្គអ្នកនិរទុក្ខ ឥឡូវនេះ ជាកាលដែលសមគួរ ដើម្បីការត្រាស់ដឹងរបស់ព្រះអង្គ បពិត្រព្រះអង្គអ្នកនិរទុក្ខ ឥឡូវនេះជាសម័យដែលសមគួរ ដើម្បីការត្រាស់ដឹងរបស់ព្រះអង្គ ។

លំដាប់នោះ ព្រះមហាសត្វ ទ្រង់មិនទាន់ទទួលពាក្យរបស់ទេវតាទាំងឡាយ ទ្រង់ត្រួតមើលមហាវិលោកនៈ ៥ ប្រការ គឺ កាល ទ្វីប ប្រទេស ត្រកូល និងការកំណត់អាយុរបស់ព្រះមាតា ។ ក្នុងមហាវិលោកនៈ ៥ ប្រការនោះ ទ្រង់ត្រួតមើលកាលមុនថា ជាវេលាសមគួរ ឬមិនទាន់សមគួរ ។ វេលា

ដែលមនុស្សទាំងឡាយមានអាយុវែងជាង ១ សែនឆ្នាំឡើងទៅ ឈ្មោះថា វេលាដែលមិនសមគួរ ក្នុងមហាវិលោកនៈ ៥ ប្រការនោះ ។ ព្រោះហេតុអ្វី ។ ព្រោះក្នុងវេលានោះ ជាតិ ជរា និងមរណៈ រមែងមិនប្រាកដដល់សត្វទាំងឡាយ និងដែលឈ្មោះថា ការសម្តែងធម៌របស់ព្រះពុទ្ធទាំងឡាយ នឹងរួចផុតទៅចាកត្រៃលក្ខណ៍ រមែងមិនមាន កាលព្រះអង្គត្រាស់ថា **អនិច្ចំ ទុក្ខំ អនត្តា** មនុស្សទាំងឡាយនឹងគិតថា នេះ ព្រះអង្គត្រាស់ដល់អ្វី ហើយមិនបង្អោនចិត្តដើម្បីនឹងស្តាប់ មិនទទួលរាប់អាន ឬជឿតាម អំពីនោះ រមែងមិនមានការត្រាស់ដឹងមគ្គផល កាលមិនមានការត្រាស់ដឹងមគ្គផល ពាក្យទូន្មាន រមែងមិនចាត់ជានិយ្យានិកធម៌ (គឺនាំសត្វចេញចាកភព) បានព្រោះដូច្នោះ វេលានោះ ទើបចាត់ជាវេលាដែលមិនសមគួរ ។ វេលាដែលមនុស្សទាំងឡាយ មានអាយុតិចជាងមួយរយឆ្នាំ ក៏មិនចាត់ថា ជាកាលដែលសមគួរ ។ ព្រោះហេតុអ្វី ។ ព្រោះវេលានោះ មនុស្សទាំងឡាយមានកិលេសក្រាស់ និងពាក្យទូន្មានដែលឲ្យដល់មនុស្សដែលមានកិលេសក្រាស់ រមែងមិនតាំងនៅក្នុងឱវាទ (ព្រះធម៌នោះ) រមែងសាបសូន្យទៅដោយឆាប់រហ័ស ដូចយកកំណាត់ឈើគូសទម្លាក់ចុះក្នុងទឹក ព្រោះដូច្នោះ សូម្បីវេលានោះ ក៏មិនទាន់ចាត់ថា ជាកាលដែលសមគួរ ។ តែកាល

កំណត់អាយុ រាប់ពីមួយសែនឆ្នាំចុះមក និងពីមួយរយឆ្នាំឡើងទៅ ចាត់ជាកាលដែលសមគួរ ។ ព្រោះក្នុងគ្រានោះ ជាវេលាដែលមនុស្សមានអាយុប្រមាណ ១០០ ឆ្នាំ ។ លំដាប់នោះ ព្រះមហាសត្វទ្រង់ពិចារណាឃើញហើយថា ជាកាលសមគួរនឹងគប្បីមកកើត ។ តអំពីនោះ កាលនឹងទ្រង់ត្រួតមើលទ្វីប ទ្រង់បានពិចារណាមើលទ្វីបទាំង ៤ ព្រមទាំងទ្វីបដែលជាបរិវារ ទ្រង់ឃើញថា ព្រះពុទ្ធទាំងឡាយ រមែងមិនមកកើតក្នុងទ្វីបទាំង ៣ នឹងកើតតែក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។ អំពីនោះ ទ្រង់ត្រួតមើលប្រទេសថា ដែលឈ្មោះថា ជម្ពូទ្វីបចាត់ជាទ្វីបធំ មានប្រមាណដល់ម៉ឺនយោជន៍ ព្រះពុទ្ធទាំងឡាយរមែងមកកើតក្នុងប្រទេសណាហ្ន៎ ទ្រង់ពិចារណាឃើញមជ្ឈិមប្រទេសនោះឯង ។

ដែលឈ្មោះថា មជ្ឈិមប្រទេស បានដល់ ប្រទេសដែលលោកពោលទុកហើយក្នុងព្រះវិន័យ ដោយន័យជាដើមថា មាននិគមឈ្មោះកជង្គលៈ នៅក្នុងទិសបូព៌ា ដូច្នេះ ។ ក៏មជ្ឈិមប្រទេសនោះ មានកំណត់ប្រវែង ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ វាស់ដោយជុំវិញបាន ៩០០ យោជន៍ ក៏ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់បំពេញបារមី ៤ អសង្ខេយ្យមួយសែនកប្បខ្លះ ៨ អសង្ខេយ្យមួយសែនកប្បខ្លះ ១៦ អសង្ខេយ្យមួយសែនកប្បខ្លះ ហើយស្តេចក៏ឧប្បត្តិក្នុង

ប្រទេសនេះ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ទ្រង់បំពេញបារមី ២ អសង្ខេយ្យ មួយសែនកប្បហើយមកកើត ។ ព្រះមហាសាវកទាំងឡាយ មានព្រះសារីបុត្រ និង ព្រះមហាមោគ្គល្លានជាដើម បំពេញបារមី ១ អសង្ខេយ្យមួយសែនកប្ប ហើយមកកើត ។ ស្តេចចក្រពត្តិគ្រប់គ្រងលើទ្វីបធំទាំងបួន មានទ្វីបតូចពីរ ពាន់ជាបរិវារ ស្តេចក៏មកកើត ។ មួយ៉ាងទៀត ទាំងក្សត្រិយ៍ ព្រាហ្មណ៍ និង គហបតីមហាសាល អ្នកមានសក្តិធំពួកដទៃ ក៏មកកើតក្នុងប្រទេសនេះ ។ ក៏ ក្នុងប្រទេសនេះ មានព្រះនគរឈ្មោះថា កបិលភស្តុជារាជធានី ព្រះអង្គ ទើប ទ្រង់ដាក់ព្រះទ័យថា យើងគួរកើតក្នុងនគរកបិលភស្តុនោះ ។ អំពីនោះ ទ្រង់ ត្រួតមើលត្រកូល ពិចារណាត្រកូលថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងកើត ក្នុងត្រកូលដែលលោកសម្មតិ ឥឡូវនេះ ត្រកូលក្សត្រិយ៍ជាត្រកូលដែលលោក-សម្មតិ យើងនឹងកើតក្នុងត្រកូលក្សត្រិយ៍នោះ ព្រះរាជាទ្រង់ព្រះនាមថា សុទ្ធោទនៈ នឹងជាព្រះបិតារបស់យើង ។ តអំពីនោះ ទ្រង់ត្រួតមើលព្រះមាតា ទ្រង់ពិចា-រណាថា ដែលឈ្មោះថា ព្រះពុទ្ធមាតា រមែងមិនជាស្ត្រីឡេះឡោះ មិនជាអ្នក លេងសុរា បំពេញបារមីមក ១ សែនកប្ប រាប់តាំងពីកើត រមែងមានសីល ៥ មិនដាច់ ក៏ព្រះទេវីព្រះនាមថា មហាមាយា ព្រះទេវីនេះ មានលក្ខណៈដូច្នេះ

ព្រះនាងដែលជាព្រះមាតារបស់យើង តើព្រះនាងនឹងមានអាយុប៉ុន្មាន ទ្រង់ឃើញថា អាយុរបស់ព្រះនាង (ក្រោយទ្រង់ព្រះគភ៌) ១០ ខែ (ប្រសូតិហើយ) នឹងមានអាយុបាន ៧ ថ្ងៃ ។ ព្រះមហាសត្វគ្រាទ្រង់ត្រួតមើល មហាវិលោកនៈ ៥ ប្រការ ដូចពោលមកនេះហើយ ទើបត្រាស់ថា ម្នាលអ្នកនិរទុក្ខទាំងឡាយ ដល់វេលាដែលយើងនឹងជាព្រះពុទ្ធហើយ កាលនឹងធ្វើការសង្គ្រោះ ទើបព្រមទទួលពាក្យរបស់ទេវតាទាំងឡាយ បញ្ជូនទេវតាទាំងនោះទៅ ដោយព្រះតម្រាស់ថា ចូរត្រឡប់ទៅចុះអ្នកទាំងឡាយ ព្រះមហាសត្វហែហមទៅដោយទេវតាជាន់តុសិត ស្ដេចចូលទៅកាន់សួននន្ទវ័នក្នុងតុសិតបុរី ។ ក៏ក្នុងទេវលោកគ្រប់ជាន់ រមែងមានសួននន្ទវ័នទាំងនោះ ។ សូម្បីក្នុងសួននន្ទវ័ននោះ ទេវតាទាំងឡាយឲ្យព្រះពោធិសត្វរឭកដល់ឱកាសនៃកុសលកម្មដែលធ្លាប់ធ្វើទុកក្នុងជាតិមុនថា ព្រះអង្គចូរចុតិអំពីតុសិតបុរីនេះទៅកាន់សុគតិចូរ ចុតិអំពីតុសិតបុរីនេះទៅកាន់សុគតិដូច្នេះគ្រាប់ទៅ ។ ព្រះពោធិសត្វហែហមទៅដោយទេវតាអ្នកជួយឲ្យរឭកដល់កុសលកម្មយ៉ាងនេះ ស្ដេចត្រាច់ទៅក្នុងនន្ទវ័ន ហើយក៏ចុតិ ។ គ្រាចុតិយ៉ាងនេះហើយ ក៏ដឹងថា យើងកំពុងចុតិ មិនមែនដឹងចុតិចិត្ត ។ សូម្បីបដិសន្ធិហើយ ក៏មិនដឹងបដិសន្ធិចិត្ត ។ ព្រះអង្គដឹងច្បាស់យ៉ាងនេះថា យើងបដិសន្ធិ

ក្នុងទីនេះ ក៏ព្រះថេរៈពួកខ្លះពោលថា គួរនឹងបានអាវជ្ជនបរិយាយ ព្រះមហាសត្វនឹងដឹងក្នុងទុតិយចិត្តវារៈ និងក្នុងតតិយចិត្តវារៈប៉ុណ្ណោះ ។ តែព្រះមហាសិវត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា បដិសន្ធិរបស់ព្រះមហាសត្វទាំងឡាយមិនដូចបដិសន្ធិរបស់សត្វដទៃ សតិសម្បជញ្ញៈរបស់ព្រះមហាសត្វទាំងនោះ ដល់ទីបំផុតហើយ ក៏ព្រោះមិនអាចនឹងដឹងចិត្តដួងនោះ ដោយចិត្តដួងនោះបាន ដូច្នោះព្រះមហាសត្វ ទើបមិនដឹងចុតិចិត្ត សូម្បីក្នុងខណៈចុតិ រមែងដឹងថា យើងកំពុងចុតិ កាលបដិសន្ធិ ក៏មិនដឹងបដិសន្ធិចិត្ត ដឹងច្បាស់ថា យើងកំពុងបដិសន្ធិក្នុងទីឯណោះ ។ ក្នុងកាលនោះ ម៉ឺនលោកធាតុរមែងញាប់ញ័រ ដូច្នេះ ។ ក៏កាលព្រះមហាសត្វឈានចុះកាន់ព្រះគភ៌មាតាយ៉ាងនេះ ទ្រង់កាន់បដិសន្ធិដោយមហាវិបាកចិត្ត ដូចគ្នានឹងអសង្ខារិកកុសលចិត្ត ដែលសហគតដោយសោមនស្សនិងសម្បយុត្តដោយញាណ មានមេត្តាជាបុព្វភាគ ក្នុងបណ្តាបដិសន្ធិចិត្ត ១៩ ដួង ។ ចំណែកព្រះមហាសិវត្ថេរ ពោលថា ដោយមហាវិបាកចិត្ត ដែលសហគតដោយឧបេក្ខា ។ ក៏ព្រះមហាសត្វ កាលទ្រង់កាន់បដិសន្ធិ បានបដិសន្ធិក្នុងថ្ងៃពេញបូណ៌មីខែអាសាឍ ។

ដូចបានស្តាប់មក គ្រានោះ ព្រះនាងមហាមាយា ទ្រង់ព្រះសប្បាយដោយ

ការលេងនក្សត្រ ដែលសម្បូរណ៍ទៅដោយគ្រឿងផឹកដែលប្រាសចាកសុរា លាប របស់ក្រអូប និងគ្រឿងប្រដាប់ តែថ្ងៃទី ៧ អំពីថ្ងៃពេញបូណ៌មីខែអាសាឍ ក្នុងថ្ងៃទី ៧ ស្ដេចចេញពីព្រឹក ស្រង់ដោយទឹកក្រអូបប្រដាប់ព្រះវរកាយដោយ គ្រឿងអលង្ការទាំងពួង សោយព្រះក្រយាហារដ៏ប្រសើរ អធិដ្ឋានអង្គឧបោសថ ហើយស្ដេចចូលបន្ទប់ដែលមានសិរី ផ្ទំលើគ្រែដែលមានសិរី ទ្រង់លក់ទៅ ទ្រង់ បានព្រះសុបិន្តដូច្នេះថា មហារាជទាំង ៤ ទ្រង់លើកព្រះនាងព្រមទាំងក្រឡាបន្ទំ នាំទៅស្រះអនោត្តៈ ហើយដាក់ទុកត្រង់ចំណែកម្ខាង ។ គ្រានោះ ព្រះទេវីរបស់ ស្ដេចមហារាជទាំង ៤ នោះ បានមកឲ្យព្រះនាងស្រង់ ដើម្បីលាងជម្រះមន្ទិល របស់មនុស្ស ហើយឲ្យស្លៀកដណ្ដប់សំពត់ទិព្វ លាបស្រឡាបដោយរបស់ ក្រអូប ប្រដាប់សំពត់ទិព្វ ឲ្យទ្រង់ផ្ទំរក្សាសីលនៅក្នុងវិមានមាស ដែលមាន នៅខាងក្នុងភ្នំប្រាក់ ដែលតាំងនៅមិនឆ្ងាយពីស្រះអនោត្តៈនោះ ។ គ្រានោះ ព្រះពោធិសត្វជាដំរីស ត្រាច់ទៅលើកូនភ្នំមាសមួយ ដែលតាំងនៅមិនឆ្ងាយពី ស្រះអនោត្តៈនោះ ចុះអំពីភ្នំមាសនោះហើយ ឡើងកាន់ភ្នំប្រាក់ មកពីទិសឧត្តរ ចូលទៅកាន់វិមានមាស ធ្វើប្រទក្សិណព្រះមាតាហើយ ហាក់បីដូចជាចូលទៅ ក្នុងឧទរប្រទេសខាងស្ដាំ ។

លំដាប់នោះ ព្រះនាងភ្ញាក់ផ្អើលហើយ បានក្រាបទូលព្រះសុបិននោះចំពោះព្រះរាជា ។ លុះព្រឹកឡើង ព្រះរាជាត្រាស់បង្គាប់ឲ្យប្រធានព្រាហ្មណ៍ ប្រមាណ ៦៤ នាក់ ចូលគាល់ ចាត់ក្រាលអាសនៈមានតម្លៃច្រើន លើភូមិភាគដែល មានតិណជាតិខៀវខ្ចី តាក់តែងហើយដោយគ្រឿងសក្ការៈដែលជាមង្គល ធ្វើដោយលាជជាដើម ហើយនាំបាយបាយាសដ៏ប្រសើរផ្សំដោយទឹកដោះថ្លា ទឹកឃ្មុំ និងជុំស្ករគ្រួស ដាក់ក្នុងថ្នាំងមាស ថ្នាំងប្រាក់ដរាបពេញ ហើយគ្របថ្នាំងមាសដោយគម្របមាស ថ្នាំងប្រាក់ក៏ដូចគ្នា ព្រះរាជទានដល់ព្រាហ្មណ៍ទាំងឡាយដែលអង្គុយលើអាសនៈនោះ ។ ញុំាងព្រាហ្មណ៍ទាំងនោះឲ្យឆ្អែតស្កប់ស្កល់ ដោយសំពត់ និងមេគោជាងដែលជនពួកដទៃនាំមកឲ្យទៀតផង ។ លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់ឲ្យព្រាហ្មណ៍ទាំងឡាយ ដែលឆ្អែតគ្រប់គ្រាន់សប្បាយហើយ ប្រាប់ដល់ព្រះសុបិន ហើយទ្រង់សួរថា នឹងមានអ្វីកើតឡើង ។ ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គទ្រង់កុំព្រះវិតក្កៈឡើយ ព្រះទេវីរបស់ព្រះអង្គទ្រង់តាំងព្រះគភ៌ និងព្រះគភ៌នោះ ក៏ជាព្រះឱរស មិនមែនព្រះធីតា ព្រះអង្គនឹងមានព្រះឱរស បើព្រះឱរសនោះនឹងនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ បើចេញបួស នឹងបានជាព្រះពុទ្ធ ទ្រង់កម្ចាត់បង់នូវកិលេសបានហើយ

ក្នុងលោក ព្រះពោធិសត្វមានសតិ និងសម្បជញ្ញៈ ចុតិអំពីពួកទេវតាជាន់តុសិត ចូលកាន់ព្រះគភ៌ព្រះមាតា ដោយប្រការដូច្នេះ ។

**[៣១]** បណ្តាបទទាំងនោះ ដោយបទថា *សតោ សម្បជានោ* នេះ លោកសម្តែងថា ព្រះពោធិសត្វទ្រង់ឈានចុះ ដោយវិធីឈានចុះកាន់ព្រះគភ៌ក្នុងប្រការទី ៤ ។ ក៏ការឈានចុះកាន់ព្រះគភ៌មាន ៤ យ៉ាង ដូចព្រះបាលីថា ការឈានចុះកាន់គភ៌មាន ៤ យ៉ាងដូច្នេះ ។ សត្វពួកខ្លះក្នុងលោកនេះ ឈានចុះកាន់ផ្ទៃមាតាក៏មិនដឹងខ្លួន តាំងនៅក្នុងផ្ទៃមាតាក៏មិនដឹងខ្លួន ចេញចាកផ្ទៃមាតាក៏មិនដឹងខ្លួន នេះជាការឈានចុះកាន់គភ៌ប្រការទី ១ ។ ប្រការដទៃទៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ឈានចុះកាន់ផ្ទៃនៃមាតាដឹងខ្លួន តាំងនៅក្នុងផ្ទៃនៃមាតាមិនដឹងខ្លួន ចេញចាកផ្ទៃមាតាក៏មិនដឹងខ្លួន នេះជាការឈានចុះកាន់គភ៌ប្រការទី ២ ។ ប្រការដទៃទៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ឈានចុះកាន់ផ្ទៃមាតាដឹងខ្លួន តាំងនៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន តែចេញចាកផ្ទៃមកមិនដឹងខ្លួន នេះជាការឈានចុះកាន់គភ៌ប្រការទី ៣ ។ ប្រការដទៃទៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ឈានចុះកាន់ផ្ទៃមាតាក៏ដឹងខ្លួន តាំងនៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន ទាំងចេញចាកផ្ទៃមាតាក៏ដឹងខ្លួន នេះជាការឈានចុះកាន់គភ៌ប្រការទី

៤ ។

ក្នុង ៤ យ៉ាងទាំងនេះ ប្រការទីមួយ ជារបស់ពួកលោកិយមនុស្ស ។ ប្រការទីពីរ ជារបស់ព្រះអសីតិមហាសាវក ។ ប្រការទីបី ជារបស់ព្រះអគ្គ-សាវកទាំងពីរ និងព្រះបច្ចេកពោធិសត្វទាំងឡាយ បានឮថា បុគ្គលបីពួកទាំងនោះ កាលត្រូវខ្យល់កម្មជវាត បក់យកជើងឡើងលើ យកក្បាលចុះក្រោម ចេញចាកទ្វារកំណើតដែលចង្អៀតហួសប្រមាណ រមែងដល់នូវសេចក្តីទុក្ខយ៉ាងក្រៃលែង ឧបមាដូចត្រូវគេចាប់គ្រវែងចុះក្នុងជ្រោះជ្រៅច្រើនរយជួរបុរស ឬដូចដំរីដែលត្រូវចេញចាកប្រហោងកូនរនុក ដូច្នោះ ។ ដោយហេតុនោះ សេចក្តីដឹងខ្លួនថា យើងកំពុងចេញ ទើបមិនមានដល់បុគ្គលទាំង ៣ ពួកនោះ ។ ការឈានចុះកាន់គភ៌ប្រការទី ៤ រមែងមានចំពោះព្រះពោធិសត្វ ជាសព្វញ្ញូទាំងឡាយ ។ ពិតណាស់ ព្រះពោធិសត្វដែលសព្វញ្ញូទាំងឡាយនោះ កាលចាប់បដិសន្ធិក្នុងគភ៌ព្រះមាតាក៏ដឹង សូម្បីកាលនៅក្នុងគភ៌ព្រះមាតាក៏ដឹង ។ សូម្បីក្នុងវេលាប្រសូតិ ខ្យល់កម្មជវាតមិនអាចនឹងបក់យកព្រះបាទរបស់ព្រះពោធិ-សត្វជាសព្វញ្ញូទាំងនោះឲ្យឡើងលើ យកព្រះសិរសាចុះខាងក្រោមបាន ព្រះពោ-ធិសត្វទាំងនោះ ទ្រង់សណ្តូកព្រះហស្តទាំងពីរ ធ្មេចព្រះនេត្រ ហើយប្រថាប់ឈរ

ស្ដេចចេញចាកព្រះឧទរ ។

[៣២] ក្នុងបទថា **មាតុកុច្ឆឹ ឱក្កមតិ** នេះ មានអធិប្បាយថា រមែងឈានចុះកាន់គភ៌មាតា ។ ពិតហើយ កាលព្រះពោធិសត្វនោះ ឈានចុះកាន់គភ៌ព្រះមាតា ក៏រមែងមានហេតុអស្ចារ្យយ៉ាងនេះ កាលមិនឈានចុះ ក៏មិនមានហេតុអស្ចារ្យ ។ បទថា **អប្បមាណោ** ប្រែថា មានប្រមាណដ៏ច្រើន ។ អធិប្បាយថា បរិបូណ៌ ។ បទថា **ទេវានំ ទេវានុភាវំ** នេះ មានអធិប្បាយថា អានុភាពរបស់ទេវតាទាំងឡាយមានដូច្នេះ គឺ រស្មីរបស់សំពត់ដែលស្លៀក រមែងផ្សាយទៅបាន ១២ យោជន៍ របស់សរីរៈក៏ផ្សាយទៅបានយ៉ាងនោះ របស់គ្រឿងប្រដាប់ក៏ផ្សាយទៅបានយ៉ាងនោះ របស់វិមានក៏ផ្សាយទៅបានយ៉ាងនោះ កន្លងនូវទេវានុភាពនោះ ។ បទថា **លោកន្តរិកា** សេចក្ដីថា លោកន្តរិកនរករណ្ដៅមួយ រមែងមានក្នុងចន្លោះចក្រវាឡទាំងបី ក៏លោកន្តរិកនរកនោះ មានប្រមាណ ៨,០០០ យោជន៍ ។ ដូចប្រហោងទទេ រមែងមានក្នុងកណ្ដាលនៃកង់រទេះ ៣ ឬបាត្រ ៣ ដែលទល់គ្នានិងគ្នា ។ បទថា **អឃា** ប្រែថា បើកហើយជានិច្ច ។ បទថា **អសំវុតា** សេចក្ដីថា សូម្បីក្នុងខាងក្រោម ក៏មិនមានទីពំនាក់ ។ បទថា **អន្ធការា** ប្រែថា ងងឹតឈឹង ។ បទថា **អន្ធការតិមិសា**

សេចក្តីថា ប្រកបដោយពពកអ័ព្ទដែលធ្វើសេចក្តីងងឹត ព្រោះហាមការកើតឡើង នៃចក្ខុវិញ្ញាណ ។ បានឮថា ចក្ខុវិញ្ញាណ រមែងមិនកើតក្នុងលោកន្តរិកនរក នោះ ។

បទថា **ឯវំ មហិទ្ធិកា** សេចក្តីថា មានឫទ្ធិយ៉ាងនេះ គឺ បានឮថា ព្រះចន្ទ និងព្រះអាទិត្យ រមែងប្រាកដក្នុងទ្វីបទាំង ៣ គ្រាតែមួយព្រមគ្នា ។ មានអានុភាពច្រើនយ៉ាងនេះ គឺ កម្ចាត់ភាពងងឹត ហើយបំភ្លឺទៅបានក្នុងទិសមួយៗ ៨ លានមួយសែនយោជន៍ ។

បទថា **អាភាយ នានុភោន្តិ** គឺ ពន្លឺរបស់ខ្លួនមិនទាន់គ្រប់គ្រាន់ ។ បានឮថា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ រមែងមិនផ្សាយពន្លឺទៅដល់កណ្តាលរណ្តៅត្រង់ភ្នំចក្រវាឡបានឡើយ ។ ឯលោកន្តរិកនរក និងភ្នំចក្រវាឡក៏មិនបានកន្លងទៅ ។ ព្រោះដូច្នោះ លោកទើបសម្តែងថា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ មិនមានពន្លឺគ្រប់គ្រាន់បំភ្លឺទៅដល់លោកន្តរិកនរកនោះ ។

បទថា **យេបិ តត្ថ សត្តា** សេចក្តីថា សួរថា ពួកសត្វដែលកើតក្នុងលោកន្តរិកនរកនោះ ធ្វើកម្មអ្វីទុក ទើបកើតក្នុងទីនោះ ។ ឆ្លើយថា ធ្វើកម្មគ្រោតគ្រាត ធ្វើទារុណចំពោះមាតាបិតា ចំពោះសមណព្រាហ្មណ៍អ្នកតាំងនៅ

ក្នុងជម្ពូទ្វីប ខ្លះ ធ្វើកំហុសយ៉ាងជទៃដែលក្រៃលែងឡើងទៅទៀតខ្លះ ធ្វើកម្មសាហាវ ដូចសម្លាប់សត្វ ផ្តាច់ជីវិតជាដើម ជាប្រចាំរាល់ៗ ថ្ងៃខ្លះ ទើបកើតក្នុងលោកន្តរិកនរកនោះ ដូចជា អភយចោរ និងនាគចោរជាដើម ក្នុងតម្ពបណ្ណិទ្វីប ។ អត្តភាពរបស់សត្វទាំងនោះ មានប្រមាណ ៣ គាវុត ។ មានក្រចកវែងដូចក្រចកសត្វប្រចៀវ ។ សត្វទាំងនោះ ប្រើក្រចកតោងនៅត្រង់កណ្តាប់ភ្នំចក្រវាឡ ដូចពួកសត្វប្រចៀវតោងដើមឈើ ដូច្នោះ ។ តែកាលណាសត្វទាំងនោះ វារទៅប៉ះដៃគ្នានិងគ្នា កាលនោះសម្គាល់ថា យើងបានអាហារហើយ ក៏រំកិលវិលទៅជុំវិញត្រង់កណ្តាប់ភ្នំចក្រវាឡនោះ ហើយធ្លាក់ចុះក្នុងទឹករក្សាលោក ។ កាលខ្យល់បក់ត្រូវ ក៏បែកធ្លាក់ចុះក្នុងទឹក ដូចផ្លែពុទ្រា ។ ពេលធ្លាក់ចុះទៅ ក៏រលាយដូចដុំម្សៅដែលធ្លាក់ចុះទៅក្នុងទឹកក្រុត ។

បទថា **អញ្ញេបិ កិរ ភោ សន្តិ សត្តា** សេចក្តីថា រមែងឃើញប្រចក្សក្នុងថ្ងៃនោះថា សូម្បីសត្វពួកដទៃកាលសោយទុក្ខនេះ ក៏កើតក្នុងលោកន្តរិកនរកនេះ ដូចជាពួកយើងដែលកំពុងសោយទុក្ខធំ ដូច្នោះ ក៏ឱកាសនេះរមែងមិនតាំងនៅសូម្បីត្រឹមតែខណៈហុតបបរយាគូតែមួយដង ។ នឹងមានត្រឹមតែវេលាដែលលក់ទៅហើយភ្ញាក់ឡើងទទួលដឹងអារម្មណ៍ប៉ុណ្ណោះ ។ ចំណែកអាចារ្យអ្នកពោល

គម្ពីរទីឃនិកាយ ពោលថា ឱកាសនោះនឹងប្រាកដត្រឹមតែមួយខណៈទះដៃ ហើយក៏បាត់ទៅ ដូចពន្លឺរបស់ផ្លេកបន្ទោរ ពេលអ្នកដទៃសួរថា នេះជាអ្វី ? ក៏ក្លែតបាត់ទៅ ។ បទថា **សន្តម្បតិ** ប្រែថា ញាប់ញ័រដោយជុំវិញ ។ ពីរបទក្រៅនេះជាវេវចនៈរបស់បទដំបូងនោះឯង ដើម្បីនឹងសរុបសេចក្តី លោកទើបពោលពាក្យថា **អប្បមាណោ ច** ជាដើមទុកទៀត ។

**[៣៣]** បទថា **ចត្តារោ** ក្នុងប្រយោគថា **ចត្តារោ នំ ទេវបុត្តា ចតុទ្ទិសំ អារក្ខាយ ឧបគច្ឆន្តិ** នេះ លោកពោលសំដៅយកស្តេចមហារាជទាំង ៤ ។ ក៏ក្នុងម៉ឺនចក្រវាឡ រមែងមានស្តេចមហារាជ ៤ ម៉ឺននៅប្រចាំ ចែកគ្នានៅក្នុងចក្រវាឡនីមួយៗ ៤ អង្គ ។

បណ្តាមហារាជទាំងនោះ មហារាជក្នុងចក្រវាឡនេះ ទ្រង់កាន់ព្រះខាន់ស្តេចមកហើយ ចូលទៅកាន់បន្ទប់ដែលមានសិរី ដើម្បីនឹងរក្សាព្រះពោធិសត្វ ក្រៅពីនេះ ចែកគ្នាទៅដេញពួកយក្ខ មានបិសាចប្រឡាក់ធូលីជាដើម ដែលគេខាំងទុកឲ្យចៀសទៅ ហើយរក្សាតាំងពីទ្វារបន្ទប់ដរាបដល់ចក្រវាឡ ។ ការមកគាល់រក្សានេះ ដើម្បីប្រយោជន៍អ្វី ព្រោះរាប់ចាប់តាំងពីវេលាដែលជាកលលៈក្នុងខណៈបដិសន្ធិដល់ នឹងមានមារទាំងសែនកោដិ លើកក្តុំសិនេរុទាំងសែនកោដិ

មកដើម្បីធ្វើអន្តរាយដល់ព្រះពោធិសត្វ ឬព្រះមាតារបស់ព្រះពោធិសត្វ អន្តរាយទាំងពួង ក៏អន្តរធានទៅមិនមែនឬ ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងរឿងដែលភិក្ខុទេវទត្ត ធ្វើព្រះលោហិតឲ្យពុះពង ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលនឹងផ្តាច់ព្រះជន្មតថាគត ដោយសេចក្តីព្យាយាមរបស់អ្នកដទៃនោះ មិនមែនជាឋានៈ មិនមែនជាឱកាស ព្រោះព្រះតថាគតទាំងឡាយ នឹងមិនបរិនិព្វានដោយសេចក្តីព្យាយាមរបស់អ្នកដទៃ ម្នាលភិក្ខុទាំងឡាយពួកអ្នកចូរទៅនៅតាមកន្លែងដើម ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតទាំងឡាយមិនចាំបាច់ត្រូវមានការរក្សា ។ បើដូច្នោះ អន្តរាយនៃជីវិត រមែងមិនមានដល់ព្រះតថាគតទាំងនោះ ដោយសេចក្តីព្យាយាមរបស់អ្នកដទៃ ។ ពួកអមនុស្សអ្នកមានរូបវិកលគួរស្អប់ សត្វដែលមានរូបគួរខ្លាចក៏មាន សេចក្តីខ្លាច ឬសេចក្តីតក់ស្លុត នឹងគប្បីកើតដល់ព្រះមាតារបស់ព្រះពោធិសត្វបាន ព្រោះឃើញរូបឬស្តាប់សម្លេងរបស់អមនុស្សពួកណា ដើម្បីហាមអមនុស្សទាំងនោះ ទើបត្រូវដាក់ការរក្សា ។ មួយទៀត ស្តេចមហារាជទាំងនោះ មានសេចក្តីគោរពកើតឡើង ដោយតេជៈនៃបុណ្យបារមីរបស់ព្រះពោធិសត្វ ទាំងខ្លួនឯងក៏មានសេចក្តីគោរពយ៉ាងក្រៃលែង ទើបធ្វើយ៉ាងនេះ ។

សួរថា ក៏ស្តេចមហារាជទាំង ៤ ចូលទៅឈរខាងក្នុងបន្ទប់ហើយសម្តែងខ្លួនឲ្យប្រាកដដល់ព្រះមាតារបស់ព្រះពោធិសត្វ ឬមិនសម្តែង ។ ឆ្លើយថា មិនសម្តែងខ្លួនក្នុងវេលាដែលព្រះមាតារបស់ព្រះពោធិសត្វទ្រង់ធ្វើកិច្ច ដូចស្រង់ទឹក ប្រដាប់តាក់តែងកាយ និងសោយជាដើម តែនឹងសម្តែងក្នុងវេលាដែលព្រះអង្គចូលបន្ទប់ដ៏មានសិរី ហើយផ្ទុំលើក្រឡាបន្ទំ ។ ដែលឈ្មោះថា រូបកាយរបស់អមនុស្សទាំងឡាយ រមែងជាវត្ថុដែលគួរខ្លាចចំពោះមុខរបស់មនុស្សទាំងឡាយក្នុងវេលានោះក៏ពិត តែសម្រាប់ព្រះមាតារបស់ព្រះពោធិសត្វ កាលឃើញអមនុស្សទាំងនោះហើយ រមែងមិនខ្លាច ដោយអានុភាពនៃបុណ្យរបស់ព្រះនាងនិងព្រះឱរស ។ ព្រះនាងមានព្រះទ័យក្នុងអមនុស្សទាំងនោះ ដូចប្រធានមន្ទីរចូលទៅកាន់ព្រះរាជស្ថានទូទៅ ។

**[៣៤]** បទថា **បកតិយា សីលវតី** សេចក្តីថា ព្រះនាងទ្រង់ដល់ព្រមដោយសីល ដោយសភាពខ្លួនឯង ។ បានឮមកថា កាលព្រះពុទ្ធមិនទាន់ស្តេចឧប្បត្តិ មនុស្សទាំងឡាយ នាំគ្នាទៅសំពះអង្គុយប្រហោងសមាទានសីលក្នុងសម្នាក់តាបស និងបរិព្វាជកទាំងឡាយ ។ សូម្បីព្រះមាតាព្រះពោធិសត្វ ក៏សមាទានសីលក្នុងសម្នាក់នៃកាលទេវិលតាបស ។ តែកាលព្រះពោធិសត្វនៅ

ក្នុងព្រះគភ៌ ព្រះនាងមិនអាចប្រថាប់អង្គុយជិតបាទមូលរបស់អ្នកដទៃបាន សូម្បី សីលដែលព្រះនាងទ្រង់ប្រថាប់អង្គុយលើអាសនៈស្មើគ្នាទទួលទុក ក៏ជាពិធីការ ប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបពោលទុកដូច្នេះថា ព្រះមាតារបស់ព្រះពោ-ធិសត្វ បានសមាទានសីលដោយព្រះអង្គឯងតែម្យ៉ាង ។

[៣៥] បទថា *បុរិសេសុ* សេចក្តីថា ចិត្តដែលមានសេចក្តីប្រាថ្នាក្នុង បុរស រមែងមិនកើតក្នុងបុរសទាំងឡាយ រាប់តាំងពីព្រះបិតារបស់ព្រះពោធិសត្វ ។ ប្រការនេះ កើតឡើងដោយសេចក្តីគោរពក្នុងព្រះពោធិសត្វ មិនមែនកើតព្រោះ លះកិលេសបានហើយទេ ។ ក៏ជាងគំនូរទាំងឡាយ សូម្បីឆ្លាតវាងវៃ ក៏មិនអាច នឹងគូររូបព្រះមាតារបស់ព្រះពោធិសត្វចុះក្នុងផ្ទាំងគំនូរជាដើមបាន ។ នរណាៗ ទើបមិនអាចនិយាយបានថា សេចក្តីតម្រេក រមែងមិនកើតដល់បុរស ព្រោះ ឃើញរូបព្រះមាតាព្រះពោធិសត្វនោះ ម្យ៉ាងទៀត បើអ្នកមានចិត្តតម្រេក ប្រាថ្នា នឹងចូលទៅរកព្រះនាង នឹងឈានជើងទៅមិនរួច ដូចត្រូវគេចងទុកដោយច្រវាក់ ទិព្វ ។ ព្រោះដូច្នោះ លោកទើបពោលពាក្យជាដើមថា **អនតិក្កមនីយា** ដូច្នេះ ។

[៣៦] បទថា *បញ្ចន្នំ កាមគុណានំ* សេចក្តីថា ការហាមវត្ថុ ដោយ អំណាចនៃសេចក្តីស្រមើស្រមៃក្នុងបុរស លោកពោលទុកមុនហើយ ដោយបទ

ថា **កាមគុណូបសញ្ហិតំ** ។

ក្នុងទីនេះសម្តែងត្រឹមតែការបានចំពោះនូវអារម្មណ៍ ។ បានឮថា ក្នុងគ្រានោះ ព្រះរាជាដោយទូទៅជ្រាបដំណឹងថា ព្រះឱរសបែបនេះ បានបដិសន្ធិក្នុងព្រះគភ៌របស់ព្រះទេវី ទើបបញ្ជូនបណ្ណាការដែលជាទីតាំងនៃអារម្មណ៍របស់ទ្វារទាំង ៥ ដែលជាគ្រឿងប្រដាប់មានតម្លៃច្រើន និងគ្រឿងតន្ត្រីជាដើម ។ សម្រាប់ព្រះពោធិសត្វ និងព្រះមាតា រមែងមានលាភសក្ការៈរកកំណត់ប្រមាណមិនបាន ព្រោះច្រើនទៅដោយកុសលសម្ភារ ដែលទ្រង់បំពេញទុកហើយ ។

**[៣៧]** បទថា **អកិលន្តកាយា** សេចក្តីថា ស្ត្រីពួកដទៃ រមែងលំបាកដោយភារៈក្នុងការរក្សាគភ៌ ទាំងដៃជើងក៏ហើម យ៉ាងណា ព្រះនាងមិនមានសេចក្តីលំបាកយ៉ាងនោះដូចស្ត្រីទាំងនោះឡើយ ។ បទថា **តិរោ កុច្ឆិគតំ** ប្រែថា ប្រថាប់នៅខាងក្នុងព្រះឧទរ គឺ ផុតវេលាដែលជាកលលៈជាដើមទៅហើយ ទ្រង់ឃើញព្រះពោធិសត្វមានអង្គាវយវៈសម្បូរណ៍ មានឥន្ទ្រិយមិនសាបសូន្យ មិនទ្រុឌទ្រោម ។

សួរថា ទ្រង់មើលដើម្បីប្រយោជន៍អ្វី ។ ឆ្លើយថា ដើម្បីឲ្យនៅជាយ៉ាងសប្បាយ ។

ក៏ធម្មតា មាតាទាំងឡាយ នឹងអង្គុយ ឬដេកជាមួយបុត្រក៏ដោយ នឹងត្រូវសម្លឹងមើលបុត្រដើម្បីឲ្យនៅយ៉ាងសប្បាយថា យើងនឹងលើកដៃ និងជើងដែលឲ្យសំយ៉ុងចុះ ហើយឲ្យតាំងនៅដោយល្អយ៉ាងណា សូម្បីមាតារបស់ព្រះពោធិសត្វក៏ដូច្នោះ ទ្រង់សម្លឹងមើលព្រះពោធិសត្វ ដើម្បីនឹងឲ្យនៅយ៉ាងសប្បាយ ដោយព្រះតម្រិះថា ទុក្ខឯណា ដែលកើតដល់ក្មេងនៅក្នុងផ្ទៃ ក្នុងវេលាដែលម្តាយក្រោកឡើង ដើរទៅ បង្វិលខ្លួន និងអង្គុយជាដើមក្តី ក្នុងវេលាដែលម្តាយលេបអាហារដែលក្តៅត្រជាក់ ប្រៃ ល្វីង និងដែលហិរក្តី ទុក្ខនោះ មានដល់ព្រះឱរសរបស់យើងខ្លះឬហ្ន៎ ក៏ទ្រង់ឃើញព្រះពោធិសត្វអង្គុយចម្រើនសមាធិហើយ ។ ធម្មតាក្មេងដែលនៅក្នុងផ្ទៃពួកស្ត្រីដទៃ នឹងអង្គុយសង្កត់លើអាហារចាស់ ក្បាលទូលអាហារថ្មីនៃមាតា បែរខ្នងទៅខាងផ្ទៃម្តាយ បែរមុខទៅខាងឆ្អឹងខ្នង យកដៃទាំងពីរខាងឱបជង្គង់ផ្ចុប់នឹងចង្កា ដូចស្វាអង្គុយនៅក្នុងប្រហោងឈើវេលាភ្លៀងធ្លាក់ តែព្រះពោធិសត្វមិនជាដូច្នោះ ។

ក៏ព្រះអង្គទ្រង់គង់ផ្អែកនឹងឆ្អឹងខ្នងនៃមាតា ហើយចម្រើនសមាធិ បែរព្រះភក្ត្រទៅផ្លូវទិសបូព៌ា ដូចព្រះធម្មកថិកអង្គុយលើធម្មាសនៈ ។ ក៏កម្មដែលព្រះមាតារបស់ព្រះពោធិសត្វធ្វើទុកក្នុងកាលមុន រមែងញុំាងវត្ថុ (ទីតាំងនៃព្រះ-

គភ៌) របស់ព្រះនាងឲ្យបរិសុទ្ធិ កាលវត្ថុបរិសុទ្ធិ លក្ខណៈនៃព្រះធរីដ៏ផូរផង់ រមែងកើតឡើង គ្រានោះ ស្បែកក៏មិនអាចនឹងបិទបាំងព្រះពោធិសត្វដែលនៅក្នុងព្រះគភ៌បាន កាលសម្លឹងមើលនឹងប្រាកដដូចប្រថាប់ឈរខាងក្រៅ ។

ដើម្បីនឹងញ៉ាំងសេចក្ដីនោះឲ្យជាក់ច្បាស់ដោយឧបមា លោកទើបពោលពាក្យមានជាដើមថា **សេយ្យថាបិ** ព្រះពោធិសត្វដែលនៅខាងក្នុងព្រះគភ៌ រមែងមើលមិនឃើញព្រះមាតា ព្រោះចក្ខុវិញ្ញាណមិនកើតខាងក្នុងព្រះគភ៌ ។

**[៣៨]** បទថា **កាលំ ករោតិ** សេចក្ដីថា មិនមែនព្រះនាងសុគត ព្រោះហេតុកាលដែលព្រះអង្គទ្រង់ប្រសូតិទេ តែព្រោះអស់ព្រះជន្មាយុតែម្យ៉ាង ។ ពិតហើយ កន្លែងដែលព្រះពោធិសត្វប្រថាប់នៅ រមែងដូចជាកុដិក្នុងព្រះចេតិយ មិនគួរដល់សត្វពួកដទៃនឹងប្រើរួម និងអ្នកណាៗ ក៏មិនអាចនឹងផ្លាស់ប្ដូរព្រះមាតានៃព្រះពោធិសត្វ ហើយតែងតាំងស្ត្រីដទៃទុកក្នុងតំណែងព្រះអគ្គមហេសីបាន ហេតុដូចពោលមកត្រឹមតែប៉ុណ្ណោះឯង រមែងជាប្រមាណនៃអាយុរបស់ព្រះមាតាព្រះពោធិសត្វ ព្រោះដូច្នោះ ព្រះនាងទើបស្ដេចសុគតក្នុងវេលានោះ ។

សួរថា ព្រះនាងស្ដេចសុគតក្នុងថ្ងៃណា ។ ឆ្លើយថា ក្នុងមជ្ឈិមវ័យ ។ សេចក្ដីពិត ក្នុងបឋមវ័យ អត្តភាពរបស់សត្វទាំងឡាយ រមែងមានឆន្ទរាគៈ

ខ្វាំងក្លា ។ ព្រោះហេតុនោះ ស្ត្រីដែលតាំងគភ៌ក្នុងវេលានោះ រមែងមិនអាចនឹងរក្សាគភ៌នោះទុកបាន ។ គភ៌ រមែងមានរោគច្រើនណាស់ កាលកន្លងទៅនៅចំណែកទាំងពីរនៃមជ្ឈិមវ័យទៅហើយ វត្ថុ (ទីតាំងនៃគភ៌) រមែងបរិសុទ្ធិក្នុងចំណែកទី ៣ នៃវ័យ កាលវត្ថុបរិសុទ្ធិ ទារកដែលកើតក៏មិនមានរោគ ។ ព្រោះដូច្នោះ សូម្បីព្រះមាតារបស់ព្រះពោធិសត្វសោយសម្បត្តិក្នុងបឋមវ័យ ប្រសូតិក្នុងចំណែកទី ៣ នៃមជ្ឈិមវ័យ ស្តេចសុគតហើយ ដោយប្រការដូច្នេះ ។

**[៣៩]** *វា សត្ត* ក្នុងបទថា *នវ វា ទស វា* នេះ គប្បីជ្រាបថា ត្រូវរួមសូម្បីបទមានជាដើមយ៉ាងនេះថា ***សត្ត វា អដ្ឋ វា ឯកាទសវា ទ្វាទស វា*** ចូលមកដោយជាវិកប្ប ។ បណ្តាកំណត់ទាំងនោះ សត្វដែលនៅក្នុងគភ៌បាន ៧ ខែប្រសូត នឹងធ្ងន់ផុត តែក៏មិនអាចអត់ធន់ត្រជាក់ក្តៅបាន ដែលនៅក្នុងគភ៌បាន ៨ ខែប្រសូត ក៏ធ្ងន់មិនផុត ក្រៅពីនោះនឹងធ្ងន់ផុត ។ បទថា ***ឋិតាវ*** ប្រែថា ប្រថាប់ឈរហើយដោយពិត ។

សូម្បីព្រះនាងមហាមាយាទេវី ទ្រង់ព្រះតម្រិះថា យើងនឹងទៅកាន់ផ្ទះនៃត្រកូលព្រះញាតិរបស់យើង ហើយក្រាបទូលព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យប្រដាប់តាក់តែងផ្លូវដែលស្តេចនឹងទៅ តាំងពីក្រុងកបិលពស្តុ ដរាបដល់

ក្រុងទេវទហៈ ហើយឲ្យព្រះទេវីប្រថាប់លើគ្រែស្នែងមាស ។ ស្តេចសក្យៈអ្នកនៅក្នុងព្រះនគរទាំងអស់ ហែហមបូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម នាំព្រះទេវីស្តេចទៅហើយ ។ ព្រះនាងទតឃើញលុម្ពិនីសាលវនោទ្យាន មិនឆ្ងាយពីព្រះនគរទេវទហៈ កើតសេចក្តីប្រាថ្នាចង់ចូលទៅប្រពាតព្រះឧទ្យាន ទើបឲ្យសញ្ញាដល់ព្រះរាជា ។ ព្រះរាជាត្រាស់បង្គាប់ឲ្យប្រដាប់តាក់តែងព្រះឧទ្យាន ហើយឲ្យចាត់ការរក្សា ។ ពេលព្រះទេវីស្តេចចូលកាន់ព្រះឧទ្យាន ក៏មានព្រះកម្លាំងខ្សោយចុះ ។ គ្រានោះ ជនទាំងឡាយដឹងហេតុ ក៏យកព្រះសន្ទិយាទៅបិទបាំងក្រោមដើមសាលព្រឹក្សដែលជាមង្គល ថ្វាយព្រះនាង ។ ព្រះនាងស្តេចក៏ចូលទៅខាងក្នុងព្រះសន្ទិយា ហើយស្តេចប្រថាប់ឈរតោងមែកឈើសាលៈលំដាប់នោះ ព្រះនាងបានប្រសូតិព្រះឱរសក្នុងគ្រានោះឯង ។

**[៤១]** បទថា ***ទេវា បឋមំ បដិគ្គណ្ហន្តិ*** សេចក្តីថា ពួកព្រហ្មជាន់សុទ្ធាវាសទាំងឡាយជាខីណាស្រព នឹងទទួលមុន ។ ទទួលយ៉ាងណា អាចារ្យមួយពួកពោលថា ពួកព្រហ្មជាន់សុទ្ធាវាសនឹង ប្លែងភេទជាអ្នកបម្រើការ ថ្វាយការប្រសូតិ ។ ក៏លោកបដិសេធ ប្រការដែលជំទាស់នោះ ហើយពោលពាក្យអធិប្បាយទុកដូច្នេះ ។ វេលានោះ ព្រះមាតាព្រះពោធិសត្វ ទ្រង់ស្លៀកសំពត់

សុវណ្ណខចិត ទ្រង់ដណ្ដប់សំពត់ ២ ជាន់ ស្រដៀងក្អែកត្រី គ្របដល់បាតព្រះបាទប្រថាប់ឈរហើយ និងការប្រសូតិព្រះឱរសរបស់ព្រះនាងក៏ងាយ ដូចទឹកដែលហូរចេញចាកធម្មក្រក ខណៈនោះ ព្រហ្មជាន់សុទ្ធាវាសទាំងនោះ ចូលទៅដោយភេទរបស់ព្រហ្មតាមប្រក្រតី ហើយទ្រង់ទទួលព្រះឱរសដោយសំណាញ់មាសមុន ។ មនុស្សទាំងឡាយទទួលតពីព្រះហស្តរបស់ព្រហ្មទាំងនោះ ដោយសំពត់សាច់យ៉ាងល្អ ។ ដោយហេតុនោះ លោកទើបពោលថា ទេវតាទាំងឡាយទទួលមុន ពួកមនុស្សទទួលខាងក្រោយ ។

បទថា **ចត្តារោ នំ ទេវបុត្តា** សំដៅដល់ស្ដេចមហារាជទាំង ៤ ។

**[៤២]** បទថា **បដិគ្គហេត្វា** បានដល់ ទទួលដោយកម្រាលដែលធ្វើដោយស្បែកខ្លា ។ បទថា **មហេសក្ខោ** ប្រែថា ថាមានតេជៈច្រើន គឺ មានយសច្រើន អធិប្បាយថា សម្បូរណ៍ដោយលក្ខណៈ ។

**[៤៣]** បទថា **វិសុទ្ធោវ និក្ខមតិ** សេចក្ដីថា ធម្មតាសត្វពួកដទៃច្រើននឹងជាប់នៅក្នុងទ្វារប្រសូតិចេញ ព្រោះមានការចង្អៀត តែព្រះមាតាព្រះពោធិសត្វមិនជាយ៉ាងនោះ ។ អធិប្បាយថា ប្រសូតិងាយ មិនជាប់អ្វីឡើយ ។ បទថា **ឧទេន** ប្រែថា ដោយទឹក ។ បទថា **កេនចិ អសុចិនា** សេចក្ដីថា ធម្មតា សត្វ

ពួកដទៃនឹងមានខ្យល់កម្មជវាតបក់យកជើងឡើងទៅខាងលើ យកសីសៈចុះមក ខាងក្រោម កន្លងទ្វារប្រសូតិសោយទុក្ខយ៉ាងធ្ងន់ធ្ងរ ឧបមាដូចធ្លាក់ចុះទៅក្នុងជ្រោះដ៏ជ្រៅរយជួរបុរស ឬដូចដំរីដែលគេទាញចេញចាកប្រហោងកូនទនុក សត្វពួកដទៃ កាលប្រសូតិ ក៏ប្រលាក់ទៅដោយរបស់មិនស្អាតច្រើនប្រការ ទើបនឹងចេញបាន យ៉ាងណា ព្រះពោធិសត្វមិនជាដូច្នោះ ។ ព្រោះខ្យល់កម្មជវាតមិនអាចនឹងធ្វើព្រះពោធិសត្វឲ្យមានព្រះបាទឡើងខាងលើ ព្រះសិរសាចុះខាងក្រោមបាន ។ ព្រះអង្គទ្រង់សណ្តូកព្រះហស្ត និងព្រះបាទទាំងពីរ ហើយស្តេចប្រថាប់ឈរ ឧបមាដូចព្រះធម្មកថិកឈានចុះអំពីធម្មាសនៈ ឬដូចបុរសឈានចុះអំពីជណ្តើរ ដូច្នោះ មិនបានប្រលាក់របស់មិនស្អាត សូម្បីបន្តិចបន្តួច នៅពេលស្ថិតនៅក្នុងព្រះគភ៌របស់ព្រះមាតាឡើយ ហើយទ្រង់ប្រសូតិ ។

**[៤៤]** បទថា *ឧទកស្ស ធារា* ប្រែថា ខ្សែទឹក ។ ក្នុងធារទឹកទាំងនោះ ធារទឹកត្រជាក់ធ្លាក់ចុះក្នុងផ្តាំងមាស ធារទឹកក្តៅធ្លាក់ចុះក្នុងផ្តាំងប្រាក់ ។ម្យ៉ាងទៀត លោកពោលសេចក្តីប្រការនេះទុក ដើម្បីនឹងសម្តែងថា ទឹកផឹក ទឹកប្រើរបស់ស្តេចទាំងពីរព្រះអង្គ មិនលាយដោយរបស់មិនស្អាតណាៗ លើផែនដី និងទឹកសម្រាប់លេង ក៏មិនសាធារណ៍ទូទៅដល់ពួកមនុស្សដទៃ ។ ក៏ទឹកដទៃដែលនឹង

គប្បីនាំមកដោយថ្នាំងមាស ថ្នាំងប្រាក់ក្តី ទឹកដែលនៅក្នុងស្រះបោក្ខរណីឈ្មោះ ហង្សវដ្តកៈជាដើមក្តី រមែងមានមិនកំណត់ ។

**[៤៥]** បទថា ***សម្បតិជាតោ*** ប្រែថា ប្រសូតិហើយត្រឹមតែមួយភ្លែត ។ ក៏ក្នុងព្រះបាលី លោកសម្តែងទុកថា ព្រះពោធិសត្វ ខណៈដែលប្រសូតិចាក ព្រះគភ៌ព្រះមាតា ក៏ប្រថាប់ព្រះយុគលបាទដ៏ស្មើចុះលើផែនដី តែមិនគួរយល់ យ៉ាងនោះ ។ សេចក្តីពិត ពេលព្រះពោធិសត្វស្តេចប្រសូតិ ព្រហ្មទាំងឡាយ ក៏យកសំណាញ់មាសទទួលទុកមុន ស្តេចមហារាជទាំង ៤ ទទួលតពីព្រះហស្ត របស់ស្តេចមហាព្រហ្មទាំងនោះ ដោយកម្រាលដែលគេធ្វើដោយស្បែកខ្លា ដែល មានសម្ផស្សដ៏ទន់ជាទីសប្បាយ ដែលសន្មតិគ្នាថា ជាមង្គល មនុស្សទាំងឡាយ ទើបទទួលតពីព្រះហស្តរបស់ស្តេចមហារាជទាំងនោះ ដោយឈ្នួត(មកុដរាជ) ដ៏ ប្រសើរ ពេលផុតអំពីដៃមនុស្ស ក៏ប្រថាប់ឈរលើផែនដី ។

បទថា ***សេតម្ហិ ឆត្តេ អនុហីរមានេ*** គឺ កាលទេវបុត្រកាន់ស្វេតឆត្រ ដែលជាទិព្វ សូម្បីគ្រឿងរាជកកុធភ័ណ្ឌទាំង ៥ មានព្រះខាន់ជាដើម ដែលជា បរិវាររបស់ឆត្រ មកហើយក្នុងទីនេះដូចគ្នា ។ តែក្នុងព្រះបាលី ពោលត្រឹមតែ ឆត្រតែម្យ៉ាង ដូចព្រះរាជាដែលគេបាំងឆត្រថ្វាយ ក្នុងវេលាស្តេចព្រះរាជដំណើរ ។

ក្នុងរាជកកុធភ័ណ្ឌទាំង ៥ ទាំងនោះ ប្រាកដតែឆ័ត្រប៉ុណ្ណោះ មិនប្រាកដអ្នកកាន់ ៗ ព្រះខាន់ ផ្លិតស្លឹកត្នោត ផ្លិតកន្ទុយសត្វក្ងោក ផ្លិតវាលវិជនី មកុដ ក៏ប្រាកដដូចគ្នា ៗ មិនប្រាកដអ្នកកាន់វត្ថុទាំងនោះ ៗ ន័យថា ទេវតាទាំងឡាយមិនប្រាកដខ្លួន កាន់គ្រឿងកកុធភ័ណ្ឌទាំងនោះទុកគ្រប់យ៉ាង ៗ សមពិតដូចពាក្យដែលលោកពោលទុកថា

*ទេវតាទាំងឡាយកាន់ឆ័ត្រ មានមណ្ឌលទាំងពាន់ មានកាំមិន*

*តិច នៅកណ្ដាលអាកាស ផ្លិតដែលមានដងជាវិការនៃមាស*

*ក៏ឃ្លាតកន្លងទៅ តែអ្នកកាន់ផ្លិត និងឆត្រមិនប្រាកដ ៗ*

បទថា សព្វា ច ទិសា នេះ លោកពោលដល់ការត្រួតមើលទិសទាំងពួង ដូចជាការក្រឡេកមើលនូវទិសទាំងពួងរបស់មហាបុរស ដែលកំពុងព្រះបាទទៅ ៧ ជំហាន តែប្រការនេះមិនគួរឃើញយ៉ាងនោះ ៗ ពិតហើយ ព្រះមហាសត្វផុតពីដៃរបស់មនុស្សទាំងឡាយហើយ ទ្រង់ក្រឡេកមើលទិសបូព៌ា ៗ ចក្រវាឡច្រើនពាន់បានប្រាកដជាទីទួលតែមួយដូចគ្នា ៗ ទេវតា និងមនុស្សទាំងឡាយក្នុងចក្រវាឡទាំងនោះ នាំគ្នាបូជាដោយគ្រឿងសក្ការៈ មានរបស់ក្រអូប និងផ្កាឈើជាដើម ហើយនិយាយថា បពិត្រព្រះមហាបុរស ក្នុងលោកនេះមិនមានបុគ្គល

ដែលស្មើនឹងព្រះអង្គបាន ទីណានឹងមានបុគ្គលប្រសើរជាង ទៅបានហ្ន៎ ។ ព្រះមហាសត្វទ្រង់ត្រួតមើលទិសទាំង ១០ គឺ ទិសធំ ៤ ទិសតូច ៤ ទិសខាងក្រោម ១ ទិសខាងលើ ១ យ៉ាងនេះ ។ មើលមិនឃើញអ្នកស្មើដោយព្រះអង្គ ទ្រង់កំណត់ថា នេះជាទិសឧត្តរ ហើយស្តេចឈានព្រះបាទទៅ ៧ ជំហាន ។ ក្នុងរឿងនេះ គប្បីឃើញសេចក្តីដូចពណ៌នាយ៉ាងនេះ ។ បទថា **អាសភី** ប្រែថា ខ្ពស់បំផុត ។ បទថា **អគ្គោ** ប្រែថា ប្រសើរបំផុត គឺ ចម្រើនបំផុត បានដល់ប្រសើរជាងបុគ្គលទាំងអស់ ដោយគុណទាំងឡាយ ពីរបទក្រៅនេះជាវេវចនៈរបស់បទថា **អគ្គោ** នុ៎ះឯង ។ លោកព្យាករណ៍ព្រះអរហត្តដែលនឹងគប្បីសម្រេចក្នុងអត្តភាពនេះ ដោយបទទាំងពីរថា **អយមន្តិមា ជាតិ នត្ថិ ទានិបុនព្ភវោ** ។

ក៏ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ប្រការដែលព្រះអង្គប្រថាប់ឈរលើផែនដី ដោយព្រះបាទដ៏ស្មើ ជាបុព្វនិមិត្តនៃការបានចំពោះនូវឥទ្ធិបាទ ៤ ប្រការដែលព្រះអង្គទ្រង់បែរព្រះភ័ក្ត្រទៅទិសឧត្តរ ជាបុព្វនិមិត្តនៃការដែលស្តេចទៅយ៉ាងធំក្រៃលែងលើមហាជនទាំងពួង ។ ប្រការដែលព្រះអង្គទ្រង់ព្រះដំណើរទៅបាន ៧ ជំហាន ជាបុព្វនិមិត្តនៃការបានចំពោះនូវរតនៈ គឺ ពោជ្ឈង្គៈ ៧ ។ ប្រការដែលគេបាំងស្វេតឆ័ត្រជា

ទិព្វ ជាបុព្វនិមិត្តនៃការបានចំពោះនូវចក្ខុ គឺ វិមុត្តិ ។ រាជកកុធភណ្ឌទាំង ៥ ជាបុព្វនិមិត្តនៃការរួចផុតដោយវិមុត្តិ ៥ ប្រការ ។ ប្រការដែលទ្រង់សម្លឹងមើលទិស ជាបុព្វនិមិត្តនៃការបានចំពោះនូវអនាវរណញ្ញាណ ។ ប្រការដែលទ្រង់ថ្លែងអាសភិវាចា ជាបុព្វនិមិត្តនៃការប្រកាសធម្មចក្កដែលនរណាៗ ឲ្យប្រព្រឹត្តទៅមិនបាន ។ សីហនាទដែលប្រកាសថា **អយមន្តិមា ជាតិ** (ជាតិនេះជាជាតិចុងក្រោយ) គប្បីជ្រាបថា ជាបុព្វនិមិត្តនៃការបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។ វារៈផ្សេងៗ ទាំងនេះ មកហើយក្នុងព្រះបាលី ។ តែសម្ពហុលវារមិនទាន់មានមក ទើបត្រូវសម្ដែងផងដែរ ។

ក៏ក្នុងថ្ងៃដែលព្រះមហាបុរសប្រសូតិ មុឺនលោកធាតុក្រើកញាប់ញ័រ ទេវតាទាំងឡាយក្នុងមុឺនលោកធាតុក៏មកប្រជុំគ្នាហើយ ក្នុងចក្រវាឡតែមួយ ។ ទេវតាទាំងឡាយទទួលមុន ពួកមនុស្សទទួលខាងក្រោយ ។ ពិណទាំងឡាយដែលគេធ្វើដោយសរសៃអំបោះ និងស្គរទាំងឡាយដែលគេដាសដោយស្បែក មិនមានអ្នកណាៗ ប្រគំឡើង ក៏ឮឡើងឯង ។ ត្រៀងចង មានខ្សែ និងច្រវាក់ខ្ទោះជាដើមនៃមនុស្សទាំងឡាយ ដាច់ចេញជាកំណាត់តូចកំណាត់ធំ ។ រោគគ្រប់យ៉ាងក៏បាត់អស់ ដូចច្រេះពណ៌ក្រហមដែលគេខាស់ចេញដោយរបស់ជូរ ។

អ្នកដែលខ្វាក់ពីកំណើតក៏ឃើញរូបផ្សេងៗ បាន ។ អ្នកថ្លង់ពីកំណើតក៏បានឮសម្លេង ។ មនុស្សពិការអស់កម្លាំង ក៏ត្រឡប់សម្បូរណ៍ដោយកម្លាំង ។ មនុស្សធ្ងួតពីកំណើត ក៏ត្រឡប់ជាជា ។ ទូកដែលត្រាច់ទៅកន្លែងផ្សេងៗ ក៏ដល់កំពង់ដោយសប្បាយ ។ រតនៈទាំងឡាយដែលនៅក្នុងអាកាស និងលើផែនដី ក៏បានបញ្ចេញពន្លឺឡើងឯង ។ អ្នកដែលជាសត្រូវត្រឡប់បានមេត្តាចិត្ត ។ ភ្លើងក្នុងអវិចីនរកក៏រលត់ ។ ពន្លឺក៏កើតឡើងក្នុងលោកន្តរនរក ។ ទឹកក្នុងទន្លេទាំងឡាយក៏មិនហូរ ។ ទាំងទឹកក្នុងមហាសមុទ្រ បានក្លាយជាទឹកផ្អែម ។ ភ័យអំពីខ្យល់ព្យុះក៏មិនមាន សត្វដែលហើរទៅក្នុងអាកាស និងនៅតាមដើមឈើ ភ្នំ ក៏ធ្លាក់ចុះមកលើផែនដី ។ ព្រះចន្ទក៏រុងរឿងយ៉ាងក្រៃលែង ។ ព្រះអាទិត្យក៏មិនក្តៅមិនត្រជាក់ ប្រាសចាកមន្ទិល ដល់ព្រមដោយឧតុ ។ ទេវតាទាំងឡាយឈរត្រង់ទ្វារវិមានរៀងៗ ខ្លួន នាំគ្នាលេងមហាកីឡាជាដើម មានទះដៃហ៊ោកញ្ជ្រៀវ និងលើកសំពត់ ។ មហាមេឃតាំងឡើងពីទិសទាំង ៤ ញ៉ាំងភ្លៀងឲ្យធ្លាក់ ។ សេចក្តីស្រេកឃ្លាន និងសេចក្តីក្តៅក្រហាយមិនបៀតបៀនដល់មហាជន ។ ទ្វារបង្អួចក៏របើកឯង ។ ដើមឈើដែលនឹងមានផ្កាមានផ្លែ ក៏បានចេញផ្កាចេញផ្លែស្គុះស្គាយ ។ ទូទៅទាំងម៉ឺនលោកធាតុ បានមានហាក់បីដូចជាទង់ផ្កាឈើតែមួយ

រួមគ្នា ។

សូម្បីក្នុងប្រការដែលគួរអស្ចារ្យនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

សេចក្តីញាប់ញ័រនៃម៉ឺនលោកធាតុ ជាបុព្វនិមិត្តនៃការបានចំពោះនូវព្រះសព្វញ្ញុតញ្ញាណរបស់ព្រះមហាបុរស ។ ប្រការទេវតាទាំងឡាយមកប្រជុំគ្នាក្នុងចក្រវាឡតែមួយ ជាបុព្វនិមិត្តនៃការរួមប្រជុំទទួលព្រះសទ្ធម្មក្នុងគ្រាតែមួយជាមួយគ្នា ក្នុងវេលាដែលទ្រង់ប្រកាសធម្មចក្រ ។ ប្រការដែលទេវតាទាំងឡាយទទួលព្រះពោធិសត្វមុន ជាបុព្វនិមិត្តនៃការបានចំពោះនូវរូបាវចរឈានទាំង ៤ ។ ប្រការមនុស្សទាំងឡាយទទួលខាងក្រោយ ជាបុព្វនិមិត្តនៃការបានចំពោះនូវអរូបាវចរឈានទាំង ៤ ។ ប្រការដែលពិណដែលគេធ្វើដោយសរសៃអំបោះ ព្រះឡើងឯង ជាបុព្វនិមិត្តនៃការបានចំពោះនូវអនុបុព្វវិហារធម៌ ។ ប្រការដែលស្គរ ដែលគេជាសដោយស្បែកព្រះឯង ជាបុព្វនិមិត្តនៃការទូន្មានដោយធម្មភេរីដែលធំក្រៃលែង ។ ប្រការដែលគ្រឿងចង មានខ្សែ និងច្រវាក់ ខ្នោះជាដើមដាច់ចេញពីគ្នា ជាបុព្វនិមិត្តនៃការកាត់នូវអស្មិមានះបានយ៉ាងដាច់ខាត ។ ប្រការដែលអ្នកទាំងឡាយជាអំពីរោគផ្សេងៗ ជាបុព្វនិមិត្តនៃការប្រាសចាកទៅនៃកិលេសទាំងពួង ។ ប្រការមនុស្សខ្វាក់ពីកំណើតឃើញរូបបាន ជាបុព្វនិមិត្តនៃការបាន

ចំពោះនូវទិព្វចក្ខុ ។ ប្រការដែលអ្នកថ្ងន់ពីកំណើតបានឮសំឡេង ជាបុព្វនិមិត្ត នៃការបានចំពោះនូវទិព្វសោតធាតុ ។ ប្រការដែលមនុស្សពិការអស់កម្លាំង ក៏សម្បូរណ៍ដោយកម្លាំង ជាបុព្វនិមិត្តនៃការសម្រេចនូវឥទ្ធិបាទទាំង ៤ ។ ប្រការដែលមនុស្សខ្វាក់ត្រឡប់បានសតិ ជាបុព្វនិមិត្តនៃការបានចំពោះនូវសតិប្បដ្ឋាន ៤ ។ ប្រការដែលទូកទាំងឡាយដែលត្រាច់ចេញទៅដល់កំពង់ដោយសប្បាយ ជាបុព្វនិមិត្តនៃការសម្រេចបដិសម្ភិទា ៤ ។ ប្រការដែលរតនៈទាំងឡាយភ្លឺឯង ជាបុព្វនិមិត្តនៃពន្លឺរបស់ព្រះធម៌ ដែលព្រះអង្គទ្រង់សម្តែងដល់សត្វលោក ។ ប្រការដែលសត្រូវទាំងឡាយត្រឡប់បានមេត្តាចិត្ត ជាបុព្វនិមិត្តនៃការបានចំពោះនូវព្រហ្មវិហារ ៤ ។ ប្រការដែលភ្លើងក្នុងនរកអវិចីរលត់ ជាបុព្វនិមិត្តនៃការរលត់ភ្លើង ១១ កង ។ ប្រការដែលលោកន្តរនរកមានពន្លឺ ជាបុព្វនិមិត្តនៃការដែលព្រះអង្គទ្រង់កម្ចាត់សេចក្តីងងឹត គឺ អវិជ្ជា ហើយទ្រង់ឃើញពន្លឺបានដោយព្រះញាណ ។ ប្រការដែលទឹករបស់មហាសមុទ្រមានរសផ្អែម ជាបុព្វនិមិត្តនៃសេចក្តីដែលព្រះធម៌មានរសតែមួយ ។ ប្រការដែលមិនកើតវាតភ័យ ជាបុព្វ-និមិត្តនៃការដែលពុទ្ធបរិស័ទមិនបែកគ្នាដោយអំណាចទិដ្ឋិ ៦២ ។ ប្រការដែលសត្វទាំងឡាយធ្លាក់ចុះកាន់ផែនដី ជាបុព្វនិមិត្តដែលមហាជនស្តាប់ពាក្យប្រៀន

ប្រដៅហើយដល់សរណៈដោយជីវិត ។ ប្រការដែលព្រះចន្ទល្អរុងរឿងក្រៃលែង ជាបុព្វនិមិត្តនៃមហាជនពេញចិត្តក្នុងព្រះធម៌ ។ ប្រការដែលព្រះអាទិត្យមិនក្តៅ មិនត្រជាក់ឲ្យដល់ព្រមដោយឧតុ ជាបុព្វនិមិត្តនៃមហាជនដល់សេចក្តីសុខកាយ សុខចិត្ត ។ ប្រការដែលទេវតាទាំងឡាយលេងកីឡា មានការទះដៃជាដើមត្រង់ ទ្វារវិមាន ជាបុព្វនិមិត្តនៃការដែលព្រះមហាសត្វ សម្រេចដល់ភាពជាព្រះពុទ្ធ ហើយទ្រង់បន្លឺឧទាន ។ ប្រការដែលមហាមេឃទាំង ៤ ទិស ញុំាងភ្លៀងឲ្យ ធ្លាក់ ជាបុព្វនិមិត្តនៃការដែលខ្សែទឹក គឺ ព្រះធម៌ ធ្លាក់ចុះជាច្រើន ។ ប្រការ ដែលមនុស្សទាំងឡាយមិនត្រូវសេចក្តីស្រេកឃ្លានបៀតបៀន ជាបុព្វនិមិត្តនៃ ការបានចំពោះនូវអមតធម៌ គឺ កាយគតាសតិ ។ ប្រការដែលមនុស្សទាំងឡាយ មិនត្រូវសេចក្តីក្តៅក្រហាយបៀតបៀន ជាបុព្វនិមិត្តនៃការដែលពុទ្ធបរិស័ទដល់ សេចក្តីសុខហើយដោយវិមុត្តិសុខ ។ ប្រការដែលទ្វារបង្អួចទាំងឡាយរបើកឯង ជាបុព្វនិមិត្តនៃការបើកទ្វារអដ្ឋង្គិកមគ្គ ។ ប្រការដែលដើមឈើទាំងឡាយចេញ ផ្លែផ្កា ជាបុព្វនិមិត្តនៃព្រះធម៌ដែលរីកដោយផ្កា គឺ វិមុត្តិ និងបរិបូរស្គម្បីដោយ សាមញ្ញផល ។ ប្រការដែលមឺននៃលោកធាតុមានទង់ ជារបៀបតែម្យ៉ាងដូចគ្នា គប្បីជ្រាបថា ជាបុព្វនិមិត្តនៃការដែលពុទ្ធបរិស័ទមានទង់របស់ព្រះអរិយៈ ជា

កម្រងផ្កា ។ នេះឈ្មោះសម្ពហុលវារៈ ។

ក្នុងសម្ពហុលវារៈនេះ មានបុគ្គលជាច្រើនសួរជាបញ្ហាថា ក្នុងវេលាដែលមហាបុរសជាន់លើផែនដី ស្តេចព្រះដំណើរបែរមុខទៅទិសឧត្តរ ហើយទ្រង់បន្លឺអាសភិវាចានោះ ទ្រង់ប្រថាប់ឈរលើផែនដី ឬនៅក្នុងអាកាស ប្រាកដព្រះអង្គ ឬមិនប្រាកដ មិនស្លៀកសំពត់ ឬថា ប្រដាប់តាក់តែងហើយយ៉ាងល្អជាកម្លោះ ឬក៏ចាស់ សូម្បីខាងក្រោយក៏គង់មានសភាពដូច្នោះ ឬជាក្មេងតូច ។ ក៏គ្រាតមកខាងក្រោយព្រះចូឡាភយត្ថេរៈ អ្នកទ្រទ្រង់ព្រះត្រៃបិដក បានវិសជ្ជនាបញ្ហាប្រការនេះទុកហើយ ក្នុងទីប្រជុំក្នុងលោហៈប្រាសាទ ។ បានឮថា ក្នុងសេចក្តីនេះ ព្រះថេរៈពោលដល់រឿងរ៉ាវទុកជាច្រើន ដោយជានិយតវាទ បុព្វេកតកម្មវាទ និងឥស្សរនិម្មានវាទ ក្នុងពេលចុងក្រោយបានព្យាករណ៍ទុកយ៉ាងនេះថា ព្រះមហាបុរស ឈរលើផែនដី ហើយបានប្រាកដដល់មហាជន ដូចស្តេចទៅក្នុងអាកាស និងស្តេចទៅមានអ្នកឃើញ តែបានប្រាកដដល់មហាជនដូចជាមើលមិនឃើញ ។ មិនមានសំពត់ស្លៀកស្តេចទៅ តែប្រាកដដល់មហាជនដូចប្រដាប់តាក់តែងទុកហើយដោយល្អ ។ ទាំងដែលនៅជាក្មេង តែបានប្រាកដដល់មហាជនដូចមានព្រះជន្មាយុ ១៦ វស្សា ។ តែក្នុងខាងក្រោយ គង់ជាក្មេងតូច

ធម្មតា មិនបានដូចដែលប្រាកដ ។ និងកាលព្រះថេរៈពោលចង្អុលបង្ហាញយ៉ាង នេះហើយ បរិស័ទទាំងឡាយរបស់លោកក៏ពេញចិត្ត ដោយពោលថា លោកដ៏ចម្រើន ព្រះថេរៈពោលដោះស្រាយបញ្ហាបានជាក់ច្បាស់ដូចព្រះពុទ្ធនោះឯង ។ លោកន្តរិកវាទៈ មានន័យដូចពោលហើយនុ៎ះឯង ។ បទថា **វិទិតា** ប្រែថា ប្រាកដហើយ ។ ពិតហើយ ព្រះសាវកទាំងឡាយ រមែងមិនអាចនឹងរកចន្លោះផ្លូវពិចារណាសង្ខារដែលជាចំណែកអតីត ក្នុងខណៈដែលមិនមានឱកាសដូចជាវេលាឆ្លូតទឹក លាងមុខ ទំពារ និងផឹកជាដើមបាន នឹងពិចារណាបានចំពោះកាលមានឱកាសប៉ុណ្ណោះ យ៉ាងណា ព្រះពុទ្ធទាំងឡាយមិនដូច្នោះ ។

**[៤៧]** ក៏ព្រះពុទ្ធទាំងឡាយ ទ្រង់ពិចារណាសង្ខារដែលកន្លងទៅហើយ ខាងក្នុង ៧ ថ្ងៃបាន តាំងពីទ្រង់លើកឡើងកាន់ព្រះត្រៃលក្ខណ៍ហើយ ទ្រង់រមែងចង្អុលបង្ហាញបាន ដែលឈ្មោះថា ធម៌ដែលមិនជាក់ច្បាស់ដល់ព្រះពុទ្ធទាំងនោះ មិនមានឡើយ ព្រោះដូច្នោះ លោកទើបពោលថា **វិទិតា** ទ្រង់ដឹងច្បាស់ហើយ ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយទាំងនោះឯង ។

ចប់អដ្ឋកថា អច្ឆរិយព្ភូតសូត្រ ទី ៣

# អ ដ្ឋ ក ថា

## ពក្កុលសូត្រទី ៤

[៤៨] *ពក្កុលសូត្រ មានបទចាប់ផ្តើមថា* ***ឯវម្មេ សុតំ*** *ខ្ញុំបានស្តាប់មក យ៉ាងនេះ ៖*

*បណ្តាបទទាំងនោះ បទថា* ***ពក្កុលោ*** *មានអធិប្បាយថា គួរទឹងពោលពាក្យជាដើមថា* ***ទ្វាវីសតិ ទ្វត្តឹស*** *អ្នកទាំងឡាយត្រឡប់ជាពោលថា* ***ពាវីសតិ ពត្តឹស*** *ដូច្នេះជាដើម យ៉ាងណា បទនេះក៏ដូច្នោះដែរ គឺ កាលគួរទឹងពោលថា* ***ទ្វិក្កុលោ*** *ឬ* ***ទ្វក្កុលោ*** *ត្រឡប់ជាពោលថា* ***ពក្កុលោ*** *។*

*ក៏ព្រះថេរៈនោះ មានត្រកូលដល់ទៅពីរត្រកូល ។*

*បានឮមកថា លោកចុតិអំពីទេវលោក កើតក្នុងត្រកូលមហាសេដ្ឋី ក្នុងនគរឈ្មោះកោសម្ពី ។ ក្នុងថ្ងៃទី ៥ ពួកទាសីនាំលោកទៅផ្ងូតទឹក ហើយចុះលេងក្នុងទន្លេគង្គា កាលពួកទាសីកំពុងឲ្យទារកលេងទឹក ត្រីមួយក្បាលឃើញទារកសម្គាល់ថា ជាអាហារ ទើបពាំក្មេងទៅ ។ ពួកទាសីក៏ចោលក្មេង គេចចៀសទៅ ត្រីលេបទារកនោះ ជម្ងឺតាសត្វមានបុណ្យមិនក្តៅក្រហាយឡើយ ។*

គេដូចជាបានចូលទៅកាន់បន្ទប់ដេក ហើយដេកលក់ទៅ ។ ដោយតេជៈនៃទារក ត្រីមានសភាពដូចលេបក្បៀងដែលក្តៅចូលទៅ ត្រូវសេចក្តីក្តៅដុតរោល មានកម្លាំងហែលទៅបានត្រឹមតែ ៣០ យោជន៍ ហើយចូលទៅជាប់សំណាញ់របស់ព្រានទេសាទក្រុងពារាណសី ធម្មតាត្រីធំដែលជាប់សំណាញ់ ក៏ត្រូវប្រហារឲ្យស្លាប់ តែដោយតេជៈនៃទារក ត្រីនេះពេលគេនាំចេញចាកសំណាញ់ ក៏ស្លាប់ភ្លាម ។ និងធម្មតាព្រានទេសាទ បានត្រីធំៗ ហើយ រមែងពុះចេញជាចំណែកដើម្បីលក់ ។ តែដោយអានុភាពរបស់ទារក ព្រានទេសាទមិនទាន់ពុះត្រីនោះ ប្រើអម្រែករែកទៅទាំងមូល ស្រែកប្រកាសទូទាំងក្រុងថា នឹងលក់តម្លៃមួយពាន់ អ្នកណាៗ ក៏មិនទិញ ។

ក៏ក្នុងក្រុងនោះ មានត្រកូលសេដ្ឋីមានសម្បត្តិ ៨០ កោដិ មិនមានបុត្រនៅក្នុងត្រកូល កាលដល់ទ្វារផ្ទះសេដ្ឋីនោះ ពេលគេសួរថា នឹងលក់តម្លៃប៉ុន្មាន ។ ក៏ត្រឡប់ឆ្លើយថា លក់មួយកហាបណៈ ។ គេឲ្យប្រាក់មួយកហាបណៈ ហើយទិញយក ។ ឯភរិយាលោកសេដ្ឋីក្នុងថ្ងៃដទៃៗ មិនចូលចិត្តធ្វើត្រី តែក្នុងថ្ងៃនោះ ដាក់ត្រីទុកលើជ្រុញ ហើយធ្វើត្រីដោយដៃខ្លួនឯងតែម្តង ។ ក៏ធម្មតា ត្រីត្រូវវះត្រង់ពោះ ។ តែនាងវះពីខាងខ្នង ឃើញទារកសម្បុរដូចមាសក្នុងពោះត្រី

ស្រែកលាន់ឮថា យើងបានបុត្រក្នុងពោះត្រីហើយ ហើយពទារកតម្រង់ទៅកាន់សម្នាក់របស់ស្វាមី លោកសេដ្ឋីឲ្យគេវាយស្គរប្រកាសដំណឹងទៅទូទាំងក្រុងក្លាមនោះឯង ហើយពទារកតម្រង់ទៅកាន់ព្រះរាជដំណាក់ ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះករុណាបានទារកក្នុងពោះត្រី ខ្ញុំព្រះករុណានឹងធ្វើដូចម្តេច ។ ព្រះរាជាត្រាស់ថា ទារកដែលនៅក្នុងពោះត្រីរួចផុតភ័យនេះ ជាអ្នកមានបុណ្យ លោកចូរចិញ្ចឹមចុះ ។ ត្រកូលក្រៅនេះ បានស្តាប់ដំណឹងថា ក្នុងព្រះនគរពារាណសីត្រកូលសេដ្ឋីមួយបានទារកក្នុងពោះត្រី ។ ពួកគេទើបនាំគ្នាទៅក្នុងក្រុងនោះខណៈនោះមាតារបស់ទារកឃើញគេកំពុងតែងខ្លួនឲ្យទារក ហើយឲ្យលេង ទើបដើរចូលទៅដោយគិតថា ក្មេងនេះគួរស្រឡាញ់ពិតហ្ន៎ ហើយប្រាប់ការប្រព្រឹត្តទៅផ្សេងៗ ។

ស្ត្រីក្រៅពីនេះនិយាយថា ក្មេងនេះជាកូនយើង ។

ស្ត្រីនោះ សួរថា នាងបានមកពីណា ។

ស្ត្រីក្រៅនេះនិយាយថា យើងបានពីក្នុងពោះត្រី ។

ស្ត្រីនោះទើបនិយាយថា ក្មេងនេះមិនមែនកូនរបស់នាងទេ ជាកូនរបស់យើង ។

ស្ត្រីក្រៅនេះសួរថា នាងបានពីទីណា ។

ស្ត្រីនោះ ជំណាលថា យើងពផ្ទៃក្មេងនេះមកដល់ ១០ ខែ គ្រានោះ ត្រីបានលេបក្មេងដែលពួកទាសីកំពុងឲ្យលេងទឹក ។

ស្ត្រីក្រៅនេះ ទើបជំទាស់ថា កូនរបស់នាងប្រហែលជាត្រីដទៃលេបទេ តែក្មេងម្នាក់នេះខ្ញុំបានពីក្នុងពោះត្រី ។ ទាំងពីរត្រកូល ទើបនាំគ្នាទៅកាន់ព្រះរាជជំណាក់ ។

ព្រះរាជាត្រាស់ថា ស្ត្រីម្នាក់នេះ អ្នកណាៗ មិនអាចនឹងបដិសេធបានថា មិនមែនមាតា ព្រោះតាំងផ្ទៃមកអស់ ១០ ខែ សូម្បីពួកព្រានទេសាទដែលចាប់ត្រីបាន ក៏បានធ្វើការទិញលក់ជាដើម ស្រេចអស់ទៅហើយ ទើបអស់សិទ្ធិ ព្រោះដូច្នោះ សូម្បីស្ត្រីម្នាក់នេះ ក៏បដិសេធមិនបានថា មិនមែនមាតា ព្រោះបានក្មេងក្នុងពោះត្រី សូមអ្នកទាំងពីរត្រកូលចូរចិញ្ចឹមរក្សាក្មេងរួមគ្នាចុះ ។ សេដ្ឋីទាំងពីរត្រកូល ក៏ចិញ្ចឹមរក្សាក្មេងរួមគ្នាទៅ កាលក្មេងចម្រើនវ័យហើយ ត្រកូលទាំងពីរក៏បានឲ្យគេសាងប្រាសាទទុកក្នុងនគរទាំងពីរ ហើយឲ្យបម្រើដោយពួកស្រីរបាំ ។ គេនៅក្នុងនគរមួយ ៤ ខែ ។ កាលគេនៅក្នុងនគរមួយគ្រប់ ៤ ខែហើយ ត្រកូលទាំងពីរឲ្យជាងសាងមណ្ឌបទុកក្នុងទូក ដែលតជាប់គ្នា ហើយឲ្យ

គេនៅក្នុងទូកនោះ ព្រមដោយស្រីវបាំទាំងឡាយ ។ គេសោយសម្បត្តិជាទីរីករាយ ធ្វើដំណើរទៅក្រុងមួយទៀត ។ ស្រីរបាំនៅក្នុងព្រះនគរបានហែហមគេដល់ពាក់កណ្តាលផ្លូវ ។ ស្រីដទៃក៏ទទួលហែហមហើយនាំគេទៅកាន់ប្រាសាទរបស់ខ្លួន ។ ស្រីរបាំដែលហែហមមុន ក៏នាំគ្នាត្រឡប់ទៅកាន់ក្រុងរបស់ខ្លួន ។ គេនៅក្នុងប្រាសាទនោះរហូតដល់អស់ ៤ ខែ ហើយធ្វើដំណើរត្រឡប់ទៅកាន់ក្រុងមួយទៀត ដោយទំនងនោះឯង ។ គេសោយសម្បត្តិយ៉ាងនេះគ្រប់ ៨០ ឆ្នាំបរិបូណ៌ ។ គ្រានោះ ព្រះមានព្រះភាគស្តេចចារិកទៅដល់ព្រះនគរពារាណសីហើយ ។ គេស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះមានព្រះភាគ កើតសទ្ធាក៏បានបួសនៅជាបុថុជ្ជនត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ លុះក្នុងថ្ងៃទី ៨ គេក៏បានសម្រេចនូវព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ។ ត្រកូលទាំងពីរមានទំនាក់ទំនងនឹងលោកយ៉ាងនេះ ព្រោះដូច្នោះ លោកទើបបានឈ្មោះថា **ពក្កុល** ។

បទថា **បុរាណគិហិសហាយោ** ប្រែថា ធ្លាប់ជាសម្លាញ់នឹងគ្នាមកក្នុងកាលនៅជាគ្រហស្ថ ។ សូម្បីបរិព្វាជកឈ្មោះ អចេលកស្សបៈនេះ ក៏មានអាយុច្រើនដូចគ្នា កាលនឹងទៅសួរសុខទុក្ខព្រះថេរៈជាអ្នកបួស បានទៅក្នុងវស្សាទី ៨០ ។ បទថា **មេថុនោ ធម្មោ** សេចក្តីថា ជាបុគ្គលល្ងង់នៅក្នុងពួកសមណៈ

អាក្រាត សួរដោយល្ងង់ៗ មិនបានសួរដោយប្រើពាក្យជាសាសនវោហារ ។ គេតាំងនៅក្នុងន័យដែលព្រះថេរៈឲ្យហើយក្នុងកាលឥឡូវនេះ ទើបសួរដោយពាក្យជាដើមថា **ឥមេហិ បន តេ** ដូច្នេះ ។

**[៥០]** ព្រះធម្មសង្គាហកត្ថេរៈទាំងឡាយកំណត់បទទាំងឡាយ មានជាដើមថា **យម្បាយស្មា** ដូច្នេះ តាំងទុកហើយ ក្នុងសព្វវារៈទាំងឡាយ ក៏ក្នុងសព្វវារៈទាំងនោះ សញ្ញាពេលកើតឡើងហើយប៉ុណ្ណោះ វិតក្កៈក៏នឹងទម្លាយកម្មបថ ព្រោះដូច្នោះ ព្រះថេរៈទើបពោលថា លោកទាំងឡាយនឹងបែកពីគ្នាហេតុដូចម្តេច ទាំងពីរយ៉ាងនេះ សុទ្ធតែធ្វើកម្មបថឲ្យបែកធ្លាយទាំងអស់ ។

**[៥១]** បទថា **គហបតិចីវរំ** បានដល់ ចីវររបស់ភិក្ខុដែលនៅចាំវស្សា ។ បទថា **សត្ថេន** បានដល់ កន្ត្រៃ ។ បទថា **សូចិយា** មានអធិប្បាយថា យើងមិនរឭកដល់ប្រការដែលចីវរនឹងត្រូវដេរដោយម្ជុល ។ បទថា **កឋិនេ ចីវរំ** បានដល់ កឋិនចីវរ ។ ក៏កឋិនចីវរ មានគតិតែម្យ៉ាងជាមួយសំពត់ចំណាំវស្សាប៉ុណ្ណោះ ព្រោះដូច្នោះ ក្នុងកឋិនចីវរនោះ លោកទើបពោលថា **សិព្វិតា ។បេ។ នាភិជានាមិ** ដូច្នេះ ។

សួរថា កាលព្រះពក្កុលត្ថេរនោះ មិនត្រេកអរនឹងគហបតីចីវរ មិនធ្វើ

នវកម្ម មានការកាត់ និងការដេរជាដើម រហូតដល់អស់វេលាប្រមាណប៉ុណ្ណេះ ចីវរនឹងកើតពីទីណា ឆ្លើយថា កើតអំពីនគរទាំងពីរ ព្រះថេរៈមានយសដ៏ធំក្រៃលែង បុត្រជីតាចៅ ចៅទួតរបស់លោក ឲ្យអ្នកធ្វើចីវរដោយសំពត់សាដកសាច់ល្អិត ឲ្យគេជ្រលក់ហើយដាក់ក្នុងប្រអប់ បញ្ជូនទៅប្រគេន ។ ក្នុងវេលាដែលព្រះថេរៈងូតទឹក គេដាក់ទុកត្រង់ទ្វារបន្ទប់ទឹក ព្រះថេរៈស្លៀក និងដណ្តប់ចីវរទាំងនោះ ។ លោកនឹងឲ្យចីវរចាស់ៗ ដល់បព្វជិតទាំងឡាយដែលលោកជួប ។ ព្រះថេរៈស្លៀកដណ្តប់ចីវរទាំងនោះហើយ មិនត្រូវធ្វើនវកម្ម ។ កិច្ចកម្មដែលនឹងត្រូវប្រមូលអ្វីៗ ក៏មិនមាន ។ លោកនឹងអង្គុយចូលផលសមាបត្តិ កាលគ្រប់បួនខែហើយ រោមក៏ជ្រុះចេញ គ្រានោះ កូនៗ ចៅៗ ក៏បានបញ្ជូនចីវរទៅប្រគេនលោក ដោយទំនងនោះឯង ។ អាចារ្យពួកខ្លះពោលថា លោកផ្លាស់ប្តូរចីវររាល់ៗ កន្លះខែម្តង ។

ក៏ប្រការដែលព្រះថេរៈជាអ្នកមានបុណ្យច្រើន មានអភិញ្ញាច្រើន បានបំពេញបារមីមកអស់មួយសែនកប្ប ផ្លាស់ប្តូរចីវររាល់ៗ កន្លះខែនោះ ជារបស់មិនគួរអស្ចារ្យឡើយ ព្រះនិគ្រោធត្ថេរអ្នកនៅជាប្រចាំក្នុងរាជដំណាក់របស់ព្រះបាទអសោកធម្មរាជ ត្រូវផ្លាស់ប្តូរចីវរក្នុងមួយថ្ងៃ ៣ ដង ។ ក៏អាមាត្យរបស់

ព្រះរាជាបានដាក់ត្រៃចីវររបស់លោកទុកលើក-ដំរី នាំមកប្រគេនពីព្រឹកព្រលឹម ព្រមទាំងប្រអប់ដាក់របស់ក្រអូប ៥០០ ប្រអប់ដាក់ផ្កាឈើ ៥០០ ។ ក្នុងវេលាថ្ងៃ និងវេលាល្ងាច ក៏បដិបត្តិដូច្នោះ ។ បានឮថា ព្រះរាជាកាលឲ្យលោកផ្លាស់សំពត់មួយថ្ងៃ ៣ ដង ក៏ត្រាស់សួរថា ពួកអ្នកនាំចីវរទៅប្រគេនព្រះថេរៈហើយឬ ។ ពេលទ្រង់ព្រះសណ្ដាប់ថា នាំទៅប្រគេនហើយ ខ្ញុំព្រះអង្គ ទើបនឹងឲ្យផ្លាស់ ។ សូម្បីព្រះថេរៈក៏មិនបានរក្សាទុក ។ តែបានប្រគេនដល់សព្រហ្មចារីដែលលោកជួបហើយ ។

បានឮថា ក្នុងគ្រានោះ ភិក្ខុសង្ឃក្នុងជម្ពូទ្វីបទាំងអស់ ដោយច្រើនបានប្រើបច្ច័យ គឺ ចីវរដែលជារបស់ព្រះនិគ្រោធត្ថេរនោះ ។ ក្នុងបទថា **អហោវត មំ កោចិនិមន្តេយ្យ** នេះ មានពាក្យសួរថា ហេតុអ្វី ការហាមមិនឲ្យចិត្តកើតឡើង ទើបជាការៈធ្ងន់ និងដែលកើតឡើងហើយក៏ត្រូវលះបង់ ។

ឆ្លើយថា ដែលឈ្មោះថា ចិត្ត ព្រោះផ្លាស់ប្ដូរបានរហ័ស ព្រោះដូច្នោះការហាមមិនឲ្យចិត្តកើតឡើង ទើបជាការៈធ្ងន់ សូម្បីការលះចិត្តដែលកើតឡើងហើយ ក៏ជាការៈធ្ងន់ដូចគ្នា ។ បទថា **អន្តរឃរេ** សេចក្ដីថា ក្នុងមហាសកុលុ-ទាយិសូត្រ តាំងពីធរណីទ្វារទៅ ហៅថា ផ្ទះ តែក្នុងទីនេះប្រាថ្នាយកតាំងពីទីតាំង

នៃទឹកធ្លាក់អំពីជាយស្បូវ ។

សួរថា ក៏ភិក្ខានឹងកើតដល់លោកបានក្នុងទីណា ។

ឆ្លើយថា ព្រះថេរៈមានមនុស្សស្គាល់ទូទៅទាំងពីរព្រះនគរ ពេលលោកមកដល់ទ្វារផ្ទះប៉ុណ្ណោះ មនុស្សក៏នាំគ្នាមកទទួលបាត្រ ដាក់កោជនដែលមានរសដ៏ក្រៃលែងផ្សេងៗ ប្រគេន ។ លោកក៏ត្រឡប់ពីកន្លែងដែលលោកបានទទួលអាហារហើយ ។ តែកន្លែងសម្រាប់ធ្វើភត្តកិច្ចរបស់លោក មានប្រចាំតែម្តង ។ បទថា **អនុព្យញ្ជនសោ** សេចក្តីថា បានឮថា ព្រះថេរៈកាន់យកនិមិត្តក្នុងរូបហើយមិនធ្លាប់សម្លឹងមើលមាតុគ្រាមឡើយ ។ បទថា **មាតុគ្រាមស្ស ធម្មំ** សេចក្តីថា នឹងសម្តែងធម៌ដល់មាតុគ្រាមដោយវាចាត្រឹមតែ ៥-៦ ម៉ាត់ ក៏គួរតែបើត្រូវសួរបញ្ហា នឹងពោលគាថា សូម្បីទាំងពាន់ ក៏សមគួរដោយពិត ។ ព្រះថេរៈមិនធ្លាប់ធ្វើវត្ថុដែលជាកប្បិយៈឲ្យជាអកប្បិយៈឡើយ ។ ពិតហើយ ការធ្វើដូច្នោះ ដោយច្រើននឹងមានដល់ភិក្ខុអ្នកចូលកាន់ត្រកូល ។ បទថា **ភិក្ខុនូបស្សយំ** ប្រែថា សម្នាក់របស់ភិក្ខុនី ។ ក៏ភិក្ខុដែលសួរសុខទុក្ខ នឹងទៅកាន់សម្នាក់របស់ភិក្ខុនីនោះ ក៏គួរ ។

ក៏ព្រះថេរៈមិនធ្វើចំពោះវត្ថុដែលជាកប្បិយៈ ។ ក្នុងបទទាំងពួងក៏មាន

ន័យនេះ ។ បទថា **ចុណ្ណេន** បានដល់ គ្រឿងលំអិត មានផ្កាជាដើម ។ បណ្តាបទទាំងនោះ បទថា **បរិកម្មេ** បានដល់ ធ្វើការប្រេបាច់ខ្លួន ។

បទថា **វិចាតា** ប្រែថា ឲ្យប្រេកបហើយ ។ បទថា **គទ្ទូហនមត្តំ** សេចក្តីថា សូម្បីខណៈចាប់ដោះគោ ហើយប្របាច់យកទឹកដោះត្រឹមតែមួយតំណក់ ។

ក៏ព្រះថេរៈមិនធ្លាប់អាពាធដោយហេតុណាៗ ឡើយ ។ បានឮថា កាលព្រះមានព្រះភាគទ្រង់ព្រះនាមថា **បទុមុត្តរៈ** មានភិក្ខុមួយសែនជាបរិវារ ស្តេចត្រាច់ចារិកទៅ ដើមឈើដែលមានពិសក្នុងព្រៃហិមពាន្តរីកហើយ ។ សូម្បីភិក្ខុទាំងសែនក៏មានអាពាធព្រោះផ្កាស្មៅពិស ។ ក្នុងសម័យនោះ ព្រះថេរៈជាតាបសអ្នកមានឫទ្ធិ ។ លោកហោះទៅ ឃើញភិក្ខុសង្ឃ ទើបចុះមកសួរដល់រោគ ហើយនាំឱសថមកពីព្រៃហិមពាន្តចាត់ចែងថ្វាយ ។ ត្រឹមតែប៉ះខ្លួប់ថ្នាំប៉ុណ្ណោះ រោគក៏ស្ងប់ក្លាម ។ សូម្បីក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា **កស្សបៈ** លោកឈប់ក្ជួរស្រែក្នុងថ្ងៃដំបូង ឲ្យក៏សាងរោងបាយ និងវច្ចកុដិ ចាត់ចែងថ្នាំថ្វាយភិក្ខុសង្ឃជាប្រចាំ ដោយកម្មនេះ លោកទើបជាអ្នកប្រាសចាកអាពាធ ។ មួយវិញទៀត ព្រោះលោកសមាទានការអង្គុយជាវត្តយ៉ាងឧក្រិដ្ឋ និងការនៅព្រៃជាវត្តប្រភេទឧក្រិដ្ឋ ដូច្នោះ លោកទើបពោលពាក្យជា

ដើមថា នាគិជានាមិ អបស្សយិតា ។

**[៥២]** បទថា **សរណោ** ប្រែថា នៅមានកិលេស ។ បទថា **អញ្ញា ឧទបាទិ** សេចក្តីថា មិនគួរព្យាករណ៍ព្រះអរហត្តដល់អនុបសម្បន្ន ។

សួរថា ព្រោះហេតុអ្វី ព្រះថេរៈទើបបានព្យាករណ៍ ។

ឆ្លើយថា ព្រះថេរៈមិនបានពោលថា យើងជាព្រះអរហន្ត តែពោលថា ព្រះអរហត្តផលកើតឡើងហើយ ។ មួយទៀត ប្រាកដថា ព្រះថេរៈបានជាព្រះអរហន្តហើយ ព្រោះដូច្នោះ លោកទើបពោលយ៉ាងនេះ ។

**[៥៣]** បទថា **បព្វជ្ជំ** សេចក្តីថា ព្រះថេរៈមិនបានឲ្យបរិព្វាជកឈ្មោះអចេលកស្សបៈ បព្វជ្ជា និងឧបសម្បទាដោយខ្លួនឯង តែឲ្យភិក្ខុពួកដទៃបំបួស ។

**[៥៤]** បទថា **អបាបុរណំ អាទាយ** ប្រែថា កាន់កូនសោ ។ បទថា **និសិន្នកោវ បរិនិព្វាយិ** សេចក្តីថា ព្រះថេរៈត្រិះរិះថា សូម្បីយើងមានជីវិតរស់នៅ កុំបានជាភារៈដល់ភិក្ខុពួកដទៃ សរីរៈរបស់យើងសូម្បីបរិនិព្វានហើយ កុំឲ្យភិក្ខុសង្ឃរកផ្លូវល់ឡើយ ទើបចូលតេជោធាតុបរិនិព្វានហើយ អណ្តាតភ្លើងឆេះឡើងពេញសរីរៈ ។ សម្បុរស្បែក សាច់ និងលោហិត ត្រូវឆេះអស់ទៅដូចទឹកដោះថ្លា ។ នៅសល់ត្រឹមតែធាតុ ដែលមានលក្ខណៈដូចផ្កាម្លិះក្តោប ។

ពាក្យដ៏សេសក្នុងបទទាំងពួង ច្បាស់ហើយទាំងនោះ ។

ក៏ឯព្រះសូត្រនេះ លោកសង្គ្រោះចូលក្នុងទុតិយសង្គហវារៈ ។

ចប់អដ្ឋកថា ពក្កុលសូត្រទី ៤

# អ ដ្ឋ ក ថា

## ទន្តភូមិសូត្រទី ៥

**[៥៦]** ទន្តភូមិសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្ដាប់មក យ៉ាងនេះ ៖

បណ្ដាបទទាំងនោះ បទថា **អរញ្ញកុដិកាយំ** បានដល់ ក្នុងសេនាសនៈ ដែលគេសាងទុក ដើម្បីប្រយោជន៍ដល់ភិក្ខុអ្នកបំពេញព្យាយាម ក្នុងទីដែល ស្ងៀមស្ងាត់មួយកន្លែងរបស់វត្តវេឡុវ័ននោះឯង ។ បទថា **រាជកុមារោ** សំដៅ ដល់ ព្រះរាជកុមារជយសេន ទ្រង់ជាបុត្ររបស់ព្រះបាទពិម្ពិសារ ។

**[៥៧]** បទថា **ផុសេយ្យ** ប្រែថា គប្បីបាន ។ បទថា **ឯកគ្គតំ** សេចក្ដី ថា ព្រះរាជកុមារត្រាស់ថា ខ្ញុំបានស្ដាប់មកយ៉ាងនេះថា ភិក្ខុដែលបដិបត្តិយ៉ាង នេះ ឈ្មោះថា រមែងបានសមាបត្តិ ឈ្មោះថា រមែងបានឈាន ។

**[៥៨]** បទថា **កិលមថោ** បានដល់ សេចក្ដីលំបាកកាយ ។ សេចក្ដី លំបាកនោះឯង ហៅថា **វិហេសា** ខ្វះ ។ បទថា **យថាសកេ តិដ្ឋេយ្យាសិ** សេចក្ដីថា សូមព្រះអង្គគប្បីតាំងនៅក្នុងចំណែកដែលមិនដឹងរបស់ព្រះអង្គចុះ ។

**[៥៩]** បទថា **ទេសេសិ** សេចក្ដីថា រមែងបានយ៉ាងនេះ គឺ បានចិត្ត-កគ្គតា បានដល់ រមែងញ៉ាំងសមាបត្តិឲ្យកើតយ៉ាងនេះ ព្រោះដូច្នោះ អ្នកដែលដល់អប្បនាសមាធិ និងឧបចារសមាធិហើយ ទើបពោលកសិណបរិកម្មយ៉ាងនេះ ។ បទថា **បវេទេត្វា** ប្រែថា ប្រកាសហើយ ។

**[៦០]** បទថា **នេក្ខម្មេន ញាតព្វំ** សេចក្ដីថា គប្បីដឹងដោយគុណ គឺ បព្វជ្ជាដែលជាគ្រឿងរលាស់ចេញចាកកាម ។ ប្រការនោះ លោកពោលទុកដោយអធិប្បាយថា ដែលឈ្មោះថា **ឯកគ្គតា** ដែលបុគ្គលដែលតាំងនៅក្នុងគុណ គឺ បព្វជ្ជាដែលជាគ្រឿងរលាស់ចេញចាកកាម គប្បីដឹង ។ បទដ៏សេសជាវេវចនៈរបស់បទថា **ញាតព្វំ** នោះឯង ។ បទថា **កាមេ បរិកុញ្ជនតោ** បានដល់ បរិភោគកាមសុខទាំងពីរយ៉ាង ។

**[៦១]** បទថា **ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា** នេះ មានអធិប្បាយថា បុគ្គលដែលវៀរចាកភាពជាអ្នកមានចិត្តតម្កល់មាំ គប្បីឃើញដូចជាការទូន្មានដំរី ដែលមិនធ្លាប់បានទទួលការទូន្មានជាដើម បុគ្គលដែលសម្បូរណ៍ដោយភាពជាអ្នកមានចិត្តតម្កល់មាំ គប្បីឃើញដូចជាការទូន្មានដំរី ដែលធ្លាប់បានទូន្មានហើយជាដើម ។ ប្រៀបដូចសត្វពាហនៈ មានដំរីជាដើមដែលមិនបាន

ទទួលការទូន្មាន រមែងមិនសមគួរនឹងទៅកាន់ទីលានហ្វឹកហាត់ ឬដល់ភូមិភាគនៃសត្វដែលទូន្មានហើយគប្បីដល់ ដោយមិនត្រូវធ្វើធុះកំពូល មិនត្រូវលះបង់ធុរៈយ៉ាងណា បុគ្គលដែលប្រាសចាកកាពជាអ្នកមានចិត្តតម្កល់មាំក៏ដូច្នោះ រមែងមិនអាចញ៉ាំងគុណ ដែលបុគ្គលសម្បូរណ៍ដោយឯកគ្គតាចិត្តឲ្យកើតហើយ ឲ្យកើតឡើងបាន ។

[៦២] បទថា **ហត្ថវិលង្ឃកេន** ប្រែថា ទាញដៃគ្នាទៅ ។ បទថា **ទិដ្ឋេយ្យំ** ប្រែថា គួរមើល ។ បទថា **អាវុដោ** ប្រែថា រួមរឹតទុក ។ បទថា **និវុដោ** ប្រែថា បិទបាំងទុក ។ បទថា **ឱផុដោ** ប្រែថា គ្របសង្កត់ទុកហើយ ។

[៦៣] បទថា **នាគវនិកំ** សេចក្តីថា ក្នុងហត្ថិបទោបមសូត្រ លោកហៅបុរសអ្នកត្រាច់ទៅក្នុងនាគវនថា **នាគវិកោ** ។ ក្នុងសេចក្តីនេះ មានអធិប្បាយថា បុរសអ្នកឆ្លាតក្នុងការទូន្មានដំរី រមែងអាចនឹងគ្រប់គ្រងដំរីបាន ។ បទថា **អតិបស្សិត្វា** ប្រែថា ឃើញហើយ ។

បទថា **ឯត្ថ គេធា** បានដល់ សេចក្តីព្រួយបារម្ភដែលប្រព្រឹត្តទៅក្នុងនាគវននោះ ។ បទថា **សរសង្កប្បានំ** ប្រែថា សេចក្តីត្រិះរិះដែលស្ទុះទៅ ។ ក្នុងបទថា **មនុស្សកន្តេសុ សីលេសុ សមាទបនាយ** មានអធិប្បាយថា ក្នុងវេលា

ណាស្ត្រី និងបុរស កុមារកុមារី ចាប់តាំងក្អកជាដើម លេងក្បាល ដំរីមិនសម្តែងអាការខុសប្រក្រតី គឺ នៅយ៉ាងសប្បាយក្នុងវេលានោះ ដំរីនោះឈ្មោះថា រមែងរីករាយចិត្តតាមប្រក្រតីដែលមនុស្សត្រូវការ ។

បទថា **បេមនីយា** បានដល់ និយាយថា នែ៎បា ព្រះរាជាប្រោសប្រទានដល់បាហើយ នឹងតែងតាំងបាទុកក្នុងតំណែងមង្គលហត្ថីនុ៎ះឯង បានឹងបានរបស់ស៊ីល្អៗ មានភោជនជាដើម ដែលគួរដល់ព្រះរាជាអនុគ្រោះ ពាក្យនិយាយបែបនេះ ជាពាក្យនិយាយដែលដំរីពេញចិត្ត ។ បទថា **សុស្សុសតិ** សេចក្តីថា ដំរីរមែងប្រាថ្នានឹងស្តាប់ពាក្យដែលគួរស្រឡាញ់បែបនោះ ។ បទថា **តិណោឃាសោទកំ** បានដល់ បន្ថែមអាហារ គឺ ស្មៅ និងទឹក បទថា **តិណឃាសំ** ប្រែថា ស្មៅដែលគប្បីទំពារ អធិប្បាយថា ស្មៅដែលគប្បីស៊ី ។

បទថា **បណ្ឌវោ** ប្រែថា ស្គរជ័យ ។ បទថា **សព្វវន្ត ទោសនិហតនិន្និតកសាវោ** បានដល់ ទាំងកម្ចាត់ទោស គឺ សេចក្តីកោងកាចគ្រប់យ៉ាងបានផង ទាំងអស់អស្មិមានះផង ។ បទថា **អង្គន្តេ្វ សំង្ខំ គច្ឆតិ** សេចក្តីថា រមែងចាត់ជាអង្គសម្បត្តិ ។

**[៦៥]** បទថា **គេហសិតសីលានំ** បានដល់ សីលដែលអាស្រ័យកាម-

គុណ ៥ ។ បទថា ញាយស្ស បានដល់ អដ្ឋង្គិកមគ្គ ។

ក្នុងបទថា អទន្តមរណំ មហល្លកោ រញ្ញោ នាគោ មតោ កាលកតោ នេះ បានសេចក្ដីដូច្នេះថា ដំរីចាស់របស់ព្រះរាជាដួល ទាំងដែលនៅមិនបានទូន្មាន ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ទន្តភូមិសូត្រទី ៥

# អ ដ្ឋ ក ថា

## ភូមិជសូត្រទី ៦

**[៧៣]** *ភូមិជសូត្រ មានបទចាប់ផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖*

*បណ្តាបទទាំងនោះ បទថា **ភូមិជោ** សេចក្តីថា ព្រះថេរៈនេះជាអ៊ំរបស់ព្រះរាជកុមារទ្រង់ព្រះនាមថា **ជយសេន** ។*

**[៧៤]** *បទថា **អាសញ្ច អនាសញ្ច** សេចក្តីថា គ្រាខ្លះក៏ប្រាថ្នា គ្រាខ្លះក៏មិនប្រាថ្នា ។ បទថា **សកេនេវ ថាលិបាកេន** សេចក្តីថា ទ្រង់អង្គាសដោយភិក្ខាដែលប្រព្រឹត្តទៅហើយតាមប្រក្រតី គឺ ដោយភត្តដែលគេត្រៀមទុកដើម្បីព្រះអង្គ ។ បទដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ភូមិជសូត្រទី ៦

# អ ដ្ឋ ក ថា

## អនុរុទ្ធសូត្រទី ៧

[៨៨] *អនុរុទ្ធសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

[៨៩] *បណ្ដាបទទាំងនោះ បទថា **ឯវមាហំសុ** សេចក្ដីថា ចូលទៅរកក្នុងវេលាដែលឧបាសកនោះមិនសប្បាយ ទើបពោលយ៉ាងនេះ ។ បទថា **អបណ្ណកំ** ប្រែថា មិនខុសក្លាំងក្លាត់ ។ បទថា **ឯកត្ថ** បានដល់ ជាទាំងចេតោវិមុត្តិដែលរកប្រមាណមិនបាន ឬចេតោវិមុត្តិដែលជាមហគ្គតៈ ។ លោកកាន់យកពាក្យនេះថា ឈានក៏ហៅយ៉ាងនោះ ព្រោះសភាពចិត្តនោះឯង មានអារម្មណ៍ជាមួយ ។*

[៩១] *បទថា **យាវតា ឯកំ រុក្ខមូលំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ** សេចក្ដីថា ព្រះយោគាវចរបង្អោនចិត្តផ្សាយទៅកាន់មហគ្គតឈានក្នុងកសិណនិមិត្តនោះ គ្របដណ្ដប់គល់ដើមឈើមួយកន្លែង ជាទីល្មមប្រមាណដោយកសិណនិមិត្តហើយ ។ បទថា **មហគ្គតំ** សេចក្ដីថា ក៏សេចក្ដីចង់ចិត្តមិនមានដល់ភិក្ខុនោះ លោកទើបពោលបទនេះទុក ដោយអំណាចនៃការប្រព្រឹត្តទៅនៃ*

មហគ្គតឈានតែម្យ៉ាង ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា **ឥមិនា ខោឯតំ គហបតិ បរិយាយេន** សេចក្ដីថា ដោយហេតុនេះ ។ ក៏ក្នុងសេចក្ដីនេះមានវិនិច្ឆ័យថា ក៏និមិត្តនៃព្រហ្មវិហារ ដែលលោកពោលទុកថា ជាអប្បមាណានេះ រមែងមិនគួរ គឺ នៅមិនកើតការពង្រីកទៅ និងឈានទាំងនោះ ក៏មិនទាន់ជាបាទនៃអភិញ្ញា ឬនិរោធ ក៏ឈានដែលជាបាទនៃវិបស្សនា រមែងជាបាទនៃវដ្ដៈ និងជាការឈានចុះកាន់ភព ។ តែនិមិត្តនៃឈានដែលជាកសិណដែលលោកពោលថាជាមហគ្គតៈ រមែងគួរ គឺ រមែងកើតការពង្រីកចេញទៅ និងរមែងឈានកន្លងបាន ហើយឈានដែលជាបាទនៃអភិញ្ញា រមែងជាបាទនៃនិរោធផង ជាបាទនៃវដ្ដៈផង ទាំងឈានចុះកាន់ភពបានផង ។ ធម៌ទាំងនេះ មានអត្ថផ្សេងគ្នាយ៉ាងនេះ និងមានព្យញ្ជនៈផ្សេងគ្នាយ៉ាងនេះ គឺ ជាអប្បមាណា និងជាមហគ្គតៈ ។

**[៩២]** ក៏ឥឡូវនេះ កាលនឹងសម្ដែងហេតុនៃការចេញចាកមហគ្គតាសមាបត្តិ ហើយចូលកាន់ភព លោកទើបពោលពាក្យមានជាដើមថា **ចតស្សោ ខោ ឥមា** ដូច្នេះ ។ បទថា **បរិត្តាភា** សេចក្ដីថា ក៏សេចក្ដីតម្កល់ចិត្តនេះរបស់ភិក្ខុដែលបង្អោនចិត្តផ្សាយទៅហើយដឹងថានៅមាន តែភិក្ខុដែលត្រូវចម្រើនឈាន

ដែលជាហេតុនៃការកើតក្នុងពួកទេវតាជាន់បរិត្តាភាទាំងឡាយ លោកទើបពោល ទុកយ៉ាងនេះ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ទេវតាជាន់បរិត្តាភា មានពន្លឺស្រអាប់ក៏មាន មានពន្លឺថ្លាំងថ្លែងក៏មាន ។ ទេវតាជាន់អប្បមាណាភា មានពន្លឺស្រអាប់ក៏មាន មានពន្លឺថ្លាំងថ្លែងក៏មាន ។

សួរថា ប្រការនេះដូចម្ដេច ។ ឆ្លើយថា ភិក្ខុធ្វើបរិកម្មក្នុងកសិណ មានប្រមាណប៉ុនចង្អេរ ឬមានប្រមាណប៉ុនផ្ដិល ធ្វើសមាបត្តិឲ្យកើតហើយ មានសេចក្ដីជំនាញដែលសន្សំទុកហើយដោយអាការទាំង ៥ ព្រោះធម៌ដែលជាសត្រូវមិនទាន់បរិសុទ្ធិល្អ ។ បុគ្គលចូលសមាបត្តិដែលនៅមិនទាន់ជំនាញនុ៎ះឯង ហើយតាំងនៅក្នុងឈានមិនរហ័សរហួន ធ្វើមរណកាលហើយ រមែងកើតក្នុងពួកទេវតាជាន់បរិត្តាភាទាំងឡាយ ។ ទាំងវណ្ណៈរបស់គេក៏តិច និងសៅហ្មង ។ ចំណែកភិក្ខុដែលមានសេចក្ដីជំនាញដែលសន្សំទុកហើយដោយអាការទាំង ៥ ចូលសមាបត្តិដែលបរិសុទ្ធិល្អ តាំងនៅក្នុងឈានដែលរហ័សរហួន ធ្វើមរណកាលហើយរមែងកើតក្នុងទេវតាជាន់បរិត្តាភា ព្រោះធម៌ដែលជាសត្រូវបរិសុទ្ធិល្អ ។ ទាំងវណ្ណៈរបស់លោកមានតិច និងបរិសុទ្ធិ ។ ដោយប្រការដូចពោលមកនេះ ទេវតាជាន់បរិត្តាភា ទើបចាត់ថា មានទាំងពន្លឺស្រអាប់ក៏មាន មានទាំងពន្លឺថ្លាំងថ្លែង

ក៏មាន ។ ក៏ប្រការដែលភិក្ខុធ្វើបរិកម្មក្នុងកសិណដ៏បរិបូណ៌ ហើយញ៉ាំងសមា-បត្តិឲ្យកើត មានសេចក្តីរហ័សរហួនដែលសន្សំទុកមកហើយ ដោយអាការទាំង ៥ ដូច្នេះ ទាំងអស់គប្បីជ្រាបដូចគ្នានឹងការដែលពោលហើយក្នុងកាលមុន ។ ដោយប្រការដូចពោលមកនេះ ទេវតាជាន់អប្បមាណាភា ទើបចាត់ថា មានទាំងពន្លឺស្រអាប់ និងមានទាំងពន្លឺបាំងថែង ។

**[៩៣]** បទថា **វណ្ណនានត្តំ** ប្រែថា មានសម្បុរកាយផ្សេងគ្នា ។ បទថា **នោ ច អាភានត្តំ** បានដល់ មិនប្រាកដថាមានពន្លឺផ្សេងគ្នា ។ បទថា **អច្ចិនានត្តំ** សេចក្តីថា មានអណ្តាតផ្សេងគ្នា គឺ វែងខ្លះ ខ្លីខ្លះ តូចខ្លះ ធំខ្លះ ។

**[៩៥]** បទថា **យត្ថ យត្ថ** សេចក្តីថា នៅអាស្រ័យ គឺ នៅប្រចាំក្នុងទីណាមួយ ដូចឧទ្យាន វិមាន ដើមកល្បព្រឹក្ស មាត់ទឹក និងស្រះបោក្ខរណី ។ បទថា **អភិរមន្តិ** ប្រែថា រមែងត្រេកអរ គឺ មិនទៀយណាយ ។ បទថា **កាជេន** បានដល់ អម្រែកណាមួយ ដូចអម្រែកបាយយាគូ អម្រែកកត្ត អម្រែកប្រេង អម្រែកទឹកអំពៅ អម្រែកត្រី និងអម្រែកសាច់ បាឋៈថា **កាចេន** ដូច្នេះក៏មាន ។ សេចក្តីក៏ដូច្នេះដូចគ្នា ។ បទថា **បិដកេន** ប្រែថា ដោយកញ្ជើ ។ បទថា **តត្ថ តត្ថេវ** សេចក្តីថា ហ្វូងរុយ ដែលគេនាំចេញចាកកន្លែងដែលរកបានឆាយ ដូច

ទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅជាដើម ហើយនាំទៅកាន់កន្លែងដែលច្រើនទៅដោយអំបិល និងត្រីស្អុយជាដើម រមែងមិនកើតសេចក្តីគិតយ៉ាងនេះថា កាលមុនទីនៅរបស់យើងសប្បាយ យើងក៏នៅជាសុខក្នុងទីនោះ អំបិលធ្វើឲ្យយើងលំបាកក្នុងទីនេះ ឬថា ក្លិនត្រីស្អុយធ្វើឲ្យយើងឈឺក្បាល រមែងត្រេកអរក្នុងទីនោះៗតែម្តង ។

**[៩៦]** បទថា **អាភា** ប្រែថា សម្បុរណ៍ដោយពន្លឺ ។

**[១០៣]** បទថា **តទង្គេន** បានដល់ អង្គនៃការចូលដល់កពនោះ អធិប្បាយថា បានដល់ ហេតុនៃការចូលដល់កព ។

ឥឡូវនេះ កាលនឹងសួរដល់ហេតុនោះ លោកទើបពោលពាក្យមានជាដើមថា **កោ នុ ខោ ភន្តេ** ដូច្នេះ ។

**[១០៤]** បទថា **កាយទុដ្ឋុល្លំ** បានដល់ សេចក្តីខ្ជិលច្រអូសផ្លូវកាយ ។ បទថា **ឈាយតោ** ប្រែថា ភ្លើងឆេះរុងរឿង ។

**[១០៥]** បទថា **ទីឃរត្តំ ខោ មេ** សេចក្តីថា បានឮថា ព្រះថេរៈបំពេញបារមី បួសជាឥសី ញុំាងសមាបត្តិឲ្យកើត បានកំណើតក្នុងព្រហ្មលោក ៣០០ ជងជាប់គ្នា ពាក្យនេះលោកពោលសំដៅដល់ព្រះថេរៈរូបនោះឯង ។ សមដូច

ដែលលោកពោលជាគាថាប្រព័ន្ធទុកដូច្នេះថា ៖

ក្នុងកាលមុន យើងស្វែងរកអសន្ខតធម៌ ដែលមិនញាប់ញ័រ

បួសជាឥសី ត្រាច់ទៅហើយរហូតអស់ ៣០០ ឆ្នាំ ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា អនុរុទ្ធសូត្រ ទី ៧

# អ ដ្ឋ ក ថា

## ឧបក្កិលេសសូត្រទី ៨

**[១០៧]** ឧបក្កិលេសសូត្រ មានបទផ្ដើមថា **ឯវំមេ សុតំ** ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។

**[១០៨]** បណ្ដាបទទាំងនោះ បទថា **ឯតទវោច** សេចក្ដីថា មិនមែនក្រាបទូលដោយសេចក្ដីប្រាថ្នានឹងឲ្យបែកគ្នា និងមិនមែនដើម្បីនឹងផ្គាប់ផ្គន់ ពិតហើយ ភិក្ខុនោះមានសេចក្ដីគិតយ៉ាងនេះថា ភិក្ខុទាំងនេះជឿស្ដាប់យើងហើយនឹងវៀរចាក និងជម្លោះព្រះពុទ្ធទាំងឡាយ ទ្រង់ប្រាថ្នាអនុគ្រោះដើម្បីប្រយោជន៍តែម្យ៉ាង ព្រះអង្គនឹងត្រាស់ប្រាប់ហេតុមួយយ៉ាងដល់ភិក្ខុទាំងនេះដោយពិត ភិក្ខុទាំងនោះស្ដាប់ហេតុផលទាំងនោះហើយនឹងវៀរចាក តពីនោះភិក្ខុទាំងនោះនឹងនៅជាសុខ ។ ព្រោះហេតុនោះ ភិក្ខុនោះទើបក្រាបទូលពាក្យមានជាដើមថា **ឥធ ភន្តេ** ដូច្នេះ ។

ក្នុងបទជាដើមថា **មា ភណ្ឌនំ** គប្បីថែមបាឋៈដែលសល់ថា អកត្ថៈជាដើមចូលផង ហើយកាន់យកសេចក្ដីយ៉ាងនេះថា **មា ភណ្ឌនំ** កុំធ្វើការបន្ទរ

ហេតុ ។ បទថា **អញ្ញតរោ** សេចក្តីថា បានឮថា ភិក្ខុនោះប្រាថ្នាប្រយោជន៍ចំពោះព្រះមានព្រះភាគ គឺ បានឮថា ភិក្ខុនោះមានសេចក្តីប្រាថ្នាយ៉ាងនេះថា ភិក្ខុទាំងនេះ ត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ និងមិនជឿស្តាប់ពាក្យទូន្មានរបស់ព្រះសាស្តា សូមព្រះមានព្រះភាគ កាលទូន្មានភិក្ខុទាំងនេះ ទ្រង់កុំលំបាកឡើយ ដូច្នេះ ។ ព្រោះដូច្នោះ ទើបក្រាបទូលយ៉ាងនេះ ។

**[១១១]** បទថា **បិណ្ឌាយ បាវិសិ** សេចក្តីថា មិនមែនស្តេចចូលទៅដើម្បីបិណ្ឌបាតតែម្យ៉ាង តែទ្រង់បានអធិដ្ឋានព្រះទ័យថា អ្នកដែលឃើញតថាគតហើយ ចូរចូលគាល់តថាគត ។

សួរថា ទ្រង់អធិដ្ឋានដើម្បីប្រយោជន៍អ្វី ។

ឆ្លើយថា ដើម្បីទ្រង់ទូន្មានភិក្ខុទាំងនោះ ។ ក៏ព្រះមានព្រះភាគស្តេចត្រឡប់អំពីបិណ្ឌបាតដោយអាការយ៉ាងនោះហើយ ត្រាស់គាថាមានជាដើមថា **បុថុ-សទ្ទោ សមជនោ** ដូច្នេះ ហើយស្តេចចេញចាកក្រុងកោសម្ពីឆ្ពោះទៅកាន់ពាល-កលោណការគ្រាម ។ តពីនោះស្តេចទៅក្នុងបាចីនវង្សមិគទាយវ័ន បន្ទាប់ពីនោះស្តេចចូលទៅកាន់ព្រៃឈ្មោះថា បាលិលេយ្យកៈ ដែលដំរីដ៏ប្រសើរឈ្មោះ បាលិ-លេយ្យកៈរស់នៅ ទ្រង់ប្រថាប់នៅរហូតអស់ត្រៃមាស ។

សូម្បីអ្នកព្រះនគរគិតថា ព្រះសាស្តាស្តេចចូលទៅកាន់វិហារហើយ ពួកយើងនឹងទៅស្តាប់ធម៌ ហើយកាន់គ្រឿងក្រអូប ផ្កាឈើត្តោះទៅកាន់វិហារ សួរថា បពិត្រលោកម្ចាស់ ព្រះសាស្តាស្តេចយាងទៅណា ។ ភិក្ខុទាំងឡាយប្រាប់ថា ពួកលោកនឹងគាល់ព្រះសាស្តាបានក្នុងទីណា ព្រះអង្គស្តេចមកដោយប្រាថ្នាថា នឹងញ៉ាំងភិក្ខុទាំងនេះឲ្យសាមគ្គីគ្នា តែមិនអាចធ្វើឲ្យសាមគ្គីគ្នាបាន ទើបស្តេចចេញទៅ ។ ពួកអ្នកក្រុងទាំងអស់នាំគ្នាបន្ទោសថា ពួកយើងចេញប្រាក់ទាំងរយ ឬពាន់ ក៏មិនអាចនឹងនាំព្រះសាស្តាមកបាន សូម្បីពួកយើងនឹងមិនក្រាបទូលអង្វរព្រះអង្គ ក៏នឹងស្តេចមកឯង ព្រោះអាស្រ័យភិក្ខុទាំងនេះ ធ្វើឲ្យពួកយើងមិនបានស្តាប់ធម្មកថាចំពោះព្រះភក្ត្រព្រះអង្គ ភិក្ខុទាំងនេះបួសចំពោះព្រះសាស្តា សូម្បីកាលព្រះអង្គទ្រង់ធ្វើឲ្យសាមគ្គីគ្នា ក៏មិនព្រមស្មោះស្ម័គ្រសាមគ្គីគ្នា ដូច្នេះ នឹងជឿស្តាប់អ្នកណាហ្ន៎ ពួកយើងកុំថ្វាយភិក្ខាដល់ភិក្ខុទាំងនេះ ។ លុះថ្ងៃស្អែក ភិក្ខុទាំងនោះត្រាច់ទៅបិណ្ឌបាត ទូទាំងព្រះនគរមិនបានភិក្ខាសូម្បីត្រឹមតែមួយវែក ក៏ត្រឡប់មកវិញ ។ សូម្បីពួកឧបាសកឧបាសិកាទាំងឡាយពោលនឹងភិក្ខុទាំងនោះទៀតថា ពួកយើងនឹងដាក់ទណ្ឌកម្មដូច្នេះឯង ត្រាតែភិក្ខុទាំងនេះដឹងកំហុសរបស់ខ្លួន នឹងឲ្យព្រះសាស្តាទ្រង់អត់ទោស ។ ភិក្ខុទាំងនោះ

គិតថា ពួកយើងនឹងឲ្យព្រះសាស្ដាអត់ទោស កាលព្រះមានព្រះភាគស្ដេចមិនទាន់យាងដល់នគរសាវត្ថី ភិក្ខុទាំងនោះបានទៅរង់ចាំនៅក្នុងក្រុងសាវត្ថី ហើយព្រះសាស្ដាទ្រង់សម្ដែងភេទករវត្ថុ ១៨ ប្រការ ដល់ភិក្ខុទាំងនោះ ហើយក្នុងរឿងនេះ មានសេចក្ដីតាមដែលពោលទុកក្នុងបាលីមុត្តកៈត្រឹមតែប៉ុណ្ណេះ ។

ឥឡូវនេះនឹងវិនិច្ឆ័យក្នុងគាថា មានជាដើមថា **បុថុសទ្ទោ** ដូចតទៅនេះ

ឈ្មោះថា **បុថុសទ្ទោ** ព្រោះអត្ថថា មានសំឡេងខ្លាំង សម្លេងធំម្យ៉ាង ។ បទថា **សមជនោ** បានដល់ អ្នកដែលដូចគ្នា គឺ ស្រដៀងៗ គ្នា លោកអធិប្បាយថា អ្នកធ្វើការបង្ករហេតុទាំងអស់នេះ មានសំឡេងខ្លាំងផង មានសម្លេងស្រដៀងគ្នាផង ដោយការបន្លឺសំឡេងឮខ្លាំងទៅជុំវិញផង ។ បទថា **ន ពាលោ កោចិ មញ្ញថ** សេចក្ដីថា ក្នុងភិក្ខុទាំងនោះ មិនមានអ្នកណាសូម្បីតែម្នាក់ ដែលនឹងសម្គាល់ខ្លួនថា យើងជាជនពាល តែសម្គាល់ខ្លួនឯងថា ជាបណ្ឌិតទៅវិញ ។ បទថា **នាញ្ញំ ភិយ្យោ អមញ្ញថិ** បានដល់ មិនមានអ្នកណាៗ សូម្បីតែម្នាក់សម្គាល់ខ្លួនថា យើងជាពាល អធិប្បាយថា កាលសង្ឃបែកគ្នា ក៏មិនបានសម្គាល់ហេតុដទៃសូម្បីតែម្យ៉ាងឲ្យក្រៃលែងឡើងទៅ គឺ មិនសម្គាល់ដល់ហេតុនេះថា សង្ឃបែកគ្នាព្រោះយើងជាហេតុ ។ បទថា **បរិមុដ្ឋា** ប្រែថា វង្វេងស្មារតី ។

បទថា **វាចាគោចរភាណិនោ** នេះ លោកអាទេស **រា** អក្សរ ឲ្យជា **រ** អក្សរ សេចក្តីថា និយាយតាមអារម្មណ៍ (និយាយតាមតែទឹកឃើញ) មិនមានសតិប្បដ្ឋានឃុំគ្រង បានដល់ និយាយអត់សតិ ។ បទថា **យាវិច្ឆន្តិ មុខាយាមំ** បានដល់ និយាយទៅត្រឹមតែដើម្បីប្រាថ្នានឹងហារមាត់ អធិប្បាយថា សូម្បីកិក្ខុត្រឹមតែមួយរូបក៏មិនព្រមស្ងាត់មាត់ ដោយសេចក្តីគោរពក្នុងសង្ឃ ។ បទថា **យេន នីតា** សេចក្តីថា ក៏ជម្លោះណានាំទៅព្រោះភាវៈមិនអៀនខ្មាសនេះ ។ បទថា **ន តំ វិទូ** សេចក្តីថា មិនដឹងដល់ហេតុនោះថា ការឈ្លោះនេះ មានទោសយ៉ាងនេះ ។ បទថា **យេ ច តំឧបនយ្ហន្តិ** សេចក្តីថា បុគ្គលពួកណាចូលទៅចងសេចក្តីក្រោធនឹងគេ មានអាការជាដើមថា អ្នកនេះបានជេរយើង ដូច្នេះ ។ បទថា **សនន្តនោ** ប្រែថា ជាធម៌ចាស់ ។ បទថា **បរេ** សេចក្តីថា វៀរលែងតែបណ្ឌិតទាំងឡាយចេញហើយ អ្នកបង្ករការឈ្លោះនឹងបុគ្គលដទៃ ឈ្មោះថា បុគ្គលពួកដទៃ បុគ្គលទាំងនោះកាលបង្ករការឈ្លោះគ្នាត្រង់កណ្តាលសង្ឃនេះ រមែងមិនដឹងថា ពួកយើងនឹងហិនហោច គឺ នឹងវិនាសជិតស្លាប់ចូលទៅគ្រប់ខណៈ ។

បទថា **យេ ច តត្ថ វិជានន្តិ** សេចក្តីថា បណ្តាបុគ្គលទាំងនោះ បុគ្គលពួកណាជាបណ្ឌិត ដឹងខ្លួនថា ពួកយើងនៅជិតមច្ចុ ដូច្នេះ ។ បទថា **តតោ**

**សម្មន្តិ មេធគា** សេចក្ដីថា ក៏បណ្ឌិតទាំងនោះដឹងហើយយ៉ាងនេះ កើតយោនិ-សោមនសិការ រមែងបដិបត្តិដើម្បីចូលទៅស្ងប់រម្ងាប់ សេចក្ដីបែកបាក់ និងការឈ្លោះ ។ គាថាថា **អដ្ឋិច្ឆិទា** ជាដើមនេះ មានមកក្នុងជាតក លោកពោលសំដៅដល់ព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារ ។

ក្នុងព្រះគាថានេះ មានសេចក្ដីដូចតទៅនេះ

សូម្បីអ្នកទាំងនោះ គឺ អ្នកដែលចងពៀរវេរានិងគ្នាសូម្បីយ៉ាងនោះ ក៏នៅតែល្អនឹងគ្នាបាន ហេតុអ្វីពួកអ្នកទាំងឡាយ ទើបមិនល្អនឹងគ្នាហ្ន៎ ។ ព្រោះថា ពួកអ្នកមិនបានកាត់ឆ្អឹង (មិនបានសម្លាប់) ជីវិតមាតាបិតា មិនបាននាំទៅគោ សេះ និងទ្រព្យគ្នាផង ។ ត្រាស់ព្រះគាថាមានជាដើមថា **សចេ សភេថ** ដូច្នេះទុក ដើម្បីទ្រង់នឹងសម្ដែងគុណ និងទោសនៃមិត្តដែលជាបណ្ឌិត និងមិត្តដែលជាពាល ។ បទថា **អភិភុយ្យ សព្វានិ បរិស្សយានិ** សេចក្ដីថា គប្បីលើកសរសើរ មានសតិ ត្រាច់ទៅជាមួយមិត្តអ្នកឃុំគ្រងគ្នា អន្តរាយដែលប្រាកដនឹងមិនប្រាកដបាន ។ បទថា **រាជាវ រដ្ឋំវិជិតំ** សេចក្ដីថា គប្បីត្រាច់ទៅដូចព្រះមហាជនក និងព្រះបាទអរិន្ទមមហារាជ ដែលទ្រង់លះបង់ដែនដែលព្រះអង្គទ្រង់ច្បាំងឈ្នះហើយ ស្ដេចត្រាច់ទៅតែមួយព្រះអង្គឯង ។

*បទថា* **មាតង្គរញ្ញេវ នាគោ** *សេចក្តីថា ដូចដំរីមាតង្គៈត្រាច់ទៅក្នុងព្រៃដូច្នោះ ។ ដំរីធម្មតា លោកហៅថា មាតង្គៈ ។ បទថា* **នាគោ** *នេះ ជាឈ្មោះរបស់ដំរីធំ ។ លោកទើបពោលបានដូច្នេះថា ត្រាច់ទៅតែម្នាក់ឯង មិនធ្វើសេចក្តីអាក្រក់ទាំងឡាយ ដូចដំរីមាតង្គៈចិញ្ចឹមមេ ត្រាច់ទៅក្នុងព្រៃតែឯង មិនធ្វើសេចក្តីអាក្រក់ និងដូចដំរីបាលិលេយ្យកៈ ដូច្នោះ ។*

**[១១២]** *បទថា* **ពាលកលោណការគ្គាមោ** *បានដល់ ស្រុកសួយរបស់ឧបាលីគហបតី ។ ក្នុងបទថា* **តេនុបសង្កមិ** *នេះ មានពាក្យសួរថា ព្រោះហេតុអ្វីទើបស្តេចចូលទៅ ។*

*ឆ្លើយថា បានឮថា ព្រះអង្គទ្រង់ឃើញទោសក្នុងការនៅជាពួករបស់ព្រះភគុនោះ ទ្រង់ប្រាថ្នានឹងឃើញភិក្ខុនៅម្នាក់ឯង ដូច្នោះ ទើបស្តេចចូលទៅក្នុងពាលលោការគ្រាម ដូចអ្នកត្រូវសេចក្តីត្រជាក់ជាដើមបៀតបៀនហើយ ប្រាថ្នាសេចក្តីអប់កំដៅជាដើម ដូច្នោះ ។ បទថា* **ធម្មិយា កថាយ** *សេចក្តីថា ប្រកបដោយអានិសង្សក្នុងការនៅម្នាក់ឯង ។*

*សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគស្តេចទើបចូលទៅក្នុងបាចីនវង្សទាយវ័ននោះ ។*

ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់ប្រាថ្នានឹងជួបភិក្ខុទាំងឡាយដែលជាអ្នកបង្កការឈ្លោះគ្នា ហើយត្រឡប់មានការស្មោះស្ម័គ្រសាមគ្គីគ្នា ព្រោះឃើញទោសនៃការឈ្លោះនោះ ហេតុដូច្នោះ ទើបស្ដេចចូលទៅក្នុងបាចីនវង្សទាយក្នុងថ្ងៃនោះ ដូចអ្នកត្រូវសេចក្ដីត្រជាក់ជាដើមបៀតបៀនហើយ ប្រាថ្នាសេចក្ដីអប់អ៊ុនកំដៅជាដើម ដូច្នោះ ។

**[១១៣]** បទថា *អាយស្មា ច អនុរុទ្ធោ* ជាដើម មានន័យដូចពោលហើយនោះឯង ។

**[១១៩]** បទថា *អត្ថិ បន វោ* សេចក្ដីថា សួរដល់លោកុត្តរធម៌ដោយពាក្យសួរចុងក្រោយ ។

ក៏លោកុត្តរធម៌នោះ មិនមានដល់ព្រះថេរៈទាំងឡាយ ព្រោះដូច្នោះ ការសួរដល់លោកុត្តរធម៌ទើបមិនសមគួរឡើយ ព្រោះដូច្នោះលោកទើបសួរដល់ឱកាសនៃបរិកម្ម ។

បទថា *ឱភាសំ ញេវ សញ្ជានាម* បានដល់ រឭកដឹងពន្លឺនៃបរិកម្ម ។

បទថា *ទស្សនញ្ច រូបានំ* បានដល់ ដឹងច្បាស់រូបដោយទិព្វចក្ខុ ។

**[១២០]** បទថា *តញ្ច និមិត្តំ ន បដិវិជ្ឈាម* សេចក្ដីថា ក៏ឱកាស និង

ការឃើញរូបរបស់ខ្ញុំព្រះអង្គទាំងឡាយ រមែងបាត់ទៅដោយហេតុណា ខ្ញុំព្រះអង្គទាំងឡាយមិនទាន់ដឹងនូវហេតុនោះ ។ បទថា **តំ ខោ បន វោ អនុរុទ្ធា និមិត្តំ បដិវិជ្ឈិតព្វំ** សេចក្តីថា ពួកអ្នកទាំងឡាយគួរដឹងនូវហេតុនោះ ។ ព្រះមានព្រះភាគទ្រង់ប្រារព្ធទេសនានេះ ដោយពាក្យមានជាដើមថា **អហំបិ សុទំ** ដូច្នេះ ក៏ដើម្បីទ្រង់សម្តែងថា ម្នាលអនុរុទ្ធៈ ពួកអ្នកត្រូវឧបក្កិលេសរុំព័ទ្ធឬ សូម្បីតថាគតក៏ធ្លាប់រុំព័ទ្ធហើយដោយឧបក្កិលេស ១១ ប្រការទាំងនេះ ។ ក្នុងបទថា **វិចិកិច្ឆា ខោ មេ** ជាដើម សេចក្តីថា ព្រះមហាសត្វចម្រើនអាលោកកសិណហើយឃើញរូបមានប្រការផ្សេងៗ ដោយទិព្វចក្ខុ ទើបកើតវិចិកិច្ឆាថា នេះអ្វីហ្ន៎ នេះអ្វីហ្ន៎ ។ បទថា **សមាធិ ចវិ** សេចក្តីថា បរិកម្មសមាធិ ទើបរួចផុត ។ បទថា **ឱភាសោ** សេចក្តីថា សូម្បីឱភាសនៃបរិកម្មក៏បាត់ទៅ គឺ មិនឃើញរូបសូម្បីដោយទិព្វចក្ខុ ។

**[១២១]** បទថា **អមនសិការោ** សេចក្តីថា វិចិកិច្ឆា រមែងកើតដល់អ្នកដែលឃើញរូប គឺ កើតអមនសិការថា ឥឡូវនេះ យើងនឹងមិនធ្វើទុកក្នុងចិត្តនូវអ្វីៗ ។

**[១២២]** បទថា **ថីនមិទ្ធំ** សេចក្តីថា កាលមិនធ្វើទុកក្នុងចិត្តដល់អ្វីៗ

ថីនមិទ្ធៈក៏កើតឡើង ។

**[១២៣]** បទថា **ឆម្ភិតត្តំ** សេចក្ដីថា ភិក្ខុចម្រើនអាលោកកសិណ បែរមុខឆ្ពោះទៅកាន់ហិមវន្តប្រទេស បានឃើញសត្វផ្សេងៗ ដូចជាយក្ខ អារក្ខទឹក និងពោះថ្លាន់ជាដើម ពេលនោះសេចក្ដីភ័យព្រឺព្រួចកើតឡើងហើយដល់អ្នក ។

**[១២៤]** បទថា **ឧប្បិលំ** សេចក្ដីថា កាលភិក្ខុគិតថា វត្ថុដែលយើងឃើញថាគួរខ្លាច វេលាក្រឡេកមើលតាមប្រក្រតីរមែងមិនមាន កាលមិនមាន ហេតុដូចម្ដេចនឹងត្រូវខ្លាច ដូច្នេះ សេចក្ដីភ្ញាក់ផ្អើលជាដើមក៏អស់ទៅ ។ បទថា **សកឹទេវ** សេចក្ដីថា គប្បីជួបរណ្ដៅទ្រព្យ ៥ រណ្ដៅ ដោយការជីកត្រឹមតែមួយដងប៉ុណ្ណោះ ។

**[១២៥]** បទថា **ទុដ្ឋុល្លំ** សេចក្ដីថា សេចក្ដីព្យាយាមដែលយើងផ្គងទុកដ៏មុតមាំ ត្រូវបានភាពភ្ញាក់ផ្អើលដែលកើតដល់យើងនោះ ធ្វើឲ្យសេចក្ដីព្យាយាមធូរថយ ។ តពីនោះនឹងមានតែសេចក្ដីក្រវល់ក្រវាយកាយ ។ បទថា **កាយទុដ្ឋុល្លំ** សេចក្ដីថា សេចក្ដីក្រវល់ក្រវាយកាយ គឺ ភាវៈនៃកាយខ្ជិលច្រអូស ក៏កើតឡើង ។

**[១២៦]** បទថា **អច្ចារទ្ធវីរិយំ** សេចក្ដីថា សេចក្ដីព្យាយាមដែលប្រារព្ធពេកទៅ កើតហើយដល់ភិក្ខុដែលផ្ដើមតាំងសេចក្ដីព្យាយាមទៀត ដោយគិតថា

*សេចក្តីក្រវល់ក្រវាយធ្វើសេចក្តីព្យាយាមរបស់យើងឲ្យធូរថយ សេចក្តីរសាប់រសល់ទើបកើតឡើង ។ បទថា* **បតមេយ្យ** *ប្រែថា គប្បីស្ងាប់ ។*

**[១២៧]** *បទថា* **អតិលីនវីរិយំ** *សេចក្តីថា កាលយើងផ្គងសេចក្តីព្យាយាមយ៉ាងនេះ ធ្វើសេចក្តីព្យាយាមធូរថយ សេចក្តីព្យាយាមដែលធូរពេក ក៏កើតឡើងបានទៀត ។*

**[១២៨]** *បទថា* **អភិជប្បា** *សេចក្តីថា កាលយើងចម្រើនអាលោកកសិណបែរមុខទៅកាន់ទេវលោក ឃើញពួកទេវតា តណ្ហាក៏កើតឡើង ។*

**[១២៩]** *បទថា* **នានត្តសញ្ញា** *សេចក្តីថា កាលយើងចម្រើនអាលោក-កសិណ ឆ្ពោះមុខទៅកាន់ទេវលោកតាមកាល ហើយធ្វើទុកក្នុងចិត្តដល់រូបមានប្រភេទផ្សេងៗ គ្នា ដោយគិតថា កាលយើងធ្វើទុកក្នុងចិត្តដល់រូប ដែលមានកំណើតដូចគ្នា តណ្ហាក៏កើតឡើងហើយ យើងនឹងធ្វើទុកក្នុងចិត្តដល់រូបដែលមានប្រភេទផ្សេងៗ ដូច្នេះ សេចក្តីសម្គាល់សភាវៈថា ផ្សេងគ្នាក៏កើតឡើង ។*

**[១៣០]** *បទថា* **អតិនិជ្ឈាយិតត្តំ** *សេចក្តីថា កាលយើងធ្វើទុកក្នុងចិត្តដល់រូបមានប្រភេទផ្សេងៗ គ្នា សេចក្តីសម្គាល់សភាវៈថា ផ្សេងគ្នាក៏កើតឡើង កាលយើងតាំងចិត្តថា នឹងធ្វើទុកក្នុងចិត្តដល់រូបដែលមានកំណើតតែមួយជាមួយ*

គ្នា នឹងគួរប្រាប់ថា ឬមិនគួរក៏ដោយ ហើយធ្វើទុកក្នុងចិត្តយ៉ាងនោះ រូបដែលមានការសម្លឹងរំពៃពេកក៏កើត ។

**[១៣២]** បទថា **ឱភាសនិមិត្តំ មនសិករោមិ** សេចក្តីថា យើងមានសេចក្តីត្រិះរិះដូច្នេះថា យើងធ្វើទុកក្នុងចិត្តតែពន្លឺនៃបរិកម្មតែម្យ៉ាងប៉ុណ្ណោះ ។ បទថា **ន ច រូបានិ បស្សាមិ** សេចក្តីថា យើងមិនឃើញរូបដោយទិព្វចក្ខុ ។ បទថា **រូបនិមិត្តំ មនសិករោមិ** សេចក្តីថា យើងធ្វើទុកក្នុងចិត្តដល់រូបដែលជាអារម្មណ៍ប៉ុណ្ណោះ ដោយទិព្វចក្ខុ ។

**[១៣៣]** បទថា **បរិត្តញ្ចេវ ឱភាសំ** បានដល់ ពន្លឺក្នុងកម្មដ្ឋានបន្តិចបន្តួច ។ បទថា **បរិត្តានិ ច រូបានិ** បានដល់ រូបក្នុងកម្មដ្ឋានបន្តិចបន្តួច ។ បណ្ឌិតគប្បីជ្រាបទុតិយវារៈ ដោយបរិយាយផ្ទុយគ្នា ។ បទថា **បរិត្តោសមាធិ** បានដល់ ឱភាសនៃបរិកម្មបន្តិចបន្តួច ។ តែក្នុងទីនេះ លោកពោលបរិកម្មសមាធិថា បន្តិចបន្តួចដូច្នេះ សំដៅដល់ពន្លឺបន្តិចបន្តួច ។ បទថា **បរិត្តំ តស្មឹ សមយេ** សេចក្តីថា ក្នុងសម័យនោះ សូម្បីទិព្វចក្ខុក៏មានបន្តិចបន្តួច ។ សូម្បីក្នុងអប្បមាណវារៈក៏មានន័យនេះដូចគ្នា ។

**[១៣៤]** បទថា **អវិតក្កំបិ វិចារមត្តំ** បានដល់ សមាធិក្នុងទុតិយជ្ឈាន

ក្នុងបញ្ចកន័យ ។

បទថា **អវិតក្កំបិ អវិចារំ** បានដល់ សមាធិក្នុងពួក ៣ នៃឈាន ទាំងក្នុងចតុក្កន័យទាំងក្នុងបញ្ចកន័យ ។ បទថា **សប្បីតិកំ** បានដល់ សមាធិក្នុងទុកឈាន និងតិកឈាន ។

បទថា **និប្បីតិកំ** បានដល់ សមាធិក្នុងទុកទុកឈាន ។ បទថា **សាតសហគតំ** បានដល់ សមាធិក្នុងតិកចតុក្កឈាន ។ បទថា **ឧបេក្ខាសហគតំ** នេះក្នុងចតុក្កន័យ បានដល់ សមាធិក្នុងចតុត្ថជ្ឈាន ក្នុងបញ្ចកន័យផង សមាធិក្នុងបញ្ចមឈានផង ។

សួរថា ក៏ព្រះមានព្រះភាគទ្រង់ចម្រើនសមាធិមានយ៉ាង ៣ នេះ ក្នុងវេលាណា ។

ឆ្លើយថា ព្រះមានព្រះភាគ ប្រថាប់គង់ត្រង់មណ្ឌលមហាពោធិព្រឹក្សទ្រង់ចម្រើនសមាធិយ៉ាងនេះក្នុងបច្ឆិមយាម ។

ក៏បឋមមគ្គ បានជាអង្គប្រកបនៃបឋមជ្ឈានដល់ព្រះមានព្រះភាគ ។ ទុតិយមគ្គជាដើម ក៏បានជាអង្គប្រកបនៃទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈាន ។ ក្នុងបញ្ចកន័យ បញ្ចមឈានមិនមានមគ្គ ។ ពាក្យថា **មគ្គ** នោះ ចាត់ជាលោកិយៈ

*នេះលោកពោលសំដៅដល់មគ្គ ដែលលាយដោយលោកិយៈ និងលោកុត្តរៈ ។*

*ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ឧបក្កិលេសសូត្រទី ៨

# អ ដ្ឋ ក ថា

## ពាលបណ្ឌិតសូត្រទី ៩

**[១៣៥]** *ពាលបណ្ឌិតសូត្រ មានបទចាប់ផ្តើមថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖*

**[១៣៦]** *បណ្តាបទទាំងនោះ បទថា* ***ពាលលក្ខណានិ*** *សេចក្តីថា ដែលឈ្មោះថា* ***ពាលលក្ខណៈ*** *ព្រោះអត្ថថា ជាគ្រឿងកំណត់ គឺ ជាគ្រឿងសម្គាល់ឲ្យដឹងថា បុគ្គលនេះជាជនពាល ។ ពាលលក្ខណៈទាំងនោះឯង លោកហៅថា ពាលនិមិត្ត ព្រោះជាហេតុនៃការសម្គាល់ឲ្យដឹងថា បុគ្គលនោះជាជនពាល ។ ហៅថា* ***ពាលាបទាន*** *ព្រោះជនពាលប្រព្រឹត្តមិនដាច់ ។ បទថា* ***ទុច្ចិន្តិតចិន្តី*** *សេចក្តីថា ធម្មតាជនពាលសូម្បីកាលគិត រមែងគិតតែរឿងអាក្រក់ៗ ដោយអំណាចអភិជ្ឈា ព្យាបាទ និងសេចក្តីឃើញខុសតែម្យ៉ាង ។ បទថា* ***ទុព្ភាសិតភាសី*** *សេចក្តីថា សូម្បីកាលនិយាយ ក៏និយាយតែពាក្យអាក្រក់ៗ ដោយវចីទុច្ចរិត មានមុសាវាទជាដើម ។ បទថា* ***ទុក្កដកម្មការី*** *សេចក្តីថា សូម្បីកាលធ្វើក៏ធ្វើចំពោះតែកម្មអាក្រក់ៗ ដោយអំណាចនៃកាយទុច្ចរិត មានបាណាតិបាត*

ជាដើម ។

**[១៣៧]** បទថា **តត្រ ចេ** បានដល់ ក្នុងបរិស័ទដែលជនពាលអង្គុយហើយនោះ ។ បទថា **តជ្ជំ តស្សារុប្បំ** សេចក្តីថា នឹងនិយាយដោយពាក្យដែលល្មមសមគួរដល់គេ គឺ សមរម្យដល់គេអធិប្បាយថា បានដល់ ពាក្យដែលបដិ-សំយុត្តដោយទោស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយិកកត របស់បញ្ចវេរ ។ បទថា **តត្រ** បានដល់ ពាក្យនិយាយដល់គ្នានោះ ។

បទថា **ពាលំ** ជាដើម ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។

**[១៣៨]** បទថា **ឱលម្ពន្តិ** សេចក្តីថា រមែងចូលទៅតាំងនៅ (តែងគ្របដណ្តប់) ។ ពីរបទដ៏សេសជាវេវចនៈរបស់ បទថា **ឱលម្ពន្តិ** នោះ ។ លក្ខណៈជនពាលទាំងនោះ រមែងប្រាកដដោយអាការដែលការផ្សាយទៅជាដើម ព្រោះដូច្នោះ លោកទើបពោលយ៉ាងនេះ ។ បទថា **បឋវិយា ឱលម្ពន្តិ** បានដល់ផ្សាយទៅលើផែនដី ពីរបទដ៏សេសក៏ជាវេវចនៈរបស់បទនោះឯង ។ ក៏ប្រការនោះ ជាអាការដែលផ្សាយទៅ ។ បទថា **តត្រ ភិក្ខវេ ពាលស្ស** សេចក្តីថា កាលប្រាកដការណ៍នោះមកដល់ តពីនោះជនពាល រមែងមានសេចក្តីគិតយ៉ាងនេះ ។

[១៤១] បទថា **ឯតទវោច** សេចក្តីថា ភិក្ខុដែលឆ្លាតក្នុងអនុសន្ធិ គិតថា នរណាៗ មិនអាចនឹងធ្វើឧបមារបស់នរកបាន ព្រះមានព្រះភាគក៏មិនបាន ត្រាស់ទុក តែត្រាស់ថា មិនមែនរបស់ដែលធ្វើឧបមាបានដោយងាយ និងសូម្បី នឹងធ្វើបានងាយ ក៏មិនមានអ្នកអាចនឹងធ្វើឧបមាបាន ណ្ហើយចុះ យើងនឹងទូល អារាធនាឲ្យព្រះទសពលទ្រង់ធ្វើឧបមា ដូច្នេះ ហើយបានពោលពាក្យនេះថា **ឯតំ សក្កកន្តេ** ដូច្នេះ ។

បទថា **ហនេយ្យុំ** សេចក្តីថា គប្បីសម្លាប់ដោយការចាក់ដងដែលពីរដង ត្រង់កន្លែងតែមួយ មិនឲ្យដល់ស្លាប់ ដោយវិធីចាក់ដងដែលៗ ហើយក៏ទៅ ។ ព្រោះដូច្នោះ ចោរនោះទើបមានមុខដំបៅដល់ទៅ ២០០ កន្លែង ។ សូម្បីបទ ដែលមានចំនួនក្រៃលែងទៅជាងនេះ ក៏ន័យនេះដូចគ្នា ។

[១៤២] បទថា **បាណិមត្តំ** បានដល់ មានសណ្ឋានប៉ុនបាតដៃ ។ បទថា **សង្ខំបិ ន ឧបេតិ** ប្រែថា មិនដល់ខ្នាតដែលល្មមនឹងរាប់បាន ។ បទថា **កលភាគម្បិ** សេចក្តីថា មិនដល់ចំណែកដែលគួរនឹងពោលថា ចូលដល់ចំរៀកទាំង រយ ចំរៀកទាំងពាន់ ឬចំរៀកទាំងសែន ។ បទថា **ឧបនិធម្បិ** បានដល់ មិន ដល់ការចូលទៅប្រៀបធៀប គឺ មិនមានសូម្បីតែអ្នកដែលក្រឡេកមើល ។

[១៤៣] បណ្ដាបទទាំងនោះ បទថា **អយោខិលំ** សេចក្ដីថា ពួកនិរយ-បាលផ្ដេកសត្វនរក ដែលមានអត្តភាពកម្ពស់ ៣ គាវុត ឲ្យដេកផ្ងារលើផែនលោហៈដែលឆេះសន្ធោសន្ធៅ យកលំពែងដែកប្រមាណប៉ុនដើមត្នោតចាក់ចូលទៅក្នុងដៃខាងស្ដាំ ក្នុងដៃខាងឆ្វេងជាដើម ក៏ធ្វើយ៉ាងនោះ ហើយឲ្យដេកផ្កាប់ខ្លះ ដេកផ្អៀងខាងស្ដាំខ្លះ ផ្អៀងខាងឆ្វេងខ្លះ ពួកនិរយបាលធ្វើទណ្ឌកម្មយ៉ាងនេះឯង ។ បទថា **សំវេសិត្វា** សេចក្ដីថា នាយនិរយបាលចាប់សត្វនរកដែលមានអត្តភាពកម្ពស់ ៣ គាវុត ឲ្យដេកលើផែនលោហៈដែលឆេះសន្ធោសន្ធៅ ។

បទថា **កុឋារីហិ** សេចក្ដីថា ចាំងដោយដឹងធំប្រមាណប៉ុនផ្ទះ ។ លោហិតហូរជាស្ទឹង ។ លោហិតបាញ់ឡើងពីសត្វនរកត្រង់កន្លែងដែលចាំងហើយ ។ ទុក្ខដ៏ធំកើតឡើង នឹងកាលចាំង ក៏ចាំងធ្វើឲ្យជាចំរៀក ចាំងចេញជាចំណែក ៨ ចំរៀកខ្លះ ៦ ចំរៀកខ្លះ ដូចតុះឧស ។ បទថា **វាសីហិ** បានដល់ កាំបិតដែលមានប្រមាណប៉ុនចង្អេរខ្នាតធំ ។ កាលចាំងដោយកាំបិតទាំងនោះ ក៏ចាំងតាំងពីស្បែកទៅដរាបដល់ឆ្អឹង អវយវៈដែលចាំងចេញហើយៗ រមែងតាំងនៅតាមប្រក្រតីដូចដើម ។ បទថា **រថេ យោជេត្វា** សេចក្ដីថា ទឹមរថដែលឆេះសន្ធោសន្ធៅដោយប្រការទាំងពួង ព្រមទាំងនឹម ទ្រូង ដុំ និងជន្ទួញ ។ បទថា

**មហន្តំ** បានដល់ មានប្រមាណប៉ុនផ្ទះកំពូលខ្នាតធំ ។ បទថា **អាកោចេន្តិ** សេចក្តីថា នាយនិរយបាលនឹងសំពងដោយញញួរដែក ដែលឆេះសន្ធោសន្ធៅ ហើយបន្តាប់ឲ្យសត្វនរកឡើង ។ បទថា **សកឹម្ពិឧទ្ធំ** សេចក្តីថា សត្វនរកឆេះដោយកំសួលពពុះអណ្តែតឡើងទៅខាងលើខ្លះ លិចចុះខាងក្រោមខ្លះ អណ្តែតទៅខាងទទឹងខ្លះ ដូចគ្រាប់បាយដែលគេដាក់ទៅក្នុងឆ្នាំងបាយ ដែលកំពុងពពុះដូច្នោះ ។

បទថា **ភាគសោ មិតោ** បានដល់ បែងចែកចំណែកទុកជាចំណែកប៉ុនៗគ្នា ។ បទថា **បរិយន្តោ** ប្រែថា ហោមព័ទ្ធដោយជុំវិញ ។ បទថា **អយសា** សេចក្តីថា ខាងលើជាគម្របដែក ។ បទថា **សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ** សេចក្តីថា ផ្សាយទៅហើយយ៉ាងនេះក៏តាំងនៅ ក៏ភ្នែករបស់អ្នកដែលឈរសម្លឹងមើលនៅក្នុងទីឆ្ងាយប្រមាណ ១០០ យោជន៍ដោយជុំវិញ ភ្នែកនឹងខ្វាតចេញមកដូចកូនបូលៗ ទាំងគូ ។ បទថា **ន សុករំ អក្ខាតេន បាបុណិតុំ** មានអធិប្បាយថា សូម្បីនឹងពោលពណ៌នាទៅទាំងរយឆ្នាំ ទាំងពាន់ឆ្នាំ ដែលឈ្មោះថានរកមានទុក្ខយ៉ាងនេះ មិនមែនជារបស់ដែលធ្វើបានដោយងាយ (គឺឧបមាបានដោយលំបាក) ។

**[១៤៤]** បទថា **ទន្តុល្លេហកំ** គឺ ប្រើធ្មេញ អធិប្បាយថា ច្រិបផ្តាច់ស្មៅដោយធ្មេញ ។

**[១៤៧]** បទថា **រសាទោ** បានដល់ បុគ្គលពាលបរិភោគដោយការជាប់ចិត្តក្នុងរស ដោយតម្រេកក្នុងរសអាហារ ។

**[១៤៩]** បទថា **អញ្ញមញ្ញខាទិកា** ប្រែថា មានតែការស៊ីគ្នាឯង ។

**[១៥០]** បទថា **ទុព្វណ្ណោ** ប្រែថា មានរូបអាក្រក់ ។ បទថា **ទុទ្ទសិកោ** បានដល់ មានរូបគួរខ្លាច ដូចរូបយក្ខដែលគេធ្វើទុកដើម្បីបន្លាចក្មេង ។ បទថា **ឱកោដិមកោ** បានដល់ ជាមនុស្សតឿ កខ្វី ពោះកំប៉ោង ។ បទថា **កាណោ** បានដល់ ជាមនុស្សខ្វាក់ភ្នែកម្ខាង ឬភ្នែកខ្វាក់ទាំងពីរខាង ។ បទថា **កុណី** បានដល់ ជាមនុស្សកំបុតដៃម្ខាង ឬមានកំបុតដៃទាំងពីរខាង ។ បទថា **បក្ខហតោ** ប្រែថា ជាមនុស្សពិការ ។ បទថា **សោកាយេន** ជាដើម លោកប្រារព្ធដើម្បីសម្តែងដល់ការចូលទៅចងសេចក្តីទុក្ខរបស់សត្វក្នុងអបាយភូមិនេះ ។

**[១៥១]** បទថា **អលិគ្គហេន** គឺ ដោយសេចក្តីថា ចាញ់ ។ បទថា **អនុពន្ធំ និគច្ឆេយ្យ** សេចក្តីថា ព្រោះសម្បត្តិគ្រប់យ៉ាងចំនួនច្រើនរបស់អ្នកបរាជ័យមិនទាន់ល្មមឲ្យដល់អ្នកឈ្នះ ដូច្នោះ គេទើបត្រូវឃុំឃាំងទៀត ។ បទ

ថា *កេវលា បរិបូរាពាលភូមិ* សេចក្តីថា ជនពាលបំពេញទុច្ចរិត ៣ យ៉ាង បរិបូណ៌ហើយ រមែងកើតក្នុងនរក តែដោយសំណល់នៃកម្មដែលសល់ក្នុងនរក នោះ សូម្បីគេនឹងបានត្រឡប់មកកើតជាមនុស្ស ក៏ត្រូវកើតក្នុងត្រកូលថោកទាប ទាំង ៥ ប្រសិនបើនៅធ្វើទុច្ចរិត ៣ ទៀត ក៏ត្រូវកើតក្នុងនរក ទាំងអស់នេះ ឈ្មោះថាជាពាលភូមិដ៏សម្បូរណ៍គ្រប់គ្រាន់ ។

**[១៥២]** បទមានជាដើមថា **បណ្ឌិតលក្ខណានិ** គប្បីជ្រាបដោយទំនង ដូចពោលហើយនោះឯង ។ ក៏បទទាំងឡាយមានជាដើមថា **សុចិន្តិតចិន្តី** ក្នុង និទ្ទេសនេះ គប្បីប្រកបចូលដោយអំណាចនៃមនោសុចរិតជាដើម ។

**[១៥៨]** បទថា **សីសន្ហាតស្ស** បានដល់ ទ្រង់ស្រង់ និងកក់ព្រះ សិរសាដោយទឹកក្រអូប ។ បទថា **ឧបោសថិកស្ស** បានដល់ ទ្រង់សមាទាន អដ្ឋឧបោសថហើយ ។ បទថា **ឧបរិបាសាទវរគតស្ស** ប្រែថា កាលប្រថាប់ នៅក្នុងមហាប្រាសាទជាន់លើ គឺ ទ្រង់សោយសុធាភោជន ស្តេចចូលកាន់បន្ទប់ ដ៏មានសិរី ខាងលើមហាប្រាសាទ ទ្រង់រំពឹងដល់សីលទាំងឡាយ ។

បានឮមកថា គ្រានោះ ព្រះរាជាតើនឡើងពីព្រលឹម ហើយទ្រង់លះបង់ ព្រះរាជទ្រព្យមួយសែនថ្វាយមហាទាន ស្រោចស្រប់ព្រះសិរសាដោយគន្ធោទក

អស់ ១៦ ឆ្នាំង ហើយសោយព្រះក្រយាហារពេលព្រឹករួច ទ្រង់ចៀងស្នាម្នាង ដោយសំពត់សបរិសុទ្ធិ អង្គុយចម្រើនសមាធិលើព្រះបន្ទំដ៏មានសិរី លើប្រាសាទ ប្រថាប់អង្គុយរំពឹងដល់បុណ្យ គឺ ទាន ការទូន្មានចិត្ត និងសេចក្ដីសង្រួមរបស់ព្រះអង្គ ។ នេះជាធម្មតារបស់ស្ដេចចក្រពត្តិទាំងពួង ។

កាលស្ដេចចក្រពត្តិទាំងនោះ កំពុងពិចារណាដល់បុណ្យទាំងនុ៎ះឯង ចក្ររតន៍ជាទិព្វកើតឡើងដោយបុញ្ញកម្មជាបច្ច័យ មានប្រការដូចពោលហើយ មានឧតុជាសមុដ្ឋាន មានលក្ខណៈដូចជាដុំកែវមណីពណ៌ខៀវ ក៏កើតប្រាកដឡើង ដូចញែកផ្ទៃទឹកមហាសមុទ្រឡើង មកខាងបស្ចិមទិស ឧបមាដូចជាធ្វើអន្ទង់នភាកាសឲ្យស្រស់ល្អ ។ ក៏រតនៈនោះ លោកហៅថា ជាទិព្វ ព្រោះប្រកបទៅដោយអានុភាពជាទិព្វ ។ ដែលឈ្មោះថា **សហស្សារ** ព្រោះមានកាំមួយពាន់ ។ ឈ្មោះថា **សនាភិកំ សនេមិកំ** ព្រោះប្រកបទៅដោយកង់ និងដុំ ។ ឈ្មោះថា **សព្វាការបរិបូរំ** ព្រោះបរិបូណ៌ទៅដោយអាការគ្រប់យ៉ាង ។

គប្បីជ្រាបវិន័យក្នុងអាការទាំងនោះ ដូចតទៅនេះ ៖

ឈ្មោះថា **ចក្ករតន៍** ព្រោះជាចក្រ និងជារតនៈ ដោយអត្ថថា ញុំាង សេចក្ដីត្រេកអរឲ្យកើត ។ ក៏ដុំរបស់ចក្ករតនៈ ដែលលោកពោលថា ព្រមទាំង

ខ្នងកង់ និងដុំនេះ សម្រេចហើយដោយកែវឥន្ទនិល ។ ក៏ត្រង់កណ្តាលដុំនោះ មានប្រហោងសម្រេចដោយប្រាក់ដ៏ល្អ មានអាការដូចជាការសើចញញឹមរបស់បុគ្គលដែលមានធ្មេញស្អាតជិតស្និទ្ធល្អ ។ និងពាសទៅដោយផែនប្រាក់ទាំងពីរខាង ។ គឺ ទាំងផ្នែកខាងក្រៅ និងផ្នែកខាងក្នុង ដូចមណ្ឌលនៃព្រះចន្ទ ។ ក៏ដុំដែលពាសទៅដោយផែនប្រាក់ និងប្រហោងទាំងនោះ ប្រាកដជាដូចជាស្នាមគំនូរដែលកំណត់ទុកក្នុងស្ថានដ៏សមរម្យ ត្រូវបានធ្វើទុកហើយដោយល្អ នេះជាសេចក្តីបរិបូណ៌ដោយអាការគ្រប់យ៉ាងរបស់ដុំចក្ករតន៍នោះ ។

ក៏ចក្ករតន៍ដែលលោកពោលថា មានកាំមួយពាន់ ប្រកបទៅដោយកាំពួកណា កាំពួកនោះសម្រេចដោយរតនៈ ៧ ប្រការ បរិបូរណ៍ដោយរស្មី ដូចរស្មីនៃព្រះអាទិត្យ ។ សូម្បីកាំទាំងនោះក៏ប្រាកដជា បានចែកទុកហើយដោយល្អដូចគ្នា ដូចគំនូរដែលគេគូរជាប់នឹងថ្នាំងទឹកកែវមណីជាដើម ។ នេះជាសេចក្តីបរិបូណ៌ដោយអាការគ្រប់យ៉ាងនៃកាំទាំងឡាយរបស់ចក្ករតន៍នោះ ។

ក៏ចក្ករតន៍ដែលលោកពោលថា ព្រមដោយកង់ ប្រកបទៅដោយកង់ណា កង់នោះសម្រេចដោយកែវប្រវាឡ មានពណ៌ក្រហមបរិសុទ្ធិគួរស្រឡាញ់ ដូចជារស្មីនៃព្រះអាទិត្យដែលកំពុងបញ្ចេញពន្លឺ ដូច្នោះ ។

ក៏ផ្ទៃរបស់កង់នោះ ជាផែនមាសជម្ពូនុទពណ៌ក្រហម មានឈ្មោះថា សាម្ងន់គួរលើកសរសើរ និងមានធ្នូតគំនូសជាវង់មូលប្រាកដជា រៀបរយហើយដោយល្អ នេះជាសេចក្ដីបរិបូណ៌ដោយអាការគ្រប់យ៉ាងរបស់ដុំនៃចក្ករតន៍ដែលជាទិព្វនោះ ។

ក៏ផ្នែកខាងខ្នងមណ្ឌលរបស់ដុំនៃចក្ករតន៍ជាទិព្វ មានឈើសម្រេចអំពីកែវប្រវាឡ ដូចបំពង់ឈើបបុសដែលមានប្រហោងខាងក្នុង ប្រដាប់ជារង្វង់មូលនៅត្រង់កាំម្ខាង ១០ ៗ ។ ឈើសម្រេចដោយកែវប្រវាឡណា វេលាខ្យល់បក់ក៏បញ្ចេញសំឡេងដ៏ពីរោះ បណ្ដាលឲ្យកើតសេចក្ដីរីករាយចិត្ត ក្ងើតក្ងើន ដូចសំឡេងរបស់តន្ត្រីប្រកបដោយអង្គ ៥ ដែលប្រគុំដោយអ្នកស្ទាត់ជំនាញ ដូច្នោះ ។ ក៏ឈើសម្រេចដោយកែវប្រវាឡនោះឯង មានស្វេតឆត្រនៅខាងលើ មានកម្រងផ្ការៀបជារបៀបទាំងពីរខាងដោយប្រការដូចពណ៌នាមកនេះ ទើបមានសីហ-បញ្ជរពីរខាង ខាងក្នុងកាំនៃដុំទាំងពីររបស់ទិព្វចក្ររតន៍ ដែលវង់ទៅដោយកង់ចូលទៅបន្ថែមភាពស្រស់ល្អនៃឈើ ដែលសម្រេចដោយកែវប្រវាឡមួយរយសម្រាប់ទ្រទ្រង់ដល់ស្វេតឆត្រមួយរយ មានក្បួនផ្កាគ្របជារបៀបដល់ទៅពីររយជាបរិវារ ដែលមានក្រុមនៃកែវមុក្ដាទាំងពីរព្យួរនៅខាងលើ ល្អគួរដល់ការទស្សនា

តាមធម្មជាតិរបស់អាកាសគង្គា មានអានុភាពបញ្ចេញពន្លឺរស្មី ដូចពន្លឺនៃព្រះចន្ទពេញបូណ៌មី ហើយក៏ចេញទៅប្រមាណមួយជួរដើមត្នោត ចុងបំផុតដោយក្រុមសំពត់កម្ពលពណ៌ក្រហមដូចពន្លឺព្រះអាទិត្យដ៏ស្រទន់ ចក្កទាំង ៣ ប្រាកដជាដូចវិលទៅព្រមៗ គ្នា ដោយការវិលទៅក្នុងអាកាសព្រមដោយចក្ករតន៍ ។ នេះជាសេចក្តីបរិបូណ៌ដោយអាការគ្រប់យ៉ាង ដោយប្រការទាំងពួងរបស់ចក្ករតន៍នោះ ។

ក៏កាលពួកមនុស្សបរិភោគអាហារខែត្រជាក់ តាមប្រក្រតីស្រេចហើយអង្គុយលើអាសនៈដែលគេក្រាលទុក ត្រង់ទ្វារផ្ទះរៀងៗ ខ្លួន សន្ទនាគ្នាដល់ហេតុការណ៍រឿងរ៉ាវតាមដែលប្រព្រឹត្តទៅ កាលពួកក្មេងតូចៗ (ក្មេងជំទង់) កំពុងលេងនៅលើថ្នល់ និងផ្លូវបែកជាបួនជាដើម ចក្ករតន៍ជាទិព្វនោះឯង ក៏ធ្វើដំណើរបែរមុខឆ្ពោះមកកាន់រាជធានី ដូចចូលទៅបន្ថែមសេចក្តីល្អ មែកឈើចុងឈើ បន្ថែមសម្រស់រហូតដល់បរិវេណក្នុងព្រៃស្រោង ធ្វើឲ្យពួកសត្វផ្សៀងត្រចៀកស្តាប់នូវសំឡេងដ៏ពីរោះ ដែលឮបានចម្ងាយ ១២ យោជន៍ ជាហេតុធ្វើឲ្យឃើញនូវពន្លឺដ៏រុងរឿងមានប្រការផ្សេងៗ ចម្ងាយមួយរយយោជន៍ ដូចជាប្រកាសបុញ្ញានុភាពនៃស្តេចចក្រពត្តិ ។ កាលចក្ករតន៍នោះ បញ្ជូនសំនៀងទៅ

ទូទាំងព្រៃទាំ៉ះឯង មនុស្សទាំងនោះគិតថា សំឡេងនេះមកពីណាហ្ន៎ ខ្លះក៏ងើយមើលទៅទិសបូព៌ា ខ្លះក៏និយាយគ្នាយ៉ាងនេះថា លោកដ៏ចម្រើនទាំងឡាយចូរមើលវត្ថុអស្ចារ្យរាល់ៗ យប់ ព្រះចន្ទពេញវង់តែមួយដួង តែថ្ងៃនេះរះឡើងពីរដួង ក៏ព្រះចន្ទទាំងគូនេះ អណ្តែតឡើងទៅកាន់នភាកាស ឧបមាដូចស្តេចហង្សទាំងគូ ហោះហើរនៅក្នុងនភាកាស ដូច្នោះ ។ មួយពួកទៀតពោលជំទាស់ថា នែ៎សម្លាញ់ លោកនិយាយអ្វី ព្រះចន្ទពីរដួងឡើងព្រមគ្នាលោកធ្លាប់ឃើញនៅទីណាខ្លះ នោះគឺ ព្រះអាទិត្យដែលទ្រទ្រង់ទុកនូវរស្មីដ៏ក្តៀវក្លា មានពណ៌ក្រហមលឿងផុសឡើងមកហើយមិនមែនឬ មួយពួកទៀត ពោលចំអកឡកឡឺយពួកទាំងនោះថា លោកឆ្កួតទៅហើយឬ ព្រះអាទិត្យទើបតែលិចទៅនេះឯងមិនមែនឬ ព្រះអាទិត្យនោះនឹងរះឡើងតាមព្រះចន្ទពេញវង់នេះបានយ៉ាងណា តែនេះច្បាស់ជាវិមានរបស់អ្នកមានបុណ្យណាម្នាក់ ទើបរុងរឿងទៅដោយពន្លឺភ្លឺស្វាងនៃរតនៈមិនមែនតិច ។ ជនទាំងនោះសូម្បីទាំងអស់ ផ្សេងៗ គ្នា ដោយការឃើញចំណែកពួកជនខាងក្រោយ ទើបពោលយ៉ាងនេះថា ពួកលោកទាំងឡាយនិយាយផ្តេសផ្តាស់ឲ្យច្រើនរឿងធ្វើអ្វី នោះមិនមែនព្រះចន្ទពេញវង់ មិនមែនព្រះអាទិត្យមិនមែនវិមានរបស់ទេវតា ដែលពិតសិរីសម្បត្តិបែបនេះ មិនបានកើតឡើងដើម្បី

វត្ថុទាំងនោះ តែវត្ថុនោះប្រហែលជាចក្ករតន៍ ។

កាលការបរចាប្រកែកតតាំងនៅតែប្រព្រឹត្តទៅដូច្នេះ ចក្ករតន៍នោះ ក៏លះចនមណ្ឌលផ្ទោះត្រង់មក ។ តពីនោះ កាលអ្នកទាំងនោះនិយាយគ្នាថា ចក្ករតន៍នេះ កើតឡើងដើម្បីអ្នកណាហ្ន៎ ក៏មានអ្នកនិយាយឡើងថា ចក្ករតន៍នេះមិនបានកើតឡើងដល់អ្នកណាដទៃក្រៅពីមហារាជរបស់ពួកយើងទាំងឡាយ ទ្រង់បំពេញកាពជាស្តេចចក្រពត្តិសម្បូរណ៍ហើយ ចក្ករតន៍នេះកើតដោយបុណ្យរបស់ព្រះអង្គពិតប្រាកដ ។

លំដាប់នោះ ទាំងមហាជនពួកនោះ ទាំងមនុស្សដទៃៗ ដែលមើលឃើញគ្រប់ៗ គ្នា ក៏ដើរតាមចក្ករតន៍ទៅដោយលំដាប់ ។ សូម្បីចក្ករតន៍នោះ ក៏ប្រទក្សិណជុំវិញព្រះនគរទៅជរាបដល់ទីបំផុតនៃកំពែងអស់ ៧ ជុំ ដូចជាការប្រកាសឲ្យមនុស្សទូទៅដឹងនូវសភាពដែលខ្លួន អណ្តែតមកដើម្បីជាសម្បត្តិរបស់ព្រះរាជាតែមួយព្រះអង្គ ធ្វើប្រទក្សិណខាងក្នុងព្រះរាជវាំងរបស់ព្រះរាជាហើយប្រតិស្ឋានទៅក្នុងទីជិតសីហបញ្ជរផ្នែកខាងទិសឧត្តររបស់ព្រះរាជវាំង ដូចត្រូវឈើគន្លឹះខ្ទាស់ទុក ដើម្បីឲ្យមហាជនបូជាដោយគ្រឿងសក្ការៈ មានរបស់ក្រអូបនិងផ្កាឈើជាដើមបានដោយសប្បាយ ។

ក៏កាលចក្ករតន៍ជាទិព្វនោះ តាំងនៅដោយប្រការដូច្នេះហើយ ព្រះរាជា-ធិបតីឃើញកនរស្មី មានព្រះទ័យប្រាថ្នានឹងទតព្រះនេត្រសរសើរចក្រកែវដែលចូលទៅត្រង់ប្រហោងនៃសីហបញ្ជរ ធ្វើឲ្យខាងក្នុងប្រាសាទរុងរឿងដោយរស្មីកែវបន្តិឲ្យកើតសេចក្តីត្រេកអរមានប្រការផ្សេងៗ សូម្បីពួកជនដែលហែហម ក៏នាំគ្នាក្រាបទូលមូលហេតុនៃចក្ករតន៍នោះ ដោយពាក្យសុទ្ធតែគួរស្រឡាញ់ កាលនោះ ព្រះរាជាធិបតីមានព្រះវរកាយពោរពេញទៅដោយបីតិបាមោជ្ជៈយ៉ាងខ្លាំងមានព្រះឧស្សាហ៍ ចេញចាកពីព្រះបល្ល័ង្ក ទ្រង់ក្រោកអំពីអាសនៈ ស្តេចទៅកាន់ទីជិតសីហបញ្ជរ ទតឃើញចក្ករតន៍ហើយ ទើបទ្រង់ព្រះចិន្តនាការថា ក៏យើងបានឮពាក្យបុរាណលោកជំណាលមកថា ។លៗ ដូច្នេះជាដើម ។ ព្រោះដូច្នោះលោកទើបពោលថា គ្រាទតឃើញ ទើបទ្រង់មានព្រះតម្រិះថា ។លៗ យើងគប្បីបានជាស្តេចចក្រពត្តិពិតប្រាកដដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ ហោតិ រាជា ចក្កវត្តិ** សេចក្តីថា សួរថាព្រះរាជារមែងបានជាស្តេចចក្រពត្តិដោយហេតុមានប្រមាណប៉ុនណា ។

ឆ្លើយថា ដោយហេតុត្រឹមតែចក្ករតន៍ហោះឡើងកាន់អាកាស ត្រឹមតែកម្ពស់មួយម្រាមដៃក៏បាន ពីរម្រាមដៃក៏បាន ។

ឥឡូវនេះ កាលនឹងសម្ដែងដល់ប្រការដែលព្រះរាជាគប្បីធ្វើក្នុងវិធីរាជា-បកិសេកជាស្ដេចចក្រពត្តិ ទើបត្រាស់ពាក្យមានជាដើមថា **អថ ខោ ភិក្ខវេ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **ឧដ្ឋាយាសនា** បានដល់ ទ្រង់ក្រោកអំពីអាសនៈដែលប្រថាប់អង្គុយ ស្ដេចមកជិតចក្ករតន៍ ។ បទថា **សុវណ្ណភិង្ការំ គហេត្វា** សេចក្ដីថា ទ្រង់លើកសុវណ្ណភិង្ការ មានប្រហោងស្រដៀងនឹងប្រមោយដំរី ទ្រង់ចាប់កុណ្ឌីទឹកដោយព្រះហស្ថឆ្វេង (ទ្រង់ប្រោះព្រំចក្ករតន៍ដោយព្រះហស្ថស្ដាំ) ហើយត្រាស់ថា ចក្ករតន៍ដចម្រើន ចូរអណ្ដែតទៅ ចក្ករតន៍ដ៏ចម្រើន ចូរមានជ័យជំនះដ៏ក្រៃលែង ។ បទថា **អនវត្តេ រាជា ចក្កវត្តិ សទ្ធិំ ចាតុរង្គិនិយា សេនាយ** សេចក្ដីថា ក៏ក្នុងខណៈដែលព្រះរាជាទ្រង់ប្រោះព្រំទឹក ប្រាថ្នាភាពជាស្ដេចចក្រពត្តិ ហើយត្រាស់ថា ចក្ករតន៍ដ៏ចម្រើន ចូរមានជ័យជំនះដ៏ធំក្រៃ-លែងចុះ ចក្ករតន៍នុះឯងក៏អណ្ដែតឡើងកាន់វេហាស៍ ។ ព្រះរាជានោះ រមែងបានឈ្មោះថា ជាស្ដេចចក្រពត្តិក្នុងវេលាដែលចក្ករតន៍អណ្ដែតទៅ ។ ក៏កាលចក្ករតន៍អណ្ដែតទៅហើយ ព្រះរាជាដែលកំពុងជាប់តាមចក្ករតន៍នោះទៅ ស្ដេចក៏ឡើងកាន់យានដ៏ប្រសើររបស់ព្រះអង្គ ហោះឡើងកាន់វេហាស៍ ដោយប្រការដូច្នេះ ។

លំដាប់នោះ ជនជាបរិវារ និងអ្នករាជការក្នុងរាជដំណាក់របស់ព្រះអង្គខ្លះក៏កាន់ឆត្រ និងចាមរជាដើម បន្ទាប់អំពីនោះទៅក៏ដល់ក្រុមឥស្សរជន ចាប់តាំងពីឧបរាជសេនាបតី ដល់ព្រមទៅដោយកម្លាំងទ័ពរបស់ព្រះអង្គ ដែលតាក់តែងគ្រឿងយុទ្ធភ័ណ្ឌ មានអាវក្រោះ និងក្រោះ ៦ ប្រការជាដើម ប្រដាប់ដោយទង់ជ័យ ទង់សំពត់ដែលលើកឡើង រុងរឿងព្រមទៅដោយពន្លឺ ដែលនាំមកប្រដាប់វត្ថុច្រើនប្រការ ខ្លះហោះឡើងកាន់វេហាស៍ហែហមព្រះរាជាតែមួយព្រះអង្គឯង ។ ក៏ដើម្បីនឹងសង្គ្រោះប្រជាជន ពួកអ្នកបម្រើការងាររបស់ព្រះរាជាទើបប្រកាសទូទាំងព្រះនគរថា អ្នកទាំងឡាយ ចក្ករតន៍កើតហើយដល់ព្រះរាជារបស់ពួកយើង ពួកអ្នកចូរប្រញាប់ចាត់ចែងតែងខ្លួនតាមឋានៈរៀងៗ ខ្លួន រួសរាន់មកប្រជុំគ្នាចុះ ។ ក៏មហាជនពួកខ្លះ លះបង់ការងារគ្រប់យ៉ាងដែលត្រូវធ្វើតាមប្រក្រតី កាន់គ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាឈើជាដើម ប្រជុំគ្នាហើយតាមសម្លេងនៃចក្ករតន៍នុ៎ះឯង សូម្បីមហាជនទាំងអស់នោះ ក៏ហោះឡើងកាន់វេហាស៍ ហែហមព្រះរាជាតែមួយព្រះអង្គ គឺ អ្នកណាប្រាថ្នានឹងធ្វើដំណើររួមទៅជាមួយព្រះរាជា អ្នកនោះក៏ទៅតាមអាកាស ដោយប្រការដូច្នេះ ។ ទើបមានបរិស័ទមកប្រជុំគ្នាទាំងទទឹង ទាំងបណ្តោយ ប្រមាណ ១២ យោជន៍ ក្នុង

បរិស័ទនោះ មិនមានសូម្បីតែម្នាក់ដែលនឹងមានអវយវៈពិកលពិការ ឬស្លៀកដណ្តប់សៅហ្មង ព្រះរាជាទើបមានបរិវារដែលល្អស្អាត ។ ធម្មតា បរិស័ទរបស់ស្តេចចក្រពត្តិធ្វើដំណើរទៅតាមអាកាស ដូចបរិស័ទរបស់វិទ្យាធរ រមែងដូចរតនៈដែលពាសពេញនៅលើផែនដីដោយកែវឥន្ទនិល ព្រោះដូច្នោះ លោកទើបពោលទុកថា ស្តេចចក្រពត្តិព្រមដោយចាតុរង្គិនីសេនា ក៏ហែហមស្តេចទៅ ។

សូម្បីចក្ករតន៍នោះ ក៏អណ្តែតទៅតាមអាកាសប្រទេស មិនខ្ពស់ពេកនៅក្នុងលំដាប់នៃចុងឈើ អាចឲ្យអ្នកសម្លឹងមើលដឹងបានថា នោះព្រះរាជា នោះឧបរាជ នោះសេនាបតី ឧបមាដូចអ្នកដែលត្រូវការផ្កាឈើ ផ្លែឈើ ឬស្លឹកឈើ ឈរត្រង់ផែនដី ក៏អាចនឹងបេះយកវត្ថុទាំងនោះបានដោយសប្បាយ ។ អ្នកណាប្រាថ្នានឹងទៅក្នុងឥរិយាបថណា មានឈរជាដើម អ្នកនោះក៏ទៅបានដោយឥរិយាបថនោះ ។ ចំណែកអ្នកដែលជាប់ចិត្តក្នុងសិល្បៈ មានចិត្រកម្មជាដើម ក៏ញ៉ាំងធុរកិច្ចរបស់ខ្លួនបានក្នុងអាកាសនោះ ។ នៅផែនដីធ្លាប់ដំណើរធុរកិច្ចយ៉ាងណា ក្នុងអាកាសក៏អាចដំណើរធុរកិច្ចគ្រប់យ៉ាងបាន ដូច្នោះ ចក្ក-រតន៍នោះ នាំបរិស័ទរបស់ស្តេចចក្រពត្តិកាត់តម្រង់ភ្នំសិនេរុរាជ ទៅផ្លូវផ្នែកខាងឆ្វេង កន្លងផ្ទៃមហាសមុទ្រដរាបដល់ក្រុងបុព្វវិទេហទ្វីប ប្រមាណ ៨,០០០

យោជន៍ ។ ចក្ករតន៍នោះ ប្រតិស្ឋាននៅលើអាកាស ដូចត្រូវគេសៀតគន្លឹះទុកខាងលើភូមិភាគដែលសមគួរដល់ជុំទំរបស់បរិស័ទទទឹង ១២ យោជន៍ វាស់ដោយជុំវិញបាន ៣៦ យោជន៍ រកឧបករណ៍ធ្វើអាហារបានសប្បាយ សម្បូរណ៍ដោយម្ហូប និងទឹក មានផ្ទៃដីស្អាតរាបស្មើគួររីករាយ ។ កាលនោះ មហាជនចុះហើយដោយសញ្ញាណនោះ ធ្វើកិច្ចគ្រប់យ៉ាង ដូចជាងូតទឹក បរិភោគអាហារជាដើមតាមការពេញចិត្ត ។ ព្រោះហេតុនោះ លោកទើបពោលថា ចក្ករតន៍ប្រតិស្ឋាននៅក្នុងប្រទេសណា ស្តេចចក្រពត្តិក៏ចូលប្រថាប់ក្នុងប្រទេសនោះ ព្រមដោយចាតុរង្គិនីសេនា ។

ក៏កាលស្តេចចក្រពត្តិទ្រង់ចូលទៅប្រថាប់ហើយយ៉ាងនេះ ព្រះរាជាក្នុងប្រទេសនោះៗ ពេលបានស្តាប់ថា ចក្កមកហើយ ក៏ត្រាស់បង្គាប់ប្រជុំពលនិកាយមិនត្រៀមច្បាំង ក៏ក្នុងវាងដែលចក្ករតន៍កើតឡើងហើយនោះឯង មិនមានអ្នកណានឹងខ្វាំងក្លាចាប់អាវុធឡើងតស៊ូ ។ នេះជាអានុភាពរបស់ចក្ករតន៍ ។

ក៏ដោយអានុភាពរបស់ចក្ក ព្រះរាជាដែលសត្រូវរបស់ស្តេចចក្រពត្តិនោះរមែងដល់សេចក្តីស្ងប់ទៅ ដោយហេតុនោះឯង ចក្ររបស់ព្រះរាជាធិបតីអង្គនោះ ទើបហៅថា **អរិន្ទមៈ** ។

ព្រោះដូច្នោះ ព្រះរាជាទាំងនោះគ្រប់ៗ ព្រះអង្គ ខ្លះក៏កាន់យកសម្បត្តិដែលសមគួរដល់សិរីរាជសម្បត្តិរបស់ខ្លួនៗ បង្អោនសិរសាចំពោះស្តេចចក្រ-ពត្តិ ធ្វើការបូជាព្រះបាទរបស់ព្រះអង្គ ធ្វើវិធីអភិសេកដោយពន្លឺនៃកែវមណីត្រង់ព្រះមោលីរបស់ខ្លួន ព្រមចាញ់ដោយពោលពាក្យជាដើមថា សូមយាងចុះមហារាជ ដូច្នេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកព្រះរាជាណាដែលជាសត្រូវទៅក្នុងទិសខាងកើត ។ល។ បពិត្រមហារាជ សូមព្រះអង្គទ្រង់ទូន្មានចុះ ។ បណ្តាបទទាំងនោះ បទថា **ស្វាគតំ** ប្រែថា ស្តេចមកល្អហើយ ។ មានអធិប្បាយថា កាលព្រះរាជាពួកខ្លះស្តេចមក ប្រជាជនសោកសៅ កាលស្តេចទៅ ប្រជាជនរីករាយ កាលព្រះរាជាពួកខ្លះស្តេចមក ប្រជាជនរីករាយ កាលស្តេចទៅប្រជាជនសោកសៅ ព្រះអង្គដូចជាព្រះរាជាផ្នែកខាងក្រោយ គឺ កាលវេលាស្តេចមក ប្រជាជនរីករាយ វេលាស្តេចទៅ ប្រជាជនសោកសៅ ព្រោះដូច្នោះ ដំណើរមករបស់ព្រះអង្គទើបឈ្មោះថា ស្តេចមកល្អហើយ ។ ក៏កាលពួកស្តេចប្រទេសរាជ ក្រាបទូលដូច្នេះហើយ សូម្បីស្តេចចក្រពត្តិក៏មិនបានត្រាស់ថា ពួកលោកត្រូវបញ្ជូនបណ្ណា-ការដល់យើង រហូតដល់អស់វេលាប៉ុណ្ណេះឆ្នាំ ទាំងទ្រង់មិនរឹបយកសម្បត្តិរបស់

ព្រះរាជាអង្គនេះ ទៅឲ្យព្រះរាជាអង្គនោះ តែទ្រង់លើកយកនូវអកុសលកម្មបថ មានបាណាតិបាតជាដើម ដោយបញ្ញាដែលសមគួរដល់ភាវៈដែលព្រះអង្គជាធម្ម-រាជា ទ្រង់សម្ដែងធម៌ដោយព្រះសូរសេនដែលគួរស្រឡាញ់ គួរពេញចិត្ត ដោយន័យជាដើមថា ដែលឈ្មោះថា បាណាតិបាតនេះ អ្នកណាសេព ចម្រើន ធ្វើឲ្យច្រើន រមែងប្រព្រឹត្តទៅដើម្បីនរក ហើយប្រកាសព្រះឱវាទមានជាដើមថា មិនគួរសម្លាប់សត្វ ដូច្នេះ ។

ព្រោះហេតុនោះ លោកទើបពោលថា ស្ដេចចក្រពត្តិត្រាស់បន្ទាប់យ៉ាងនេះថា អ្នករាល់គ្នាមិនគួរសម្លាប់សត្វ ។បេ។ អ្នកទាំងឡាយចូរគ្រប់គ្រងស្រុកក្រុងតាមសមគួរចុះ ដូច្នេះ ។

សួរថា ក៏ព្រះរាជាគ្រប់ព្រះអង្គព្រមទទួលឱវាទនេះ របស់ព្រះរាជាធិបតីឬ ។

ឆ្លើយថា ព្រះរាជាគ្រប់ព្រះអង្គមិនធ្លាប់ទទួលឱវាទនេះរបស់ព្រះពុទ្ធមកអំពីមុន តើនឹងទទួលឱវាទរបស់ព្រះរាជាធិបតីយ៉ាងណាបាន ព្រោះដូច្នោះ ព្រះរាជាពួកណា ជាអ្នកឆ្លាតវាងវៃ ព្រះរាជាទាំងនោះព្រមទទួល និងកាលព្រះរាជាគ្រប់ព្រះអង្គប្រព្រឹត្តតាម រមែងចម្រើន ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់

ពាក្យមានជាដើមថា **យេ ខោ បន ភិក្ខវេ** ដូច្នេះ ។ កាលស្ដេចចក្រពត្តិព្រះរាជទានព្រះឱវាទដល់អ្នកក្រុងបុព្វវិទេហៈយ៉ាងនេះ សោយព្រះក្រយាហារព្រឹកហើយ ចក្ករតន៍នោះ ក៏អណ្ដែតឡើងកាន់វេហាស៍ដោយកម្លាំងរបស់ស្ដេចចក្រពត្តិ ចុះកាន់សមុទ្រទិសខាងកើត ។ ចក្ករតន៍ចុះកាន់មហាសមុទ្រប្រមាណមួយយោជន៍ រលកក៏ខ្សរខ្សាយទៅ ដូចស្ដេចនាគហិតក្លិនថ្នាំហើយបិទពពារ ចក្ក-រតន៍តាំងនៅក្នុងមហាសមុទ្រ ដូចនៅក្នុងកែវពិទូរ្យ ដូច្នោះ ។ ក៏ក្នុងខណៈនោះឯង រតនៈផ្សេងៗ ដែលពាសពេញនៅក្នុងបាតនៃមហាសមុទ្រ ក៏ផុសពីមហា-សមុទ្រនោះ កកស្រទាប់ដរាបពេញប្រទេសនោះ (គឺត្រង់កន្លែងចក្ករតន៍) ដូចជាមកអបអរសាទរនូវបុណ្យរបស់ព្រះរាជាធិបតីអង្គនោះ ។ កាលព្រះរាជា និងរាជបុរស ឃើញផ្ទៃនៃបាតមហាសមុទ្រពេញទៅដោយរតនៈមានប្រការផ្សេងៗនោះ ទើបជនខ្លះកាន់យកមកពាក់ មកតាក់តែងតាមពេញចិត្ត ក៏កាលបរិស័ទកាន់យករតនៈតាមពេញចិត្តហើយ ចក្ករតន៍នោះក៏វិលត្រឡប់ និងកាលចក្ករតន៍នោះវិលត្រឡប់ បរិស័ទនៅខាងមុខ ព្រះរាជានៅត្រង់កណ្ដាល ចក្ករតន៍នៅត្រង់ទីបំផុត សូម្បីទឹកសមុទ្រនោះ ដូចជាត្រូវរស្មីនៃចក្ករតន៍លេបទុក ដូចជាមិនអាចទ្រាំនៅបាន ទើបញែកចេញចាកចក្ករតន៍នោះ និងទឹកមហាសមុទ្រនោះ

វិលទៅពីខាងក្រោយចក្ករតន៍នោះ ជាប់តាមទៅមិនដាច់ខ្សែ ។ ស្តេចចក្រពត្តិកាលទ្រង់មានជ័យជំនះយ៉ាងធំក្រៃលែងចំពោះបុព្វវិទេហទ្វីប ដែលមានមហាសមុទ្រទិសខាងកើតជាព្រំដែន ទ្រង់មានព្រះបំណងនឹងបានជ័យជំនះក្នុងជម្ពូ-ទ្វីប ដែលមានមហាសមុទ្រផ្នែកទិសខាងត្បូងជាព្រំដែន ទើបបែរព្រះភក្រ្តទៅកាន់សមុទ្រផ្នែកទិសទក្សិណ តាមមាគ៌ាដែលចក្ករតន៍បង្ហាញហើយ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ចក្ករតន៍នោះវិលអណ្តែតទៅទល់សមុទ្រផ្នែកទិសខាងកើត ហើយត្រឡប់វិលអណ្តែតទៅផ្នែកទិសខាងត្បូង ។

ក៏វិធីវិលត្រឡប់របស់ចក្ករតន៍នោះ ដែលវិលអណ្តែតទៅយ៉ាងនេះ ការជំនុំរបស់ពួកសេនា ការទៅរបស់ស្តេចប្រទេសរាជ ការប្រគល់អនុសាសន៍ដល់ព្រះរាជាប្រទេសរាជទាំងនោះ ការចុះកាន់សមុទ្រផ្នែកទិសទក្សិណ ការកាន់យករតនៈដែលហូរមកតាមខ្សែទឹកនៃមហាសមុទ្រ ទាំងអស់នេះ បណ្ឌិតគប្បីជ្រាបដោយន័យមុននោះឯង ។

ក៏ចក្ករតន៍នោះ កាលមានជ័យជំនះហើយ ក៏វិលអណ្តែតឆ្លងសមុទ្រផ្នែកខាងទិសទក្សិណសំដៅទៅជម្ពូទ្វីប មានផ្ទៃដីប្រមាណមួយសែនយោជន៍ ហើយ

វិលទៅដោយន័យដូចពោលហើយក្នុងកាលមុននោះឯង ។ ដើម្បីឈ្នះអមរគោ-យានទ្វីប កាលមានជ័យជំនះក្នុងអមរគោយានទ្វីប ដែលមានសមុទ្រជាព្រំដែននោះ ដោយទំនងនោះឯង ក៏វិលអណ្តែតឆ្លងសមុទ្រផ្នែកទិសបច្ចិមទៅ ដោយវិធីនោះឯង ដើម្បីឈ្នះឧត្តរកុរុទ្វីប ដែលមានផ្ទៃដីប្រមាណ ៨,០០០ យោជន៍ កាលមានជ័យជំនះក្នុងឧត្តរកុរុទ្វីបនោះ ដែលមានសមុទ្រជាព្រំដែន ដោយវិធីតែម្យ៉ាងដូចគ្នា ក៏វិលអណ្តែតឆ្លងមកពីសមុទ្រផ្នែកខាងទិសឧត្តរ ។ ស្តេចចក្រពត្តិទ្រង់សម្រេចភាពជាអ្នកជំក្រៃលែងក្នុងផែនដី មានមហាសមុទ្រទាំង ៤ ជាព្រំដែន ដោយប្រការដូចពណ៌នាមកនេះ ។ ស្តេចចក្រពត្តិនោះ មានជ័យជំនះគ្រប់ទិសដូច្នេះហើយ ទ្រង់ប្រាថ្នាទតសិរីរាជសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់ព្រមទាំងបរិស័ទ ហោះឡើងកាន់ផ្ទៃនភាកាស ត្រួតមើលទ្វីបធំទាំង ៤ ដែលមានទ្វីបតូចៗ ៥០០ ៗ ជាបរិវារ ដូចជាស្រះទាំង ៤ ដែលលម្អទៅដោយពួកឈើផ្សេងៗមានបទុម ឧប្បល និងបុណ្ឌរិក ដែលរីកស្គុះស្គាយ ដូច្នោះ ហើយស្តេចត្រឡប់មកកាន់រាជធានីដើមរបស់ព្រះអង្គតាមលំដាប់ ដោយមាគ៌ាដែលសម្តែងទុកហើយក្នុងចក្កវត្តិសូត្រ ។

គ្រានោះ ចក្ករតន៍នោះប្រតិស្ឋានទៅ ដូចជាការបន្ថែមទ្វារព្រះរាជវាំង

ឲ្យរឹតតែល្អស្អាត ក៏កាលចក្ករតន៍នោះប្រតិស្ឋានទៅដូច្នេះ កិច្ចដែលនឹងគប្បីធ្វើជាប់ទាក់ទងនឹងគប់ភ្លើងក្តី ការអុជប្រទីបក្តី មិនចាំបាច់មានក្នុងព្រះរាជវាំង ពន្លឺនៃចក្ករតន៍នោះឯង កម្ចាត់សេចក្តីងងឹតក្នុងយាមរាត្រីបាន ចំណែកមនុស្សពួកណាត្រូវការភាពងងឹត មនុស្សទាំងនោះក៏បានភាពងងឹត ដោយហេតុនោះ លោកទើបពោលថា **ទក្ខិណសមុទ្ទំ អជ្ឈោគាហេត្វា ។បេ។ ឯវរូបំ ចក្ករតនំ បាតុភវតិ** ដូច្នេះ ។

ក៏អាមាត្យរបស់ស្តេចចក្រពត្តិ កាលមានចក្ករតន៍ប្រាកដហើយយ៉ាងនេះ ក៏បង្គាប់ឲ្យធ្វើភូមិភាគឲ្យស្អាត ដែលជាទីនៅរបស់មង្គលហត្ថី តាមប្រក្រតី ឲ្យលាបស្រឡាបដោយរបស់ក្រអូប មានចន្ទន៍ក្រហមជាដើម ខាងក្រោមឲ្យដាក់ពេញទៅដោយបុប្ផាដែលវណ្ណៈដ៏វិចិត្រ ផ្នែកខាងលើ តុបតែងដោយផ្កាយមាស មានពិតានប្រដាប់ទៅដោយកួងផ្កាជាទីរីករាយ ដែលគេព្យួរជាចង្កោមក្នុងចន្លោះផ្កាយមាស ធ្វើឲ្យមានភាពល្អស្រស់ដូចទេវវិមាន ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ព្រះចិន្តាដល់ការមករបស់ដំរីកែវ ឈ្មោះបែបនេះ ។ ព្រះរាជាបំពេញមហាទាន សមាទានសីល ប្រថាប់អង្គុយរំពឹងដល់បុញ្ញសម្បត្តិនោះ ដោយន័យដូចពោលហើយក្នុងកាលមុនទុំះឯង ។

លំដាប់នោះ ដំរីដ៏ប្រសើរ ដែលអានុភាពនៃបុណ្យរបស់ស្តេចចក្រពត្តិដាស់តឿនហើយ ប្រាថ្នានឹងសោយសក្ការៈពិសេសនោះ ដំរីដ៏ប្រសើរមកអំពីត្រកូលដំរីឆទ្ទន្ត ឬអំពីត្រកូលដំរីឧបោសថ មានសម្បុរសផូរផង់បរិសុទ្ធិ ប្រដាប់ដោយសំពត់ជាអករណៈសម្រាប់ចង្កេ និងត្រង់មុខ ដោយសំពត់ពណ៌ក្រហមឆ្អិនឆ្អៅ ដូចព្រះអាទិត្យពណ៌អារុណ មានខ្លួនប្រកបដោយអវយវៈទាំង ៧ ត្រូវលក្ខណៈ គឺ មានអវយវៈតូចធំតាំងនៅត្រូវចំណែក មានចុងប្រមោយក្រហមដូចបទុមមាសពណ៌ក្រហមដែលរីក អាចហោះ អាចដើរលើអាកាសបាន ដូចព្រះយោគីអ្នកមានឫទ្ធិ ជាដំរីប្រសើរបំផុត ដូចភ្នំប្រាក់ ដែលមានកំពូលលាបដោយម្សៅនៃមនោសិលា ប្រតិស្ឋាននៅក្នុងប្រទេសនោះ ដំរីប្រសើរនោះ កាលមកពីត្រកូលដំរីឆទ្ទន្ត ក៏មកតាំងពីនៅតូចជាងដំរីទាំងពួង កាលមកពីត្រកូលដំរីឧបោសថ ក៏មកជាដំរីដ៏ប្រសើរជាងដំរីទាំងពួង តែក្នុងព្រះបាលីបញ្ជាក់ថា មកក្នុងលក្ខណៈស្តេចដំរី ឈ្មោះឧបោសថ ។ កាលស្តេចចក្រពត្តិអ្នកបំពេញវត្តរបស់ស្តេចចក្រពត្តិបរិបូរណ៍ហើយ ទ្រង់ព្រះចិន្តាដោយន័យដូចពោលហើយក្នុងព្រះសូត្រនុ៎ះឯង ។ ដំរីឧបោសថក៏ដើរមក មិនមែនមកដើម្បីមនុស្សពួកដទៃកាលមកដល់រោងដំរីមង្គលហត្ថី ជម្មតាគេក៏នាំដំរីមង្គលហត្ថីចេញ ហើយចូល

ទៅឈរជំនួសក្នុងរោងដំរីនោះដោយខ្លួនឯងតែម្តង ដោយហេតុនោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៅមានទៀត ។បេ។ ជាស្តេចដំរី ឈ្មោះឧបោសថ ។

ក៏ទ្រមាក់ដំរីជាដើម ឃើញហត្ថិរតន៍នោះ ប្រាកដដូច្នោះហើយ ខ្វះក៏រីករាយត្រេកអរ ប្រញាប់ទៅក្រាបទូលឲ្យព្រះរាជាធិបតីទ្រង់ជ្រាប ដោយរហ័ស ព្រះរាជាស្តេចមកយ៉ាងប្រញាប់ប្រញាល់ ទតឃើញហើយ មានព្រះរាជហឫទ័យប្រោសប្រាណ ទ្រង់ព្រះតម្រិះថា នឹងបានយានដំរីដ៏ប្រសើរហ្ន៎ ប្រសិនបើសម្រេចការហ្វឹកហាត់ហើយ ទើបទ្រង់លាព្រះហស្តចេញ ។ គ្រានោះ ដំរីកែវត្រជាងស្លឹកត្រចៀក ដូចកូនគោដែលជាប់តាមមេគោក្នុងក្រោល កាលនឹងសម្តែងភាពដែលខ្លួនជាសត្វក្លាហាន ទើបចូលទៅគាល់ព្រះរាជា ព្រះអង្គមានបំណងនឹងប្រថាប់គង់លើដំរីកែវនោះ គ្រានោះ បរិវារជនជ្រាបសេចក្តីប្រាថ្នារបស់ព្រះអង្គហើយ ទើបតុបតែងដំរីកែវនោះដោយទង់មាស និងគ្រឿងអលង្ការមាស គ្របដោយសំណាញ់មាស ហើយនាំចូលទៅថ្វាយ ។ ព្រះរាជាទ្រង់ធ្វើដំរីកែវឲ្យនៅស្ងៀម ឡើងប្រថាប់ដោយជណ្តើរ សម្រេចដោយរតនៈ ៧ ប្រការ មានព្រះទ័យប្រាថ្នានឹងទៅតាមផ្លូវអាកាស ព្រមគ្នានឹងការត្រិះរិះរបស់ព្រះរាជាធិបតីនុ៎ះឯង

ស្តេចដំរីនោះក៏ស្ទុះឡើងកាន់ផ្ទៃនភាកាសពណ៌ខៀវ រុងរឿងដោយពន្លឺនៃកែវឥន្ទនិល និងកែវមណី ដូចស្តេចហង្ស ។ តពីនោះ បរិស័ទរបស់ព្រះរាជាទាំងអស់ក៏ជាប់តាមទៅ ដោយន័យដូចពោលហើយក្នុងការត្រាច់ទៅរបស់ចក្ករតន៍ ។ ព្រះរាជាព្រមទាំងបរិស័ទ ស្តេចត្រាច់ទៅទូទាំងផែនដីទាំងអស់ ហើយស្តេចត្រឡប់ដល់រាជធានី ទាន់ពេលសោយព្រះក្រយាហារព្រឹក ដំរីកែវរបស់ស្តេចចក្រពត្តិ មានឫទ្ធិច្រើនយ៉ាងនេះ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ទិស្វា** ។បេ។ **បាតុរហោសិ** ដូច្នេះ ។ បរិស័ទរបស់ស្តេចចក្រពត្តិដែលមានហត្ថិរតន៍ ប្រាកដហើយដូច្នេះ ទើបជួយគ្នាបោសប្រាសសម្អាតរោងសេះមង្គលឲ្យស្អាត ធ្វើផែនដីឲ្យរៀបស្មើ តុបតែងហើយ ទើបក្រាបទូលរំលឹកព្រះរាជាឲ្យមានព្រះឧស្សាហ៍ ទ្រង់ព្រះចិន្តាដល់ការមករបស់អស្សរតន៍នោះ ព្រះរាជាទ្រង់បំពេញទានសក្ការៈ សមាទានសីល ប្រថាប់អង្គុយលើផ្ទៃប្រាសាទជាន់លើ ទ្រង់បង្អោនរឭកដល់បុញ្ញសម្បត្តិ ដោយន័យមុនទុំះឯង គ្រានោះស្តេចសេះ ឈ្មោះវលាហកៈ ដោយអានុភាពនៃបុណ្យរបស់ស្តេចចក្រពត្តិនោះជាស់តឿនហើយ អស្សរតន៍នោះ មានសម្បុរដូចអ័ព្ទ ឬដូចដុំពពកក្នុងសរទ-កាល ដែលខ្ចៃលធ្លាត់ទៅដោយផ្លេកបន្ទោរ អស្សរតន៍នោះ មានជើងក្រហម

មានមាត់ក្រហម មានជង្ឃួនសស្ងួតស្អិតស្និទ្ធដូចពន្លឺផ្កាយព្រឹក មានសីសៈ ស្រដៀងសីសៈក្អែក ព្រោះមានសីសៈខ្មៅ ដូចកែវមណីលាយកែវឥន្ទនិល មាន សរសៃសក់ល្អដូចបណ្តូលស្មៅយាប្លង់ ព្រោះប្រកបទៅដោយសរសៃសក់ដែល មានកញ្ចុំល្អិត ស្រឡូន ត្រង់ដូចស្មៅយាប្លង់ដែលគេរៀបទុក អស្សរតន៍នោះ ហោះទៅក្នុងអាកាសបាន មកពីត្រកូលវលាហកៈ ប្រតិស្ឋាននៅក្នុងទីនោះ ពាក្យដ៏សេសគ្រប់យ៉ាង គប្បីជ្រាបដោយន័យដូចពោលហើយក្នុងហត្ថិរតនៈនោះ ឯង ។ ទ្រង់សំដៅយកអស្សរតន៍បែបនេះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យ មានជាដើមថា **បុន ច បរំ** ដូច្នេះ ។

កាលស្តេចចក្រពត្តិ មានរតនៈប្រាកដដូច្នេះ ក៏មានមណីរតន៍អណ្តែតមក ពីភ្នំវេបុល មានប្រវែងប្រមាណ ៤ ហត្ថ មានសណ្ឋានប្រមាណប៉ុនដុំរទេះ ខាង ចុងទាំងសងខាងប្រដាប់ទៅដោយកណ្ណិកា និងប្រដាប់ដោយបទុមមាស មានផ្កា មុក្តាស្អាតបរិសុទ្ធិប្រាសចាកមន្ទិល ដូចជាព្រះចន្ទថ្ងៃពេញបូណ៌មី ដែលហែ- ហមទៅដោយហ្វូងផ្កាយតូចធំ មានពន្លឺផ្សាយស្មើទៅដូច្នោះ កាលកែវមណីនោះ អណ្តែតមកយ៉ាងនេះហើយ គេក៏ប្រើ ឫស្សីតៗ គ្នា លើកឡើងកាន់អាកាស កម្ពស់ប្រមាណ ៦០ ហត្ថ ដោយវៀរកែវមុក្តា ក្នុងពេលយប់ មានពន្លឺផ្សាយ

ទូទៅទាំងបរិវេណប្រមាណមួយយោជន៍ដោយជុំវិញ មណីរតន៍ ដែលមានពន្លឺទូទៅទាំងបរិវេណទាំងអស់ ដូចពន្លឺក្នុងវេលាព្រះអាទិត្យរះ នោះជាហេតុឲ្យអ្នកស្រែប្រកបកសិកម្មបាន ឈ្មួញពាណិជ្ជប្រកបការទិញលក់បានក្នុងផ្សារ អ្នកសិល្បៈខ្លះសម្គាល់ថា ជាពេលថ្ងៃ ក៏ប្រកបកិច្ចការងាររបស់ខ្លួនបានតាមនាទី ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៀតមានទៀត ។ល។ មណីរតន៍ រមែងប្រាកដដូច្នេះ ។

ឥត្ថីរតន៍ ដែលជាហេតុឲ្យកើតសេចក្ដីសុខពិសេសតាមភេទវិស័យ រមែងកើតដល់ស្ដេចចក្រពត្តិអ្នកមានមណីរតន៍ប្រាកដហើយ ដូច្នេះ ។ ក៏ពួកមហាជនរមែងនាំអគ្គមហេសីមកពីត្រកូលមទ្ទរាជ ថ្វាយដល់ស្ដេចចក្រពត្តិខ្លះ អគ្គមហេសីដែលមកឯងអំពីឧត្តរកុរុទ្វីប ដោយបុញ្ញានុភាពខ្លះ ។ ក៏គុណសម្បត្តិដ៏សេសរបស់អគ្គមហេសីនោះ មានមកហើយក្នុងព្រះបាលីទាំងអស់ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៀតមានទៀត នាងកែវរូបល្អ គួរមើល រមែងប្រាកដដល់ស្ដេចចក្រពត្តិ ដូច្នេះ ។ ក្នុងបទដែលមកក្នុងព្រះបាលីទាំងនោះ មានវិនិច្ឆ័យដូច្នេះ ដែលឈ្មោះថា **អភិរូបា** ព្រោះមានរូបល្អ គឺ ដល់ព្រមដោយទ្រង់ទ្រាយ ។ ក៏កាលនឹងសម្លឹងមើល ក៏មើលបានពេញភ្នែក ព្រោះ

ដូច្នោះ ទើបឈ្មោះថា **ទស្សនីយា** ព្រោះត្រូវសម្រាកកិច្ចយ៉ាងដទៃទុក ហើយក្រឡេកមកមើល ។

**[១៦២]** និងឈ្មោះថា **បាសាទិកា** ព្រោះកាលមើល ក៏នាំឲ្យមានចិត្តសោមនស្សរីករាយ ។ បទថា **បរមាយ** សេចក្ដីថា ឈ្មោះថា ខ្ពស់បំផុត ព្រោះនាំសេចក្ដីជ្រះថ្លាមកឲ្យយ៉ាងនេះ ។ បទថា **វណ្ណបោក្ខរតាយ** ប្រែថា មានពណ៌សម្បុរល្អ ។ បទថា **សមន្នាគតា** ប្រែថា ចូលដល់ ។ មួយទៀត ឈ្មោះថា មានរូបល្អ ព្រោះមិនខ្ពស់ពេក មិនទាបពេក , ឈ្មោះថា គួរមើល ព្រោះមិនស្គមពេក មិនធាត់អ្នក , ឈ្មោះថា គួរជ្រះថ្លា ព្រោះមិនខ្មៅពេក មិនសពេក ឈ្មោះថា ប្រកបដោយសភាពស្រស់ល្អនៃសម្បុរពណ៌យ៉ាងក្រៃលែង ព្រោះកន្លងពណ៌សម្បុររបស់មនុស្ស តែមិនទាន់ដល់ថ្នាក់ពណ៌សម្បុរទិព្វ សេចក្ដីពិត ពណ៌សម្បុររបស់មនុស្សទាំងឡាយ មិនមានពន្លឺផ្សាយពាសពេញទៅខាងក្រៅ ចំណែកពណ៌សម្បុររបស់ទេវតាផ្សាយពាសពេញចេញទៅបានឆ្ងាយ ។ តែពន្លឺនៃសរីរៈរបស់ស្ត្រីកែវនោះ ភ្លឺទូទៅក្នុងបរិវេណប្រមាណ ១២ ហត្ថ ក៏ក្នុងបណ្ដាគុណ-សម្បត្តិ មានសភាពមិនខ្ពស់ពេកជាដើម លោកពោលអារោហសម្បត្តិទុក ដោយគុណសម្បត្តិគូដំបូង ពោលបរិណាហសម្បត្តិទុកដោយគុណសម្បត្តិគូទីពីរ ពោល

វណ្ណសម្បត្តិទុក ដោយគុណសម្បត្តិគូទីបី ។ មួយទៀត ដោយគុណសម្បត្តិ ៦ ប្រការទាំងនេះ អគ្គមហេសីមិនមានសេចក្តីខ្វះខាតផ្ទៃកាយឡើយ ។ កាយ-សម្បត្តិ ត្រាស់ទុកដោយបទនេះថា **អតិក្កន្តា មនុស្សវណ្ណំ** ។ បទថា **តូល-បិចុនោ វា កប្បាសបិចុនោ វា** សេចក្តីថា មានសម្ផស្សផ្ទៃកាយដូចជាសម្ផស្សសំឡីគ ឬសំឡីកប្បាស ដែលគេដាក់ទុកក្នុងទឹកដោះថ្លា ហើយថ្លិច ១០០ ដង ។

បទថា **សីតេ** បានដល់ ក្នុងគ្រាដែលព្រះរាជាធិបតីត្រជាក់ ។ បទថា **ឧណ្ហេ** បានដល់ ក្នុងគ្រាដែលព្រះរាជាធិបតីក្តៅ ។ បទថា **ចន្ទនគន្ធោ** សេចក្តីថា ក្លិនចន្ទដែលគេកិនអស់វេលាយូរ (ដាក់បល្លិតផងជារបស់ថ្មោង) នាំមកលាយនឹងជាតិទាំង ៤ លាបកាយ រមែងផ្សាយចេញពីកាយ ។ បទថា **ឧប្បលគន្ធោ** សេចក្តីថា ក្លិនក្រអូបរបស់ផ្កាឧប្បលខៀវ ដែលគេក្តិចក្នុងខណៈនោះ (យ៉ាងណា) រមែងក្រអូបចេញពីមាត់របស់ស្ត្រីកែវនោះ ក្នុងវេលាសើចសប្បាយ ឬចរចា (ក៏យ៉ាងនោះ) ។ ក៏ដើម្បីនឹងសម្តែងដល់មារយាទដែលសមគួរដល់សរីរសម្បត្តិរបស់ស្ត្រីកែវ ព្រោះប្រកបដោយគុណសម្បត្តិបែបនេះ ទើបត្រាស់ពាក្យមានជាដើមថា **តំ ខោ បន** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ ដូច្នេះ ដែលឈ្មោះថា **បុព្វុដ្ឋាយិនី**

(ភ្ញាក់មុន) ព្រោះនឹងត្រូវក្រោកឡើងមុនតែម្យ៉ាង ព្រោះវង្វៀសថា ព្រះរាជាទ្រង់ឃើញហើយ នឹងក្រោធដូចភ្លើងឆេះរាជអាសនៈ ។ ឈ្មោះថា **បច្ឆានិបាតិនី** (ផ្ទុំក្រោយ) ព្រោះកាលព្រះរាជាប្រថាប់អង្គុយ នឹងត្រូវនៅគាល់បម្រើ មានការបក់ផ្លិតថ្វាយសម្ដេចព្រះរាជាធិបតីមុនហើយ ទើបនឹងផ្ទុំ ឬសម្រាកជាខាងក្រោយ ។ ឈ្មោះថា **កឹការបដិស្សាវិនី** (យកចិត្តទុកដាក់ធ្វើការងារអ្វីៗ) ព្រោះនឹងត្រូវក្រាបទូលព្រះរាជាដោយវាចាថា បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំម្ចាស់នឹងត្រូវធ្វើអ្វី ។ ដែលឈ្មោះថា **មនាបចារិនី** (ប្រព្រឹត្តត្រូវព្រះទ័យ) ព្រោះនឹងត្រូវប្រព្រឹត្ត គឺ ធ្វើឲ្យត្រូវព្រះទ័យព្រះរាជា ។ ដែលឈ្មោះថា **បិយវាទិនី** (ពោលតែពាក្យជាទីសប្បាយព្រះទ័យ) ព្រោះព្រះរាជាប្រោសប្រាណ យ៉ាងណា នឹងត្រូវទូលយ៉ាងនោះ ។

ឥឡូវនេះ ដើម្បីទ្រង់នឹងសម្ដែងថា ស្ត្រីកែវនោះ ត្រូវមានអាចារៈបរិសុទ្ធិផ្សេង មិនមានមាយា សាឋេយ្យៈ ទើបត្រាស់ពាក្យមានជាដើមថា **តំ ខោ បន** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នោ អតិចរតិ** បានដល់ មិនប្រព្រឹត្តកន្លងចិត្តអធិប្បាយថា មិនប្រាថ្នាប្រុសដទៃសូម្បីដោយចិត្ត ។ ក្នុងបណ្ដាគុណសម្បត្តិ

ទាំងនោះ គុណសម្បត្តិពួកណាដែលត្រាស់ទុកក្នុងផ្នែកខាងដើមថា ត្រូវមានរូបល្អជាដើមក្តី ដែលត្រាស់ទុកក្នុងខាងក្រោយថា ត្រូវក្រោកមុនជាដើមក្តី គុណ-សម្បត្តិទាំងនោះ ត្រាស់ថា ជាគុណសម្បត្តិធម្មតាប៉ុណ្ណោះ ។ ក៏បទជាដើមថា **អតិក្កន្តា មនុស្សានំ** គប្បីជ្រាបថា ស្តេចចក្រពត្តិទាំងឡាយ រមែងកើតដោយអានុភាពនៃកម្មចាស់ រាប់តាំងពីចក្ករតន៍ប្រាកដ ព្រោះត្រូវអាស្រ័យបុញ្ញកម្ម ។ មយ៉ាងទៀត ផ្តើមតាំងពីចក្ករតន៍កើតប្រាកដ សូម្បីជាអ្នកមានរូបល្អជាដើមកើតបរិបូណ៌ទៅគ្រប់យ៉ាង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ទើបត្រាស់ថា ឥត្ថីរតន៍បែបនេះរមែងកើត ដូច្នេះ ។ គហបតីរតន៍ រមែងកើតប្រាកដដល់ស្តេចចក្រពត្តិ អ្នកមានឥត្ថីរតន៍ប្រាកដហើយ ដើម្បីជាប្រយោជន៍ជាប់ទាក់ទងនឹងកិច្ចការផ្នែកខាងព្រះឃ្លាំង តាមព្រះរាជអធ្យាស្រ័យ អ្នកដែលមានភោគៈច្រើនតាមប្រក្រតីក្តី អ្នកដែលកើតក្នុងត្រកូលមានភោគៈច្រើនក្តី មានចំណែកជួយឲ្យកិច្ចការព្រះឃ្លាំងរបស់ព្រះរាជាចម្រើនរុងរឿង ទើបនឹងជាសេដ្ឋី ជាគហបតីបាន ។ ក៏ចក្ខុដូចជាទិព្វកើតពីវិបាកកម្ម ដើម្បីប្រយោជន៍ រមែងកើតប្រាកដដល់គហបតីកែវនោះឯង ជាហេតុឲ្យមើលឃើញទ្រព្យខាងក្នុងផែនដីបាន ក្នុងជម្រៅ ១ យោជន៍ គេឃើញសម្បត្តិនោះហើយសប្បាយចិត្ត ទៅគាល់ស្តេច

ចក្រពត្តិ ទទួលនាទីខាងឃ្លាំងថ្វាយព្រះរាជា ប្រកបកិច្ចការខាងឃ្លាំងគ្រប់យ៉ាង ឲ្យសម្បូរណ៍ ។

ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៅមានទៀត ។លៗ គហបតីរតន៍បែបនេះ រមែងប្រាកដដូច្នេះ ។

ក៏បរិនាយកកែវ អាចចាត់ចែងកិច្ចការគ្រប់យ៉ាងឲ្យសម្រេច រមែងកើតប្រាកដដល់ស្តេចចក្រពត្តិដែលមានគហបតីកែវប្រាកដហើយដល់ព្រះអង្គ ដោយប្រការដូច្នេះ ។ បរិនាយកកែវនោះ ជារាជបុត្រច្បងរបស់ស្តេចចក្រពត្តិ ជាបណ្ឌិត មានបញ្ញាដោយប្រក្រតី ក៏បរចិត្តញាណ (ញាណកំណត់ដឹងចិត្តអ្នកដទៃ) រមែងកើតប្រាកដដល់បរិនាយកកែវនោះ ដោយអានុភាពនៃកម្មរបស់ខ្លួនឯង ព្រោះអាស្រ័យបុញ្ញានុភាពរបស់ស្តេចចក្រពត្តិ ជាហេតុឲ្យដឹងវារៈចិត្តរបស់រាជបរិវារបានប្រមាណ ១២ យោជន៍ ហើយកំណត់វត្ថុដែលមិនជាប្រយោជន៍ និងវត្ថុដែលជាប្រយោជន៍ សម្រាប់ព្រះរាជាបាន ។ សូម្បីបរិនាយកកែវនោះ ឃើញអានុភាពរបស់ខ្លួននោះហើយ សប្បាយចិត្ត ទទួលអាសាព្រះរាជា ដោយទទួលនូវកិច្ចការគ្រប់យ៉ាង ។

ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ប្រការដទៃទៀតមានទៀត បរិនាយកកែវរមែងកើតប្រាកដ ដូច្នេះ ។

**[១៦៤]** បណ្ដាបទទាំងនោះ បទថា **ឋាបេតព្វំ ឋាបេតុំ** បានដល់ ដើម្បីទ្រទ្រង់តែងតាំងអ្នកដែលគួរតែងតាំងក្នុងតំណែងនោះៗ ។

**[១៦៦]** បទថា **សមវេបាកិនិយា** ជាដើម លោកពោលទុកហើយក្នុងកាលក្រោយនោះឯង ។

បទថា **កដគ្គាហេន** ប្រែថា ព្រោះចាប់យកជ័យជំនះទុកបាន ។ បទថា **មហន្តភោគក្ខន្ធំ** សេចក្ដីថា នឹងគប្បីបានប្រាក់ពីរ ឬបីសែន ដោយការចាប់យកជ័យជំនះបានក្នុងគ្រាតែមួយប៉ុណ្ណោះ ។ បទថា **កេវលា បរិបូរា បណ្ឌិតភូមិ** សេចក្ដីថា បណ្ឌិតបំពេញសុចរិតទាំងបី រមែងកើតក្នុងសួគ៌ ។ តពីនោះ កាលមកកាន់មនុស្សលោក រមែងកើតក្នុងទីដែលមានភាពសម្បូរណ៍ដោយត្រកូល រូប និងភោគៈ គេតាំងនៅក្នុងសម្បត្តិនោះហើយ បំពេញសុចរិត ៣ ឲ្យបរិបូរ រមែងបានទៅកើតក្នុងសួគ៌ទៀត ។ តាមដែលពណ៌នាមកនេះ ទើបឈ្មោះថា ជាបណ្ឌិតភូមិដ៏បរិបូណ៌គ្រប់គ្រាន់ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ពាលបណ្ឌិតសូត្រ ទី ៩

# អ ដ្ឋ ក ថា

## ទេវទូតសូត្រទី ១០

**[១៧២]** *ទេវទូតសូត្រ មានបទចាប់ផ្ដើមថា* **ឯវមេ្ម សុតំ** *ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៖*

**[១៧៣]** *ក្នុងបទទាំងនោះ ។ ពាក្យជាដើមថា* **ទេ្វ អគារា** *មានពិស្ដារទុកហើយក្នុងអស្សបុរសូត្រ ។ បទថា* **និរយំ ឧបបន្នា** *សេចក្ដីថា ក្នុងគ្រាខ្លះព្រះមានព្រះភាគទ្រង់ញ៉ាំងទេសនាតាំងពីនរក ហើយបញ្ចប់ត្រឹមទេវលោក ។ គ្រាខ្លះតាំងពីទេវលោកទ្រង់បញ្ចប់ត្រឹមនរក ។ បើប្រាថ្នានឹងត្រាស់សួគ៌សម្បត្តិឲ្យពិស្ដារ ត្រាស់ដល់ទុក្ខក្នុងនរកដោយចំណែកមួយ ទុក្ខក្នុងកំណើតសត្វតិរច្ឆានទុក្ខក្នុងបិត្តិវិស័យ ត្រាស់ដល់សម្បត្តិក្នុងមនុស្សលោកដោយចំណែកមួយ ។ ប្រសិនបើប្រាថ្នានឹងត្រាស់ទុក្ខក្នុងនរកឲ្យពិស្ដារ រមែងត្រាស់ដល់សម្បត្តិក្នុងទេវលោក មនុស្សលោក និងទុក្ខក្នុងកំណើតសត្វតិរច្ឆាន និងបិត្តិវិស័យដោយចំណែកមួយ ឈ្មោះថា ញ៉ាំងទុក្ខក្នុងនរកឲ្យពិស្ដារ ក្នុងព្រះសូត្រនេះ ព្រះអង្គប្រាថ្នានឹងញ៉ាំងទុក្ខក្នុងនរកឲ្យពិស្ដារ ព្រោះដូច្នោះ ទ្រង់ញ៉ាំងទេសនាតាំងអំពី*

ទេវលោកឲ្យចប់ស្រេចត្រឹមនរក ដើម្បីត្រាស់ដល់សម្បត្តិក្នុងទេវលោក មនុស្ស-លោក និងទុក្ខក្នុងកំណើតសត្វតិរច្ឆាន និងក្នុងបិត្តិវិស័យដោយចំណែកមួយ ហើយត្រាស់ដល់ទុក្ខក្នុងនរកដោយពិស្តារ ទើបត្រាស់ពាក្យជាដើមថា

**[១៧៤]** ***តមេនំ ភិក្ខវេ និរយបាលា*** ។ ក្នុងបទនោះ ព្រះថេរៈពួកខ្លះពោលថា ឈ្មោះថា នាយនិរយបាលមិនមាន កម្មប៉ុណ្ណោះ រមែងជាហេតុឲ្យកើតដូចរូបយន្ត ។ កម្មនុ៎ះ ត្រូវបដិសេធទុកក្នុងអភិធម្ម ដោយន័យជាដើមថា អើ ! នាយនិរយបាល ក្នុងនរកមាន និងកម្មជាហេតុឲ្យកើតក៏មាន ។ ដូចជា ក្នុងមនុស្សលោក មានអ្នកធ្វើទារុណកម្មដល់អ្នកទោស យ៉ាងណា នាយនិរយបាលក៏មាននៅក្នុងនរក ដូច្នោះ ។

បទថា ***យមស្ស រញ្ញោ*** បានដល់ ព្រះរាជាវេមានិកប្រេត ឈ្មោះថា យមរាជ ក្នុងវេលាខ្លះសោយសម្បត្តិជាទិព្វ មានដើមកប្បព្រឹក្សទិព្វ ឧទ្យានជាទិព្វ អ្នករបាំជាទិព្វ សម្បត្តិទិព្វក្នុងវិមានទិព្វ ក្នុងវេលាខ្លះក្លាយជាយមរាជអ្នកទ្រទ្រង់ធម៌ សោយផលកម្ម តែមិនមែនវេលាតែមួយជាមួយគ្នា ។ ចំណែកត្រង់ទ្វារទាំង ៤ មានអ្នករក្សា ៤ នាក់ ។

**[១៧៥]** បទថា ***នាទសំ*** សេចក្តីថា លោកសំដៅយកការមិនមាននៃ

ទេវទូតណាមួយ ដែលត្រូវគេបញ្ជូនទៅទុកក្នុងសម្នាក់របស់ខ្លួន ទើបពោល យ៉ាងនេះ ។ គ្រានោះស្តេចយមរាជដឹងថា អ្នកនេះមិនកំណត់សេចក្តីនៃភាសិត ប្រាថ្នានឹងឲ្យគេកំណត់ ទើបពោលពាក្យថា **អម្ភោ** ។ បទថា **ជាតិធម្មោ** គឺ មានការកើតជាធម្មតា មិនផុតពីការកើតទៅបាន ឈ្មោះថា **ជាតិ** រមែងប្រព្រឹត្ត ទៅក្នុងខាងក្នុងរបស់យើង ។ សូម្បីក្នុងបទជាដើមថា **បរតោ ជរាធម្មោ** ក៏មាន ន័យនេះដូចគ្នា ។ ក្នុងបទថា **បឋមំ ទេវទូតំ សមនុយុញ្ជិត្វា** សេចក្តីថា ទារក តូច (ការត:) រមែងពោលយ៉ាងនេះ ដោយអត្ថថា អ្នកដ៏ចម្រើន ចូរមើលយើង សូម្បីយើងក៏មានដៃ និងជើងដូចពួកលោក តែយើងដេកត្រាំនៅក្នុងមូត្រលាមក របស់ខ្លួន មិនអាចនឹងក្រោកឡើងងូតទឹកតាមធម្មតារបស់ខ្លួនបាន យើងជាអ្នក មានកាយស្មោកគ្រោកហើយ តែមិនអាចនឹងប្រាប់ថា ចូរងូតទឹកឲ្យយើង យើង ឈ្មោះថា មានសភាពដូច្នេះ ព្រោះមិនផុតពីការកើត តែក៏មិនមែនយើងប៉ុណ្ណោះ សូម្បីលោកទាំងឡាយ ក៏មិនផុតពីការកើត ការកើតនឹងមានសូម្បីដល់លោក ទាំងឡាយក៏នឹងមានប្រាកដដូចយើង លោកចូរធ្វើសេចក្តីល្អទុក តាំងពីមុនការ កើតនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះឯង ទារកនោះ ឈ្មោះថា **ទេវ-ទូត** ។ តែសេចក្តីនៃពាក្យនេះ លោកពោលទុកក្នុងមាឃទេវសូត្រ ។

សូម្បីក្នុងបទថា **ទុតិយំ ទេវទូតំ** នេះ សេចក្ដីថា សត្វចាស់ជរា ឈ្មោះថា រមែងពោលយ៉ាងនេះ ដោយសេចក្ដីថា អ្នកដ៏ចម្រើន ពួកលោកចូរមើល សូម្បីយើងក៏ធ្លាប់ជាកម្លោះ សម្បូរណ៍ដោយកម្លាំងជើង កម្លាំងដៃ និងរហ័សរហួនដូចលោក សេចក្ដីដល់ព្រមដោយកម្លាំង និងភាពរហ័សរហួនទាំងនោះរបស់យើង បាត់អស់ទៅហើយ សូម្បីដៃ និងជើងរបស់យើងមាន តែធ្វើកិច្ចដោយដៃ និងជើងមិនបាន យើងឈ្មោះថា មានសភាពដូច្នេះ ព្រោះមិនផុតពីជរា មិនមែនតែយើងប៉ុណ្ណោះ សូម្បីលោកទាំងឡាយ ក៏មិនរួចផុតចាកជរា ភាពជរានោះ នឹងមកដល់សូម្បីលោកទាំងឡាយក៏នឹងមានប្រាកដដូចយើង ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះឯង សត្វចាស់ជរានោះ ឈ្មោះថា **ទេវទូត** ។

**[១៧៧]** សូម្បីក្នុងបទថា **តតិយំ ទេវទូតំ** នេះ សេចក្ដីថា សត្វដែលជម្ងឺ ឈ្មោះថា រមែងពោលយ៉ាងនេះ ដោយសេចក្ដីថា អ្នកដ៏ចម្រើន ពួកលោកចូរមើល សូម្បីយើងក៏ធ្លាប់ជាអ្នកមិនមានរោគដូចលោក តែយើងឥឡូវនេះត្រូវព្យាធិគ្របសង្កត់ ដេកទន្ទេលនៅក្នុងមូត្រ និងលាមករបស់ខ្លួន មិនអាចក្រោកឡើងបាន សូម្បីដៃ និងជើងរបស់យើងនៅមាន ក៏ធ្វើកិច្ចដោយដៃ និងជើងមិនបាន យើងមានសភាពដូច្នេះ ព្រោះមិនផុតពីព្យាធិ មិនមែនតែយើង

ប៉ុណ្ណោះ សូម្បីលោកទាំងឡាយក៏មិនផុតពីព្យាធិ ព្យាធិនឹងមកដល់សូម្បីលោកទាំងឡាយដូចយើង លោកទាំងឡាយនឹងមានព្យាធិប្រាកដ លោកចូរធ្វើសេចក្ដីល្អទុកចុះ មុនពេលដែលព្យាធិមកដល់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ សត្វដែលមានជម្ងឺនោះ ឈ្មោះថា **ទេវទូត** ។

**[១៧៨]** ក៏ក្នុងបទថា **ចតុត្ថំ ទេវទូតំ** នេះ ទារុណកម្ម ឬអ្នកទោស ឈ្មោះថា **ទេវទូត** ។

ក្នុងពីរបទនោះ ក្នុងចំណែកទារុណកម្ម ៣២ មុន រមែងពោលយ៉ាងនេះ ដោយអត្ថថា ពួកយើងកាលកើត រមែងមិនកើតអំពីដើមឈើ ឬផ្ទាំងថ្ម រមែងកើតក្នុងសរីរៈរបស់មនុស្សដូចពួកលោក ដោយប្រការដូច្នេះ លោកចូរធ្វើសេចក្ដីល្អទុកឲ្យបានមុនពេលកើត ព្រោះហេតុនោះ ទារុណកម្មទាំងនោះ ទើបឈ្មោះថា **ទេវទូត** ។ សូម្បីអ្នកទោស រមែងពោលយ៉ាងនេះ ដោយអត្ថថា ពួកយើងកាលនឹងត្រូវដាក់ទណ្ឌកម្ម ៣២ យ៉ាង មិនបានត្រង់ដើមឈើជាដើម រមែងធ្វើក្នុងសត្វ ដូចជាពួកលោកទុំះឯង ។ ដោយប្រការដូច្នេះ ពួកលោកចូរធ្វើសេចក្ដីល្អមុនពេលដែលគេដាក់ទោស ។ ព្រោះហេតុនោះ សូម្បីអ្នកទោសទាំងនោះ ឈ្មោះថា **ទេវទូត** ។

**[១៧៩]** ក្នុងបទថា ***បញ្ចមំ ទេវទូតំ*** នេះ សេចក្ដីថា សត្វដែលស្លាប់ហើយ (ហាក់ដូចជា) ពោលយ៉ាងនេះ ដោយអត្ថថា អ្នកដ៏ចម្រើន ពួកលោកចូរមើលយើង ដែលគេយកចោលក្នុងព្រៃជាទីចោលសាកសព ដល់សភាពហើមប៉ោងជាដើម យើងក៏មានសភាពដូច្នេះ ព្រោះមិនផុតពីសេចក្ដីស្លាប់ តែមិនមែនយើងប៉ុណ្ណោះ សូម្បីពួកលោកក៏មិនផុតពីសេចក្ដីស្លាប់ដូចគ្នា សេចក្ដីស្លាប់នឹងមកដល់លោកទាំងឡាយ លោកទាំងឡាយនឹងស្លាប់ដូចយើង ពួកលោកចូរធ្វើសេចក្ដីល្អមុនសេចក្ដីស្លាប់នោះមកដល់ ព្រោះដូច្នោះ សត្វដែលស្លាប់នោះឈ្មោះថា ***ទេវទូត*** ។

សួរថា នរណា នឹងបានប្រយោជន៍អំពីទេវទូតនេះ នរណាមិនបាន ។ ឆ្លើយថា អ្នកណាធ្វើបាបកម្មច្រើន អ្នកនោះទៅកើតក្នុងនរក ។ អ្នកណាធ្វើបាបកម្មតិចតួច អ្នកនោះរមែងបាន ។ ជនទាំងឡាយចាប់ចោរព្រមទាំងភណ្ឌៈ រមែងធ្វើវត្ថុដែលគួរធ្វើ មិនវិនិច្ឆ័យ តែនាំចោរដែលត្រូវដេញដោលសួរ ទៅកាន់សាលាក្ដី គេបានការកាត់ក្ដីយ៉ាងណា ប្រការប្រៀបធៀបក៏ដូច្នោះ ។ ក៏អ្នកមានបាបកម្មតិចតួច រមែងរឭកបានតាមធម្មតារបស់ខ្លួន សូម្បីត្រូវគេរំលឹកក៏រឭកបាន ។ ក្នុងសេចក្ដីនោះ មានទមិឡឈ្មោះ ទីឃទន្តៈ រឭកបានតាមធម្មតា

របស់ខ្លួន ។ បានឮថា ទមិឡនោះ យកសំពត់ពណ៌ក្រហមបូជាអាកាសចេតិយក្នុងសុមនគីរីវិហារ គ្រានោះ គេកើតក្នុងឧស្សទនរក បានឮសំឡេងអណ្តាតភ្លើង ក៏រឭកដល់សំពត់ដែលខ្លួនបានបូជា ។ គេទើបទៅកើតក្នុងឋានសួគ៌ ។ ម្នាក់ទៀត បានថ្វាយសំពត់សាដកសាច់គ្រោតគ្រាតដល់ភិក្ខុកម្លោះ ដែលជាបុត្រដាក់ទុកជិតជើង ។ ក្នុងវេលាជិតស្លាប់ គេកាន់យកនិមិត្តក្នុងសម្លេងថា បដ: បដ: (សំពត់ៗ) សូម្បីគេក៏កើតក្នុងឧស្សទនរក គេរឭកដល់សំពត់នោះ ព្រោះសំឡេងអណ្តាតភ្លើង ទើបទៅកើតក្នុងឋានសួគ៌ ។ គេរឭកដល់កុសលកម្មតាមធម្មតារបស់ខ្លួនយ៉ាងនេះ ទើបកើតក្នុងឋានសួគ៌ ។ តែកាលរឭកតាមធម្មតារបស់ខ្លួនមិនបាន ទើបយមរាជសួរដល់ទេវទូតទាំង ៥ ។ ក្នុងទេវទូតទាំង ៥ នោះ អ្នកខ្លះរឭកបានត្រង់ទេវទូតទីមួយ ។ អ្នកខ្លះ រឭកបានត្រង់ទេវទូតទីពីរជាដើម ។ ចំណែកសត្វណាដែលរឭកមិនបានដោយទេវទូតទាំង ៥ យមរាជតែងជួយទឹកដោយព្រះអង្គឯង ។ បានឮថា អាមាត្រម្នាក់បូជាមហាចេតិយដោយធ្នាំងផ្កាម្លិះ បានឲ្យចំណែកបុណ្យដល់យមរាជ ។ នាយនិរយបាល នាំអាមាត្រនោះដែលកើតក្នុងនរក ព្រោះអកុសលកម្មទៅរកស្តេចយមរាជ ។ កាលអាមាត្រនោះរឭកមិនបាននូវទេវទូតទាំង ៥ ស្តេចយមរាជរឭកមើលដោយព្រះ

អន្តងន ឃើញហើយក៏រំពឹកថា អ្នកធ្លាប់បូជាមហាចេតិយដោយផ្កាំងផ្កាម្ទិះ ហើយ ផ្សាយចំណែកបុណ្យឲ្យយើងមិនមែនឬ ។ គេរឭកបានក្នុងវេលានោះ ហើយ ទៅកាន់ទេវលោក បើទ្រង់នឹករកមិនឃើញទេ ក៏នៅស្ងៀម នឹកក្នុងព្រះទ័យថា ឱសត្វនេះ មុខជានឹងបានទុក្ខធំ ។

**[១៨២]** បទថា **មហានិរយេ** បានដល់ អវិចីមហានរក សួរថា អវិចី-មហានរកនោះ មានទំហំប្រមាណខាងក្នុងប៉ុនណា ។ ឆ្លើយថា អវិចីមហានរក នោះ មានជំហូលជាផែនលោហៈ បណ្តោយ និងទទឹងប្រមាណ ៩០០ យោជន៍ ដូចគ្នា ជញ្ជាំងម្ខាងៗ ប្រមាណ ៨១ យោជន៍ ។ អណ្តាតភ្លើងនោះតាំងឡើង ក្នុងទិសបូព៌ាទល់ជញ្ជាំងទិសបច្ចិម ទម្លុះជញ្ជាំងនោះទៅខាងមុខ ១០០ យោជន៍ ។ សូម្បីក្នុងទិសដ៏សេស ក៏មានន័យនេះឯង ។ ដោយប្រការដូច្នេះ ដោយផ្នែក បណ្តោយ និងផ្នែកទទឹង ដោយទីបំផុតរបស់អណ្តាតភ្លើង មានប្រមាណ ៣១៨ យោជន៍ ។ តែដោយជុំវិញៗ មានប្រមាណ ៩៥៤ យោជន៍ ។ ចំណែកដោយ ជុំវិញនឹងឧស្សទៈប្រមាណមួយម៉ឺនយោជន៍ ។ ក្នុងបទថា **ឧព្ភតំ តាទិសមេវ ហោតិ** នេះ សេចក្តីថា មិនអាចនឹងលើកជើងដែលត្រូវភ្លើងឆេះដល់ឆ្អឹងឲ្យផុត ពីការឆេះបាន ។ ក៏ក្នុងបទនេះ មានអធិប្បាយដូច្នេះ ត្រូវឆេះទាំងខាងក្រោម ខាង

លើ ។ ដោយប្រការដូច្នេះ ក្នុងវេលាជាន់ត្រូវភ្លើងនេះ ក្នុងវេលាលើកឡើង ក៏ដូច្នោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់យ៉ាងនេះ ។ បទថា **ពហុសម្បត្តោ** គឺ ច្រើនសែនឆ្នាំ ។

សួរថា ព្រោះហេតុអ្វី នរកនេះទើបឈ្មោះថា **អវិចី** ។ ឆ្លើយថា លោកហៅចន្លោះថា វិចី ។ ក្នុងនរកនោះ មិនមានចន្លោះរបស់អណ្តាតភ្លើងរបស់សត្វ ឬរបស់ទុក្ខ ព្រោះដូច្នោះ នរកនោះ ទើបឈ្មោះថា អវិចី ។ អណ្តាតភ្លើងតាំងឡើងពីជញ្ជាំងទិសបូព៌ានៃនរកនោះ សាយផ្សះទៅ ១០០ យោជន៍ ទម្លុះជញ្ជាំងទៅខាងមុខ ១០០ យោជន៍ ។ សូម្បីក្នុងទិសដ៏សេសល់ ក៏មានន័យនេះឯង ។ ទេវទត្តកើតត្រង់កណ្តាលនៃអណ្តាតភ្លើងទាំង ៦ នេះ ។ ទេវទត្តមានអត្តភាពប្រមាណ ១០០ យោជន៍ ជើងទាំងពីរលិចចុះក្នុងផែនលោហៈត្រឹមកជើង ដៃទាំងពីរលិចចូលទៅក្នុងជញ្ជាំងលោហៈត្រឹមកដៃ ។ ក្បាលជាប់នឹងដំបូលលោហៈត្រឹមថ្ងាសចិញ្ចើម ។ លំពែងលោហៈមួយដើម ចាក់ពីខាងក្រោម ធ្លុះកាយទៅទល់នឹងដំបូល ។ លំពែងចេញពីជញ្ជាំងទិសខាងលិច ទម្លុះទ្រូងឆ្លាយចូលទៅជញ្ជាំងទិសខាងកើត លំពែងចេញពីជញ្ជាំងទិសខាងជើង ធ្លុះថ្អឹងជំនីទៅទល់ជញ្ជាំងទិសខាងត្បូង ទេវទត្តមានសភាពដូច្នេះ ព្រោះផលនៃកម្ម ទេវទត្តនេះនៅ

នរក ព្រោះខុសក្នុងព្រះតថាគតដែលជាអ្នកមិនញាប់ញ័រ ។ ដោយប្រការដូច្នេះ នរកឈ្មោះថា អវិចី ព្រោះអណ្តាតភ្លើងជានិច្ច ។ ក្នុងខាងក្នុងនរកនោះ ក្នុងទីប្រមាណ ១០០ យោជន៍ សត្វនរកចង្អៀតណែន ដូចម្សៅដែលគេចាក់ទុកក្នុងនាឡិ ព្រោះហេតុនោះ មិនគួរពោលថា ក្នុងទីនេះមានសត្វ ក្នុងទីនេះមិនមានសត្វ ។ សត្វដើរ ឈរ អង្គុយ និងដេកមិនមានទីបំផុត ។ សត្វទាំងឡាយកាលដើរ ឈរ អង្គុយ ឬដេក រមែងមិនបៀតបៀនដល់គ្នានិងគ្នា ។

ឈ្មោះថា អវិចី ព្រោះសត្វទាំងឡាយចង្អៀតណែនយ៉ាងនេះ ។ ចំណែកចិត្តដែលសហគតដោយឧបេក្ខា ៦ ដួង រមែងកើតឡើង និងចិត្តដែលសហគតដោយទុក្ខមួយ រមែងកើតឡើងក្នុងកាយទ្វារ ។ កាលបើដូច្នោះ កាលបុគ្គលដាក់តំណក់ទឹកផ្អែម ៦ តំណក់ទុកត្រង់ចុងអណ្តាត មួយតំណក់ដាក់ទុកត្រង់តម្កលោហៈ ក៏ត្រូវដុតដោយកម្លាំងភ្លើង តំណក់ទឹកនោះរមែងប្រាកដ ក្រៅពីនេះជាអព្វោហារិក យ៉ាងណា ទុក្ខក្នុងនរកនេះមិនមានចន្លោះ ព្រោះមានការឆេះជាកម្លាំង ទុក្ខក្រៅនេះជាអព្វោហារិក ដូច្នោះ ។ ឈ្មោះថា អវិចី ព្រោះពេញទៅដោយទុក្ខយ៉ាងនេះឯង ។

បទថា **មហន្តោ** គឺ ប្រមាណ ១០០ យោជន៍ ។

**[១៨៥]** បទថា **សោ តត្ថ បតតិ** សេចក្តីថា ជើងម្ខាងនៅក្នុងមហានរក ។ ជើងម្ខាងធ្លាក់ទៅក្នុងគូថនរក ។ បទថា **សុចិមុខា** គឺ មានមាត់ស្រួចដូចម្ជុល ។ សត្វទាំងនោះមានកប៉ុនដំរី និងប៉ុនទូកទោណិកៈ (ទូកធ្វើឈើមូល) ។

**[១៨៦]** បទថា **កុក្កុលនិរយោ** សេចក្តីថា នរកក្តៅពេញទៅដោយផេះក្តៅប្រាសចាកភ្លើង ស្រដៀងផ្ទះកំពូល ខាងក្នុងមានទំហំប្រមាណ ១០០ យោជន៍ ។ សត្វដែលធ្លាក់ទៅក្នុងនរកដល់ខាងក្រោម ដូចគ្រាប់ស្ពៃក្នុងគំនរគ្រាប់ស្ពៃ ដែលគេបោះចូលទៅក្នុងរណ្តៅផេះក្តៅ ដូច្នេះ ។

បទថា **អារោបេន្តិ** សេចក្តីថា យកដំបងដែកវាយឲ្យលើកឡើងចុះ ។ ក្នុងវេលាលើកដំបងដែកទាំងនោះឡើង ក្នុងវេលាសត្វនរកនោះឡើង បន្ទាក៏សំយ៉ុងចុះ ក្នុងវេលាចុះបន្ទាក៏បះឡើង ។

**[១៨៨]** បទថា **វាតេរិតានិ** បានដល់ រសាត់ទៅតាមខ្យល់ដែលសម្រេចអំពីកម្ម ។ បទថា **ហត្ថំម្បិ ឆិន្ទន្តិ** សេចក្តីថា បានដល់ ដំ និងអារ ដូចជាអារសាច់លើជ្រុញ ។ បើក្រោកឡើងគេចចេញទៅបាន កំពែងដែកផុសឡើងមកលោមព័ទ្ធ កាំបិតកោរក៏តាំងឡើងខាងក្រោម ។ បទថា **ខារោទកា នទី** បានដល់ ស្ទឹងលោហៈពណ៌ក្រហម ឈ្មោះថា វេតតរណី ស្ទឹងនោះ មានគ្រាប់

ដែលសម្រេចអំពីដែកនៅខាងក្រោមស្ទឹកឈូក មុតដូចកាំបិតកោរ ត្រង់ប្រាំង ទាំងសងខាងមានវល្លិផ្ដៅ និងស្បូវ ។ បទថា **សោ តត្ថទុក្ខា តិប្បកា ខរា** សេចក្ដីថា សត្វនរកនោះអណ្ដែតឡើងខាងលើ និងលិចចុះទៅខាងក្រោម ក្នុងនរក បានមុតជាប់នឹងស្ទឹកឈូក ។ សត្វនរកនោះ ត្រូវមុតនឹងបន្លាខ្សាច់ ត្រូវពុះដោយកាំបិតកោរដ៏មុត និងកូតដោយស្បូវត្រង់ប្រាំងទាំងសងខាង ។ ទាញមកដោយវល្លិផ្ដៅ ។ ត្រូវពុះដោយសស្រ្តាដ៏មុត ។

**[១៩០]** បទថា **តត្ថេន អយោសង្កុនា** សេចក្ដីថា កាលសត្វនរកពោលថា យើងឃ្លានហើយ នាយនិរយបាលទាំងនោះ ញាត់នូវដុំទង់ដែងដ៏ក្ដៅចូលទៅក្នុងមាត់ ។ គេដឹងថា ជាលោហៈប៉ះត្រង់ធ្មេញ គ្រានោះ នាយនិរយបាលយកកន្ធៃដែកដ៏ក្ដៅគាស់មាត់របស់សត្វនរកនោះ ។ នាយនិរយបាលយកទឹកទង់ដែងចាក់ចូលទៅក្នុងឆ្នាំងទង់ដែងដ៏ធំ ហើយធ្វើការបង្អកទឹកទង់ដែងដ៏ក្ដៅដល់សត្វនរក យ៉ាងនោះឯង ។

**[១៩១]** បទថា **បុន មហានិរយេ** សេចក្ដីថា នាយនិរយបាលដាក់ទោសតាំងពីគ្រឿងចង ៥ ប្រការ រហូតដល់បង្អកទឹកទង់ដែងយ៉ាងនេះហើយ ផ្ដើមធ្វើទារុណតាំងពីបង្អកទឹកទង់ដែង រហូតដល់គ្រឿងចង ៥ ប្រការទៀត រួចបោះ

សត្វនោះចូលទៅក្នុងមហានរកវិញ ។

ក្នុងមហានរកនោះ សត្វខ្លះផុតពីគ្រឿងចង ៥ ប្រការ ខ្លះផុតពីគ្រឿងចង ២ ប្រការ ខ្លះផុតពីគ្រឿងចង ៣ ប្រការ ខ្លះផុតពីការបង្អកទឹកទង់ដែង ។ ក៏កាលមិនទាន់អស់កម្ម នាយនិរយបាលក៏បោះចូលទៅក្នុងមហានរកវិញ ។

ក៏ភិក្ខុកម្មោះមួយរូប កាលរៀនព្រះសូត្រនេះ ពោលថា លោកដ៏ចម្រើន កាលសត្វនរកសោយទុក្ខប៉ុណ្ណេះហើយ នាយនិរយបាលនូវតែបោះគេទៅក្នុងមហានរកទៀតឬ ។ ភិក្ខុនោះពោលថា លោកដ៏ចម្រើន ឧទ្ទេសនេះចូរលើកទុកសិនចុះ លោកចូរប្រាប់កម្មដ្ឋានដល់ខ្ញុំ ឲ្យព្រះថេរៈប្រាប់កម្មដ្ឋានហើយ ក៏សម្រេចជាព្រះសោតាបន្ន អាស្រ័យរៀនឧទ្ទេស ។ សូម្បីជនពួកដទៃ រៀនឧទ្ទេសនេះ សម្រេចអរហត្តមិនមានចំនួន ។ ក៏ព្រះសូត្រនេះ ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនវៀរឡើយ ។

**[១៩៣]** បទថា **ហីនកាយូបគា** បានដល់ ជាអ្នកមានកាយថោកទាប ។ បទថា **ឧបាទានេ** គឺ ប្រកាន់ដោយតណ្ហា និងទិដ្ឋិ ។ បទថា **ជាតិមរណសម្ភវេ** បានដល់ ជាហេតុនៃការកើត និងការស្លាប់ ។ បទថា **អនុបាទា** បានដល់ មិនប្រកាន់ដោយឧបាទាន ៤ ។ បទថា **ជាតិមរណសង្ខយេ** គឺ រមែងរួចផុត

ព្រោះនិព្វាន ពោលគឺ ជាទីអស់ជាតិ និងមរណៈ ។

បទថា **ទិដ្ឋធម្មាភិនិព្វុតា** សេចក្តីថា រលត់ហើយ ដោយការរលត់កិលេស ទាំងពួងក្នុងទិដ្ឋធម៌ គឺ ក្នុងអត្តភាពនេះឯង ។ បទថា **សព្វទុក្ខំ ឧបច្ចគុ** គឺ ឈ្មោះថា កន្លងទុក្ខទាំងពួងបាន ។

ចប់អដ្ឋកថា ទេវទូតសូត្រ ទី ១០

ចប់វគ្គទី ៣

## រួមអដ្ឋកថាក្នុងសុញ្ញតវគ្គ


១-ចូឡសុញ្ញតសូត្រ
២-មហាសុញ្ញតសូត្រ
៣-អច្ឆរិយព្ភូតធម្មសូត្រ
៤-ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ
៥-ទន្តភូមិសូត្រ
៦-ភូមិជសូត្រ
៧-អនុរុទ្ធសូត្រ
៨-ឧបក្កិលេសសូត្រ
៩-ពាលបណ្ឌិតសូត្រ
១០-ទេវទូតសូត្រ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងសៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គីមអាន ម៉ៅ គីមសៀង<br>-ម៉ៅ ប៊ុនសន្ថា ក្អួយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម កឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឹន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គឹម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -ឧបាសិកា តាំង ផល្លា ព្រមទាំងស្វាមី និងបុត្ត | $ 10 US |
| -ឧបាសក តាំង សុខឡាយ ភរិយា និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផាអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈួ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

## តាមរយៈភិក្ខុចិត្តរក្សិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ភិក្ខុ ចៅ សៀប " អូស្ត្រាលី " | 100 AUS |
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលប៊ន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -ឧបាសិកា គង់ សារឿម | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -ឧបាសិកា កូវ សារី | 100 AUS |
| -ឧបាសិកា ឈ គិមស៊ិន និងបុត្ត សំ ថានី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឌី មុយ ឧបាសិកា តែ ចាន់ណាវ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាប៊ួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉ោគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃឹម វីឡាត់ | 50 AUS |
| -ឧបាសក តូ សឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គឹម លាភ ( មាណេ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |

| | |
|---|---|
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គឹម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភាវ ឧបាសិកា កាំង គឹមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ុម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារីម | 15 AUS |
| -ថៃស៊ីម,ថៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ្គិច | 10 AUS |
| -ឧបាសក គ្រួច សាន | 10 AUS |
| -ឧបាសិកា ស៊ា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងីមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វ៉ាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គឹម ស្រួន | 5 AUS |